# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ស្តង់ដាបច្ចេកទេសអគ្គិសនី

## លក្ខខណ្ឌលំអិត

## សម្រាប់មធ្យោបាយបញ្ជូននិងចែកចាយ

**ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

**ខែកក្កដា ឆ្នាំ ២០០៦**

# ស្តង់ដាបច្ចេកទេសអគ្គិសនី
# លក្ខខណ្ឌលំអិតសម្រាប់មធ្យោបាយបញ្ជូននិងចែកចាយ

## មាតិកា

## ជំពូក ១
## សេចក្តីផ្តើម


មាត្រា ១~. និយមន័យ

មាត្រា ២~. គោលបំណង

មាត្រា ៣~. វិសាលភាព

មាត្រា ៤~. ស្តង់ដាដែលត្រូវគោរពតាម

មាត្រា ៥~. ប្រភេទមធ្យោបាយបញ្ជូននិងចែកចាយអគ្គិសនី


## ជំពូក ២
## បញ្ញត្តិទូទៅសម្រាប់មធ្យោបាយបញ្ជូននិងចែកចាយអគ្គិសនី

### ផ្នែកទី ១
### បញ្ញត្តិទូទៅ


មាត្រា ៦~. ការបង្ការគ្រោះមហន្តរាយអគ្គិសនី

មាត្រា ៧~. ការបង្ការគ្រោះថ្នាក់បណ្តាលមកពីមធ្យោបាយអគ្គិសនី

មាត្រា ៨~. សុវត្ថិភាពចំពោះជនទី៣

មាត្រា ៩~. ការបង្ការការខូចមធ្យោបាយអគ្គិសនីដោយគ្រោះធម្មជាតិ

មាត្រា ១០~. ការបង្ការមិនឱ្យដាច់ចរន្តអគ្គិសនី

មាត្រា ១១~. ការការពារបរិក្ខារអគ្គិសនីទល់នឹងចរន្តលើស

មាត្រា ១២~. ការការពារទល់នឹងការឆ្លងប៉ះដី

មាត្រា ១៣~. ការការពារបរិស្ថាន

មាត្រា ១៤~. អាយុកាលនៃមធ្យោបាយអគ្គិសនី

មាត្រា ១៥~. លក្ខខណ្ឌទាក់ទងនឹងការធ្វើគម្រោងរៀបចំមធ្យោបាយអគ្គិសនី

មាត្រា ១៦~. ឯកសារបច្ចេកទេសរបស់មធ្យោបាយអគ្គិសនីនិងការទុកដាក់ថែរក្សាវា

មាត្រា ១៧~. ប្រព័ន្ធគមនាគមន៍ និងប្រព័ន្ធទូរគមនាគមន៍

មាត្រា ១៨~. ភាពត្រឹមត្រូវនៃនាឡិកាស្ទង់អគ្គិសនី

ផ្នែកទី២

ការភ្ជាប់ខ្សែដី

មាត្រា ១៩~. លក្ខខណ្ឌទូទៅនៃការភ្ជាប់ខ្សែដី

មាត្រា ២០~. ចំណាត់ថ្នាក់ការភ្ជាប់ខ្សែដី

មាត្រា ២១~. ការភ្ជាប់ខ្សែដីសម្រាប់ខ្សែបណ្តាញអគ្គិសនី

មាត្រា ២២~. ការភ្ជាប់ខ្សែដីសំរាប់រោងចក្រអគ្គិសនី អនុស្ថានីយ ស្ថានីយបែងចែក និងទីតាំង របស់អ្នកប្រើប្រាស់តង់ស្យុងខ្ពស់និងតង់ស្យុងមធ្យម

មាត្រា ២៣~. ការភ្ជាប់ខ្សែដីសម្រាប់ខ្សែបណ្តាញចែកចាយ និងទីតាំងរបស់អ្នកប្រើប្រាស់ តង់ស្យុងទាប

ផ្នែកទី៣

ខ្សែចម្លង

មាត្រា ២៤~. ខ្សែចម្លងសម្រាប់មធ្យោបាយបញ្ជូននិងចែកចាយ

មាត្រា ២៥~. ការតភ្ជាប់ខ្សែចម្លង

មាត្រា ២៦~. មេគុណសុវត្ថិភាពរបស់ខ្សែស្រាត និងខ្សែដី នៃបណ្តាញអាកាស

មាត្រា ២៧~. ការប្រើប្រាស់ក្បែរគ្នា និងការប្រើប្រាស់រួមគ្នា នៃបណ្តាញអគ្គិសនីឬបណ្តាញ គមនាគមន៍

មាត្រា ២៨~. បណ្តាញក្រោមដី

## ជំពូក ៣
## មធ្យោបាយបញ្ជូនតង់ស្យុងខ្ពស់

មាត្រា ២៩~. ឧបករណ៍ការពារសម្រាប់បរិក្ខាអគ្គិសនី

មាត្រា ៣០~. ការរៀបចំបង្គោលទ្រខ្សែអាកាសតង់ស្យុងខ្ពស់

មាត្រា ៣១~. ការគ្រោងប្រដាប់ទ្រសម្រាប់សំរាប់ខ្សែចម្លង និង/ឬ សម្រាប់ខ្សែដី នៃខ្សែបណ្តាញអាកាសតង់ស្យុងខ្ពស់

មាត្រា ៣២~. ការការពារទល់នឹងរន្ទះសម្រាប់ខ្សែបណ្តាញអាកាសតង់ស្យុងខ្ពស់

មាត្រា ៣៣~. ខ្សែស្រាតនៃខ្សែបណ្តាញអាកាសតង់ស្យុងខ្ពស់

មាត្រា ៣៤~. គម្លាតរវាងខ្សែស្រាតនិងបង្គោលទ្រនៃខ្សែបណ្តាញ អាកាសតង់ស្យុងខ្ពស់

មាត្រា ៣៥~. កំពស់ខ្សែបណ្តាញអាកាសតង់ស្យុងខ្ពស់

មាត្រា ៣៦~. គម្លាតរវាងខ្សែបណ្តាញអាកាសតង់ស្យុងខ្ពស់ និងមធ្យោបាយដទៃទៀត ឬដើមឈើ

មាត្រា ៣៧~. ការបង្ការចំពោះគ្រោះថ្នាក់និងការរំខានពីអាំង ឌុចស្យុងអេឡិចត្រូស្តាទិច និង អាំងឌុចស្យុងអេឡិចត្រូម៉ាញេទិច

មាត្រា ៣៨~. ឧបករណ៍ចាប់ចរន្តច្រាល

# ជំពូក ៤

# មធ្យោបាយចែកចាយតង់ស្យុងមធ្យមនិងតង់ស្យុងទាប


មាត្រា ៣៩៖ បង្គោលទ្រ

មាត្រា ៤០៖ ខ្សែបណ្ដាញអាកាសតង់ស្យុងមធ្យមនិងតង់ស្យុងទាប

មាត្រា ៤១៖ កំលាំងមេកានិចនៃអ៊ីសូឡាទ័រ

មាត្រា ៤២៖ ត្រង់ស្វូរម៉ាទ័រតង់ស្យុងមធ្យម/ទាប

មាត្រា ៤៣៖ ការតម្លើងត្រង់ស្វូរម៉ាទ័រចែកចាយសម្រាប់ប្រព័ន្ធខ្សែទោលចរន្តត្រឡប់តាមដី **(SWER)**

មាត្រា ៤៤៖ ឧបករណ៍ការពារ

មាត្រា ៤៥៖ កំពស់នៃខ្សែបណ្ដាញអាកាសតង់ស្យុងមធ្យមនិងតង់ស្យុងទាប

មាត្រា ៤៦៖ គម្លាតរវាងខ្សែបណ្ដាញអាកាសតង់ស្យុងមធ្យមនិងតង់ស្យុងទាប និងវត្ថុដទៃទៀត

មាត្រា ៤៧៖ លក្ខខ័ណ្ឌនៅជិតគ្នានិងកាត់ខ្វែងគ្នានៃខ្សែបណ្ដាញអាកាសតង់ស្យុងមធ្យមនិងតង់ស្យុងទាប

# ជំពូក ១

# សេចក្តីផ្តើម

## មាត្រា ១.. និយមន័យ

នៅក្នុងល័ក្ខខ័ណ្ឌលំអិតនៃស្តង់ដាបច្ចេកទេសអគ្គិសនីនេះ ប្រសិនបើពុំមានការបញ្ជាក់ខ្លឹមសារណាផ្សេងទេ ពាក្យទាំងឡាយខាងក្រោមនេះ ត្រូវមាននិយមន័យដូចការពន្យល់ខាងក្រោម:

**១. អ.អ.ក**

" អ.អ.ក " គឺជាអក្សរកាត់នៃអាជ្ញាធរអគ្គិសនីកម្ពុជា ។

**២. ខ្សែបណ្តាញអគ្គិសនី**

"ខ្សែបណ្តាញអគ្គិសនី " គឺជាផ្នែកមួយនៃមធ្យោបាយអគ្គិសនី ដែលប្រើសំរាប់បញ្ជូនឬផ្គត់ផ្គង់អគ្គិសនី ។ ខ្សែបណ្តាញអគ្គិសនីតភ្ជាប់ស្ថានីយអគ្គិសនី អនុស្ថានីយ ស្ថានីយបែងចែក និងកន្លែងប្រើប្រាស់អគ្គិសនី ។ "ខ្សែបណ្តាញអគ្គិសនី " ក៏គិតបញ្ចូលទាំងខ្សែបណ្តាញដែលបិតនៅក្នុងប្រដាប់ការពារនិងប្រដាប់បិទបើកពាក់ព័ន្ធផងដែរ។

**៣. មធ្យោបាយអគ្គិសនី**

"មធ្យោបាយអគ្គិសនី " គឺមធ្យោបាយទាំងអស់ដែលសម្រាប់ផលិត បញ្ជូននិងផ្គត់ផ្គង់អគ្គិសនី ដូចជារោងចក្រផលិតអគ្គិសនី អនុស្ថានីយ ស្ថានីយបែងចែក ខ្សែបណ្តាញអគ្គិសនី មជ្ឈមណ្ឌលបញ្ជា។ល។ នៅក្នុងនេះក៏គិតបញ្ចូលទាំងបរិក្ខា អគារ ទំនប់ ផ្លូវទឹក កន្លែង ស្តុកប្រេងឥន្ធនៈ និងកន្លែងចាក់កាកសំណល់។ល។ ដែរ ។

**៤. បរិក្ខាអគ្គិសនី**

"បរិក្ខាអគ្គិសនី " គឺជាមធ្យោបាយអគ្គិសនីដែលមានផ្ទុកចរន្តអគ្គិសនី។

**៥. លទសបអ**

"លទសបអ "គឺជាអក្សរកាត់នៃពាក្យល័ក្ខខ័ណ្ឌទូទៅនៃស្តង់ដាបច្ចេកទេសអគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជា ។

**៦. ខ្សែទប់**

ខ្សែទប់ គឺជាខ្សែដែលជួយពង្រឹងគ្រឹះរបស់បង្គោលទ្រ ។ ជាធម្មតាគេចងទប់ពីចុងបង្គោលមកជាមួយនឹងដី ។

**៧. ខ្សែបណ្តាញតង់ស្យុងខ្ពស់**

"ខ្សែបណ្តាញតង់ស្យុងខ្ពស់ " គឺជាខ្សែបណ្តាញអគ្គិសនីដែលមាន តង់ស្យុងខ្ពស់ជាង ៣៥ គីឡូវ៉ុល ។

## ៨. IEC

IEC គឺជាអក្សរកាត់នៃពាក្យ International Electrotechnical Commission មានន័យថា គណកម្មការបច្ចេកទេសអគ្គិសនីអន្តរជាតិ ។

## ៩. ខ្សែស្រោម

"ខ្សែស្រោម "មានន័យថាគឺជាខ្សែដែលស្រោបដោយប៉ូលីអេទីឡែន (XLPE) សំរាប់ខ្សែបណ្តាញតង់ស្យុងមធ្យម និងខ្សែដែលស្រោបដោយ XLPE ឬស្រោបដោយប៉ូលីវិនីលក្លរ (PVC) សំរាប់ខ្សែបណ្តាញតង់ស្យុងទាប ។

## ១០. ISO

ISO ជាអក្សរកាត់នៃពាក្យ International Organization for Standardization មានន័យថា អង្គការអន្តរជាតិសំរាប់ការងារស្តង់ដា ។

## ១១. ការប្រើរួមគ្នា

" ការប្រើប្រាស់រួមគ្នា " គឺជាល័ក្ខខ័ណ្ឌមួយដែលខ្សែបណ្តាញអគ្គិសនី និង/ឬ ខ្សែបណ្តាញគមនាគមន៍ដែលជាកម្មសិទ្ធរបស់ម្ចាស់២នាក់ ឬច្រើននាក់បានតម្លើងនៅលើបង្គោលតែមួយ ។

## ១២. ខ្សែបណ្តាញតង់ស្យុងទាប

"ខ្សែបណ្តាញតង់ស្យុងទាប " មានន័យថាខ្សែបណ្តាញអគ្គិសនី ដែលមានតង់ស្យុងមិនលើសពី ៦០០វ៉ុល ។

## ១៣. ខ្សែបណ្តាញតង់ស្យុងមធ្យម

"ខ្សែបណ្តាញតង់ស្យុងមធ្យម " មានន័យថាខ្សែបណ្តាញអគ្គិសនីដែល មានតង់ស្យុងខ្ពស់ជាង៦០០វ៉ុល ប៉ុន្តែមិនលើសពី ៣៥ គីឡូវ៉ុល ។

## ១៤. ប្រព័ន្ធបណ្តាញជាតិបញ្ជូនអគ្គិសនី

"ប្រព័ន្ធបណ្តាញជាតិបញ្ជូនអគ្គិសនី " គឺជាប្រព័ន្ធតង់ស្យុងខ្ពស់ដែលជាឆ្អឹងខ្នងនៃខ្សែបណ្តាញបញ្ជូន ដែលតភ្ជាប់គ្នាទៅវិញទៅមកនូវអនុស្ថានីយ ព្រមទាំងមធ្យោបាយពាក់ព័ន្ធទាំងឡាយសំរាប់គោលបំណងដឹកជញ្ជូនអគ្គិសនីធំ ។

## ១៥. ការរៀបចំហ្វាផ្ទុយគ្នា

" ការរៀបចំហ្វាផ្ទុយគ្នា " មានន័យថាការរៀបចំខ្សែបណ្តាញអាកាសដែលមានពីសៀគ្វី ដែលលំដាប់ ៣ ហ្វា របស់សៀគ្វីមួយត្រូវខុសគ្នា និងសៀគ្វីមួយទៀតដូចមានបង្ហាញនៅក្នុងគំរូខាងស្តាំ ។




## ១៦. RTU

RTU គឺជាអក្សរកាត់នៃពាក្យ Remote Terminal Unit ដែល មានន័យថា ឧបករណ៍ធ្វើការពីចម្ងាយ របស់ប្រព័ន្ធ SCADA ដែលតម្លើងនៅនឹងមធ្យោបាយអគ្គិសនីណាមួយ សំរាប់ធ្វើការត្រួតមើល និងបញ្ជាមធ្យោបាយអគ្គិសនីនោះពីចម្ងាយ ។

## ១៧. SCADA

SCADA គឺជាអក្សរកាត់នៃពាក្យ Supervisory, Control, and Data Acquisition មានន័យថា ប្រព័ន្ធសំរាប់គ្រប់គ្រង បញ្ជា និងទទួលទិន្នន័យ ។

## ១៨. ការប្រើប្រាស់ក្បែរគ្នា

" ការប្រើប្រាស់ក្បែរគ្នា " គឺជាល័ក្ខខ័ណ្ឌមួយដែលខ្សែបណ្តាញ អគ្គិសនី និង/ឬ ខ្សែបណ្តាញគមនាគមន៍របស់ម្ចាស់តែ១ ត្រូវតម្លើងនៅលើបង្គោលទ្រមួយ ។

## ១៩. លលសបអ

**"លលសបអ "** គឺជាអក្សរកាត់នៃពាក្យល័ក្ខខ័ណ្ឌលំអិតនៃស្តង់ដាបច្ចេកទេសអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។

## ២០. អនុស្ថានីយ

"អនុស្ថានីយ " គឺជាមធ្យោបាយអគ្គិសនីដែលនៅទីនោះតង់ស្យុងអគ្គិសនីត្រូវបានផ្លាស់ប្តូរ ហើយក្នុងនោះមានត្រង់ស្វូម៉ាទ័រ ឧបករណ៍ការពាររន្ទះ ឌីស្យុងទ័រ ប្រដាប់កាត់ផ្តាច់ ត្រង់ស្វូម៉ាទ័រតង់ស្យុង ត្រង់ស្វូម៉ាទ័រចរន្ត របាតង់ស្យុង ប្រព័ន្ធរឺឡេការពារ RTU សំរាប់ ប្រព័ន្ធ SCADA, មធ្យោបាយទូរគមនាគមន៍ ។ល។

## ២១. បង្គោលទម្រ

"បង្គោលទម្រ " គឺជារចនាសម្ព័ន្ធសំរាប់ទ្រខ្សែបណ្តាញអគ្គិសនី ដូចជាបង្គោលឈើ បង្គោលដែក បង្គោលបេតុង និងបង្គោលបំពង់ ដែក ។

## ២២. SWER

"SWER" គឺជាអក្សរកាត់នៃពាក្យ Single Wire Earth Return system មានន័យថា ប្រព័ន្ធខ្សែមួយចម្លងអគ្គិសនីត្រលប់មកវិញតាមដី ។ "SWER" គឺជាវិធីចែកចាយអគ្គិសនីមួយដែលប្រើខ្សែចំលងតែ មួយខ្សែ ហើយអគ្គិសនីធ្វើដំណើរត្រលប់មកវិញតាមដី ។

## ២៣. ស្ថានីយបែងចែក

"ស្ថានីយបែងចែក " គឺជាមធ្យោបាយអគ្គិសនីសំរាប់ប្តូរការផ្គត់ផ្គង់អគ្គិសនីឱ្យខ្សែបណ្តាញ ដែលរួមមានប្រដាប់ផ្តាច់ ឌីស្យុងទ័រ របាតង់ស្យុង ប្រព័ន្ធរ៉ឺឡេការពារ, RTU សំរាប់ប្រព័ន្ធ SCADA ។ល។

## ២៤. ស្តង់ដាបច្ចេកទេស

"ស្តង់ដាបច្ចេកទេស " មានន័យថាជា ស្តង់ដាបច្ចេកទេសអគ្គិសនី ក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ២៥. ទីតាំងអ្នកប្រើប្រាស់

"ទីតាំងអ្នកប្រើប្រាស់ " មានន័យថា ទីកន្លែងដែលគេតម្លើងម៉ាស៊ីន បរិធាន និងគ្រឿងប្រដាប់ផ្សេងទៀត សំរាប់ប្រើប្រាស់អគ្គិសនី ។

# មាត្រា ២. គោលបំណង

លក្ខខ័ណ្ឌលំអិតនៃស្តង់ដាបច្ចេកទេសអគ្គិសនីសម្រាប់មធ្យោបាយបញ្ជូននិងចែកចាយអគ្គិសនី កំណត់លក្ខខ័ណ្ឌសំខាន់ៗទាំងឡាយដែលត្រូវការចាំបាច់សម្រាប់បញ្ញត្តិមធ្យោបាយបញ្ជូននិងចែកចាយអគ្គិសនី ដែលកំពុងមានឬដែលមានផែនការនឹងសាងសង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ លក្ខខ័ណ្ឌទាំងឡាយដែលកំណត់នៅក្នុងឯកសារស្តង់ដានេះ មានគោលបំណងសំខាន់បំផុតគឺធ្វើយ៉ាងណាកុំឱ្យគ្រោះថ្នាក់ដល់មធ្យោបាយអគ្គិសនី និងមានសុវត្ថិភាពក្នុងដំណើរការមធ្យោបាយអគ្គិសនីនោះ ។

## មាត្រា ៣.. វិសាលភាព

មធ្យោបាយបញ្ជូននិងចែកចាយអគ្គិសនីទាំងអស់នៅក្នុង ព្រះរាជាណាចក្រកម្ពុជា ត្រូវតែមានលក្ខណៈស្របតាម ល័ក្ខខ័ណ្ឌទាំងឡាយ ដែលកំណត់នៅក្នុងស្តង់ដាបច្ចេកទេសនេះ ។

បុគ្គលទាំងអស់ ទាំងអ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មអគ្គិសនី ទាំងទីប្រឹក្សាបច្ចេកទេស ទាំងអ្នកម៉ៅការសាងសង់ និងទាំងអ្នកប្រើប្រាស់អគ្គិសនី ដែលពាក់ព័ន្ធនឹង ការសិក្សា ការរៀបចំ ការសាងសង់និងការដំណើរការមធ្យោបាយបញ្ជូននិងចែកចាយអគ្គិសនី នៅក្នុង ព្រះរាជាណាចក្រកម្ពុជា ត្រូវតែគោរពតាមល័ក្ខខ័ណ្ឌទាំងឡាយដែលមានចែងនៅក្នុងល័ក្ខខ័ណ្ឌលំអិតនៃស្តង់ដាបច្ចេកទេសអគ្គិសនីនេះ ។

## មាត្រា ៤.. ស្តង់ដាដែលត្រូវគោរពតាម

មធ្យោបាយបញ្ជូននិងចែកចាយអគ្គិសនី ដែលមានផែនការនឹងសាងសង់ ព្រមទាំងដាក់ឱ្យដំណើរការនៅក្នុង ព្រះរាជាណាចក្រកម្ពុជា ត្រូវគោរពតាមស្តង់ដាបច្ចេកទេសអគ្គិសនីនៃ ព្រះរាជាណាចក្រកម្ពុជា ។ ក្នុងករណីដែលបញ្ហាណាមួយមិនមានចែងក្នុងស្តង់ដាបច្ចេកទេសនេះទេ ត្រូវគោរពតាមស្តង់ដា IEC ។ ប្រសិនបើបញ្ហានេះមិនមានកំណត់នៅក្នុងស្តង់ដា IEC ទេ ពេលនោះត្រូវគោរពតាមស្តង់ដា ISO ។ ប្រសិនបើបញ្ហានេះនៅតែមិនមានកំណត់នៅក្នុងស្តង់ដា ISO ទេនោះ ពេលនោះត្រូវគោរពតាមស្តង់ដាណាមួយដែល មានការទទួលស្គាល់ជាអន្តរជាតិ ក្នុងល័ក្ខខ័ណ្ឌដែលមានការយល់ព្រមពីក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ។

## មាត្រា ៥.. ប្រភេទមធ្យោបាយបញ្ជូននិងចែកចាយអគ្គិសនី

មធ្យោបាយបញ្ជូននិងចែកចាយអគ្គិសនីដែលបញ្ញត្តិនៅក្នុងល័ក្ខខ័ណ្ឌលំអិតនៃស្តង់ដាបច្ចេកទេសអគ្គិសនីនេះ ត្រូវបានបែងចែកជា ២ ប្រភេទ គឺ :

១- មធ្យោបាយតង់ស្យុងខ្ពស់

២- មធ្យោយបាយតង់ស្យុងមធ្យមនិងទាប

# ជំពូក ២

# បញ្ញត្តិទូទៅ

# សម្រាប់មធ្យោបាយ

# បញ្ជូននិងចែកចាយអគ្គិសនី

# ផ្នែកទី ១
# បញ្ញត្តិទូទៅ

## មាត្រា ៦.. ការបង្ការគ្រោះមហន្តរាយអគ្គិសនី

បរិក្ខាអគ្គិសនីត្រូវតែតម្លើងតាមរបៀបដែលមិនបណ្តាលឱ្យមានការឆក់អគ្គិសនី អគ្គិភ័យ និងគ្រោះថ្នាក់ដទៃទៀត ។

## មាត្រា ៧.. ការបង្ការគ្រោះថ្នាក់បណ្តាលមកពីមធ្យោបាយអគ្គិសនី

មធ្យោបាយអគ្គិសនីត្រូវតម្លើងដោយមានវិធានការណ៍ការពារត្រឹមត្រូវ មិនឱ្យអ្នកដំណើរការប៉ះពាល់ដល់ផ្នែកមានចរន្ត ផ្នែកដែលក្តៅ និងផ្នែកដែលមានគ្រោះថ្នាក់ដទៃទៀតរបស់វា ហើយនិងបង្កាមិនឱ្យអ្នកដំណើរការអាចធ្លាក់ពីលើមធ្យោបាយទាំងនោះដោយចៃដន្យ ។

## មាត្រា ៨.. សុវត្ថិភាពចំពោះជនទី៣

### ១.សុវត្ថិភាពចំពោះជនទី៣នៅអនុស្ថានីយ និងស្ថានីយបែងចែកអគ្គិសនី

ត្រូវចាត់វិធានការណ៍សមស្របដើម្បីបង្ការជនទី៣មិនឱ្យចូលទៅក្នុងអនុស្ថានីយ និងស្ថានីយបែងចែកអគ្គិសនី ។ វិធានការណ៍ទាំងនេះមាន :

**ក.** ត្រូវមានរបងឬជញ្ជាំងខាងក្រៅដែលខ័ណ្ឌបរិវេណខាងក្រៅពីបរិវេណខាងក្នុង ។ កំពស់របងឬជញ្ជាំងខាងក្រៅនេះមិនត្រូវទាបជាង ១៨០០ មម ឡើយ ។ គម្លាតពីព្រំប្រទល់នៃរបងឬជញ្ជាំង ទៅបរិក្ខាអគ្គិសនី មិនត្រូវតូចជាងចំនួនដែលបានកំណត់នៅក្នុងតារាងខាងក្រោមឡើយ ។

**តារាងទី១..គម្លាតព្រំប្រទល់នៃរបងឬជញ្ជាំងទៅបរិក្ខាអគ្គិសនី**

| កំរិតតង់ស្យុង | កពស់របង ឬជញ្ជាំង | គម្លាតពីព្រំប្រទល់ទៅបរិក្ខាអគ្គិសនី " មីល្លីម៉ែត្រ " | |
|---|---|---|---|
| គីឡូវ៉ុល | មីល្លីម៉ែត្រ | ករណីជញ្ជាំង | ករណីរបង |
| ២២ | មិនតិចជាង ១៨០០ | មិនតិចជាង ២១០០ | មិនតិចជាង ២៦០០ |
| ១១៥ | មិនតិចជាង ១៨០០ | មិនតិចជាង ២១០០ | មិនតិចជាង ២៦០០ |
| ២៣០ | មិនតិចជាង ១៨០០ | មិនតិចជាង ២៩០០ | មិនតិចជាង ៣៤០០ |

**ខ.** ត្រូវដាក់ផ្លាកសញ្ញាបង្ហាញពីគ្រោះថ្នាក់ នៅច្រកចេញចូលដើម្បីឱ្យជនទីបីប្រុងប្រយ័ត្ន ។ ដោយឡែកនៅតាមរបង ឬនៅតាមជញ្ជាំង ប្រសិនបើចាំបាច់ក៏ត្រូវដាក់ផ្លាកសញ្ញាគ្រោះថ្នាក់ដែរ ។

**គ.** ត្រូវរៀបចំឱ្យមានសោរឬប្រដាប់សមស្របដទៃទៀត នៅច្រកចេញចូល ។

### ២.សុវត្ថិភាពចំពោះជនទី៣នៅបង្គោលទ្រខ្សែអគ្គិសនី

ត្រូវចាត់វិធានការណ៍សមស្របដើម្បីបង្ការជនទី៣មិនឱ្យឡើងទៅលើបង្គោលទ្រខ្សែបណ្តាញអាកាសអគ្គិសនី ។ ដើម្បីបង្ការគ្រោះថ្នាក់ចំពោះជនទី៣ពាក់ព័ន្ធនឹងបង្គោលទ្រខ្សែបណ្តាញអគ្គិសនី ត្រូវអនុវត្តវិធានការណ៍ ដូចខាងក្រោម :

- មិនត្រូវតម្លើងជណ្តើរលោហៈនៃបង្គោលទម្រនៅកំពស់ទាបជាង ១.៨ ម៉ែត្រ ពីដីឡើយ
- សញ្ញាប្រុងប្រយ័ត្នដើម្បីឱ្យជនទី៣ដឹងពីគ្រោះថ្នាក់ ត្រូវតម្លើងនៅតាមបង្គោលទ្រនីមួយៗ
- ចំពោះខ្សែបណ្តាញតង់ស្យុងខ្ពស់ត្រូវតម្លើងរបាំងសមស្របនៅគ្រប់ជើងបង្គោលទម្រ ដើម្បីការពារជនទី៣មិនឱ្យឡើងទៅលើបង្គោលទម្របាន ។ ប៉ុន្តែក្នុងករណីដែលបង្គោលទម្រមានទីតាំងស្ថិតនៅកន្លែងដែលជនទី៣ពិបាកនឹងចូលទៅជិតបាន ដូចជានៅលើភ្នំ ឬក៏មានរបងឬជញ្ជាំងដែលមានកំពស់សមល្មមហ៊ុំព័ទ្ធបង្គោលទម្រ ពេលនោះអាចមិនបាច់តម្លើងរបាំងការពារនៅជើងបង្គោលបាន ។

## មាត្រា ៩.. ការបង្ការការខូចមធ្យោបាយអគ្គិសនីដោយគ្រោះធម្មជាតិ

ត្រូវមានវិធានការសមស្រប ដើម្បីបង្ការមធ្យោបាយអគ្គិសនីមិនឱ្យខូចដោយគ្រោះធម្មជាតិដែលបានព្យាករណ៍ទុកជាមុន ដូចជាទឹកជំនន់ រន្ទះ រញ្ជួយដី និងខ្យល់បក់ខ្លាំង ។

## មាត្រា ១០.. ការបង្ការមិនឱ្យដាច់ចរន្តអគ្គិសនី

- នៅពេលមធ្យោបាយអគ្គិសនីណាមួយខូចធ្ងន់ធ្ងរ មធ្យោបាយនោះត្រូវតែផ្តាច់ចេញពីប្រព័ន្ធអគ្គិសនីយ៉ាងណា ដើម្បីឱ្យឥទ្ធិពលនៃការខូចរបស់វាទៅលើប្រព័ន្ធអាចថយចុះនក៏រិតតិចតួចបំផុត ហើយប្រព័ន្ធនោះអាចមានលទ្ធភាពនៅបន្តដំណើរការជាធម្មតា ។
- នៅពេលមានកំហូចប្រព័ន្ធអគ្គិសនីកើតឡើងនៅក្នុងប្រព័ន្ធមួយ ដែលភ្ជាប់ជាមួយមធ្យោបាយផលិតកម្មអគ្គិសនីមួយ មធ្យោបាយផលិតកម្មអគ្គិសនីនោះត្រូវតែផ្តាច់ចេញពីប្រព័ន្ធភ្លាម ដើម្បីឱ្យហ្សេនេរ៉ាទ័ររបស់វាដំណើរការបន្តទៀតដោយគ្មានបន្ទុក រង់ចាំការជួសជុលកែតម្រូវប្រព័ន្ធឱ្យធម្មតាឡើងវិញ ។
- នៅពេលដែលមានកំហូចលើខ្សែបណ្តាញអគ្គិសនីកើតឡើង តំបន់ផ្តាច់ចរន្តត្រូវបន្ថយឱ្យនៅចំនួនតិចតួចបំផុតតាមលទ្ធភាពអាចធ្វើបាន ដោយកាត់ផ្តាច់តែផ្នែកណាដែលមានកំហូចឬដោយប្រើវិធីសមស្របដទៃទៀត ។

## មាត្រា ១១.. ការការពារបរិក្ខារអគ្គិសនីពលនឹងចរន្តលើស

### ១. លក្ខណៈទូទៅ

ដើម្បីការពារបរិក្ខារអគ្គិសនីកុំឱ្យឡើងកំដៅហួសដោយចរន្តលើសខ្លាំង និងដើម្បីការពារកុំឱ្យកើតមានអគ្គីភ័យ ត្រូវតម្លើងឧបករណ៍ការពារចរន្តលើសនៅកន្លែងសមស្របនៃសៀគ្វីអគ្គិសនី ។

### ២. លក្ខណៈនៃឧបករណ៍ការពារចរន្តលើសសម្រាប់ខ្សែបណ្តាញតង់ស្យុងខ្ពស់ និងខ្សែបណ្តាញតង់ស្យុងមធ្យម

ក. លក្ខណៈនៃហ្វុយស្សីបដែលប្រើសម្រាប់ការពារចរន្តលើសនៅលើសៀគ្វីអគ្គិសនីតង់ស្យុងមធ្យម ត្រូវអនុលោមទៅតាមការកំណត់នៃ IEC 60282 (2002-01) [ហ្វុយស្សីបតង់ស្យុងខ្ពស់] ។

ខ. លក្ខណៈនៃឌីស្យុងទ័រដែលប្រើសម្រាប់ការពារចរន្តលើសនៅលើសៀគ្វីអគ្គិសនីតង់ស្យុងមធ្យម ត្រូវអនុលោមទៅតាមការកំណត់នៃ IEC ៦២២៧១ [ប្រដាប់កាត់ផ្តាច់និងប្រដាប់ចុចបញ្ជា] ។

គ. ឌីស្យុងទ័រការពារចរន្តលើស ត្រូវមានគ្រឿងប្រដាប់សំគាល់ពីស្ថានភាពបិទបើករបស់វា ។ ទោះជាយ៉ាងនេះក៏ដោយ ប្រសិនបើគេអាចសំគាល់ស្ថានភាពបិទបើករបស់វាដោយងាយស្រួលនោះ វាមិនចាំបាច់មានប្រដាប់សំគាល់នេះទេ ។

## មាត្រា ១២_. ការការពារទល់នឹងការឆ្លងប៉ះដី

ដើម្បីទប់ស្កាត់ការខូចបរិក្ខាអគ្គិសនី ការឆក់អគ្គិសនី និងអគ្គីភ័យ ដោយសារការឆ្លងប៉ះដី ត្រូវតម្លើងឧបករណ៍ការពារទល់នឹងការឆ្លងប៉ះដី ឬមានវិធានការណ៍សមស្របដទៃទៀត ។

## មាត្រា ១៣_. ការការពារបរិស្ថាន

### ១. ល័ក្ខខ័ណ្ឌគោរពស្តង់ដាបរិស្ថាន

ដើម្បីបង្ការកុំឱ្យមានការបំពុលបរិស្ថាន មធ្យោបាយអគ្គិសនីត្រូវតែសាងសង់ឡើងស្របទៅតាមច្បាប់និងបទប្បញ្ញត្តិបរិស្ថាននានា នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

### ២. ការហាមឃាត់មិនឱ្យតម្លើងគ្រឿងម៉ាស៊ីនឬបរិក្ខាអគ្គិសនីដែលប្រើប៉ូលីក្លរីណាតហ្វេណុល (ហៅកាត់ថា PCB )

ក. ការតម្លើងបរិក្ខាអគ្គិសនីថ្មីដែលប្រើប្រេងរំអិលជាអ៊ីសូឡង់ ហើយក្នុងនោះមានសារធាតុ PCB ច្រើនជាង០,០០៥ ភាគរយ (៥០ ppm ) ឡើងទៅ ត្រូវបានហាមឃាត់ ។

ខ អាចអនុញ្ញាតឱ្យប្រើប្រាស់បរិក្ខាអគ្គិសនីដែលកំពុងមានបច្ចុប្បន្ន ទោះជាក្នុងបរិក្ខានោះមានសារធាតុ PCB ក៏ដោយ ប្រសិនបើបរិក្ខាអគ្គិសនីនោះត្រូវបានតម្លើងមុនពេលល័ក្ខខ័ណ្ឌលម្អិតនៃស្តង់ដាបច្ចេកទេសអគ្គិសនីចូលជាធរមាន ប៉ុន្តែត្រូវចាត់វិធានការណ៍មានប្រសិទ្ធភាព ដើម្បីការពារកុំឱ្យសារធាតុ PCB លិចធ្លាយចេញពីធុងប្រេង ។

គ នៅពេលដែលវត្ថុធាតុដែលមានសារធាតុ PCB ច្រើនជាង ០,០០៥ ភាគរយ(៥0ppm) ត្រូវបានយកចេញពីបរិក្ខាអគ្គិសនីណាមួយ វត្ថុធាតុនេះនេះមិនត្រូវយកទៅប្រើនៅក្នុងបរិក្ខាអគ្គិសនីមួយទៀតឡើយ គឺត្រូវរំលាយចោលឱ្យបានត្រឹមត្រូវ ដូចជាសំណល់ពុលឧស្សាហកម្ម ។

## មាត្រា ១៤.. អាយុកាលនៃមធ្យោបាយអគ្គិសនី

មធ្យោបាយអគ្គិសនីត្រូវតែឋិតថេរសំរាប់ការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនិងស្ថិរភាពក្នុងរយៈពេលវែង ។

## មាត្រា ១៥.. ល័ក្ខខ័ណ្ឌទាក់ទងនឹងការធ្វើគម្រោងរៀបចំមធ្យោបាយអគ្គិសនី

ក្នុងការធ្វើគម្រោងរៀបចំមធ្យោបាយអគ្គិសនី ការជ្រើសរើសសំភារៈ ការផ្គុំនិងតម្លើងបរិក្ខារដែលពាក់ព័ន្ធ ត្រូវធ្វើការថ្លឹងថ្លែងមេគុណសុវត្ថិភាពឱ្យបានសមស្រប ដើម្បីទប់ទល់នឹងសភាពតានតឹងដែលអាចព្យាករណ៍ទុកជាមុន ដូចជាសភាពនិងភាពធន់របស់អ៊ីសូឡង់ តានតឹងដោយកំដៅនិច សភាពតានតឹងដោយមេកា។

### ១.ការសម្របសម្រួលកំរិតអ៊ីសូឡង់

ត្រូវធ្វើការសម្របសម្រួលកំរិតអ៊ីសូឡង់របស់បរិក្ខានិងមធ្យោបាយអគ្គិសនីនានា ដូចជាស្ថានីយអគ្គិសនី បណ្តាញបញ្ជូន បណ្តាញចែកចាយ យ៉ាងណា ដើម្បីឱ្យវាអាចឋិតនៅក្នុងល័ក្ខខ័ណ្ឌមួយដែលសមហេតុផលជាងគេ ដោយគិតគូរលើគ្រប់បញ្ហាដូចជា បច្ចេកទេស សេដ្ឋកិច្ច និងការដំណើរការ ។ ក្នុងការសម្របសម្រួលកំរិតអ៊ីសូឡង់ ត្រូវយកចិត្តទុកដាក់ចំណុចសំខាន់ខ្លះដូចខាងក្រោម :

#### ក. តង់ស្យុងស្តង់ដាទ្រាំបានរបស់អ៊ីសូឡង់

ក្នុងការជ្រើសរើសបរិក្ខាអគ្គិសនី អ៊ីសូឡង់របស់បរិក្ខានោះត្រូវសមស្របជាមួយនឹង "តង់ស្យុងស្តង់ដារបស់អាំពុលផ្លេកបន្ទោរដែលអ៊ីសូឡង់ទ្រាំបាន " និង " តង់ស្យុងស្តង់ដារបស់ហ្វ្រេកង់រយៈពេលខ្លីដែលអ៊ីសូឡង់ទ្រាំបាន " ដែលមានបង្ហាញក្នុងតារាង "តង់ស្យុងស្តង់ដាទ្រាំបានរបស់អ៊ីសូឡង់ " ខាងក្រោម ។

**តារាងទី២_តង់ស្យុងស្តង់ដាទ្រាំបានរបស់អ៊ីសូឡង់**

| តង់ស្យុងណូមីណាល់ | 22kV | 115kV | 230kV |
|---|---|---|---|
| តង់ស្យុងស្តង់ដាររបស់អាំពុលផ្លេកបន្ទោរដែលអ៊ីសូឡង់ទ្រាំបាន | 95,125,145kV | 550kV | 950kV |
| តង់ស្យុងស្តង់ដាររបស់ប្រេកង់រយៈពេលខ្លីដែលអ៊ីសូឡង់ទ្រាំបាន | 50kV | 230kV | 360,395kV |

**ខ. ការតម្លើងឧបករណ៍ចាប់ចរន្តច្រាល**

ត្រូវធ្វើការគ្រប់គ្រង "អាំពុលផ្លេកបន្ទោរ" និង "អាំពុលនៃការបិទបើក" ដោយតម្លើងឧបករណ៍ចាប់ចរន្តច្រាល ដើម្បីសម្របសម្រួលវាឱ្យបានត្រឹមត្រូវ ។

**គ. ការសម្របសម្រួលកំរិតអ៊ីសូឡង់របស់រោងចក្រអគ្គិសនី អនុស្ថានីយ និងខ្សែបណ្តាញបញ្ជូន**

ដើម្បីបង្ការទល់នឹងអាំពុលផ្លេកបន្ទោរ ដែលជ្រៀតចូលទៅរោងចក្រអគ្គិសនី អនុស្ថានីយ ស្ថានីយបែងចែកពីខ្សែបណ្តាញបញ្ជូន ឱ្យបានជាអតិបរមាគម្លាតនៃក្បាលកោងច្រាលអគ្គិសនីរបស់បង្គោលដែកជិតរោងចក្រអគ្គិសនី អនុស្ថានីយ ស្ថានីយបែងចែក ត្រូវសម្របសម្រួលជាមួយកំរិតតង់ស្យុងស្តង់ដាទ្រាំបានរបស់បរិក្ខាអគ្គិសនីនៅក្នុងរោងចក្រអគ្គិសនី អនុស្ថានីយ និងស្ថានីយបែងចែក ។

## ២. កំលាំងឌីអេឡិចទ្រិចនៅក្នុងសៀគ្វីអគ្គិសនី

ត្រូវពិនិត្យកំលាំងឌីអេឡិចទ្រិចរបស់សៀគ្វីអគ្គិសនីឱ្យបានច្បាស់លាស់ ដោយការធ្វើតេស្តកំលាំងឌីអេឡិចទ្រិច ការវាស់រ៉េស៊ីស្តង់អ៊ីសូឡង់ ។ល។ ដើម្បីធានាថា លទ្ធភាពដំណើរការរបស់វាត្រូវគ្នាជាមួយតង់ស្យុងណូមីណាល់របស់វា ។

បន្ថែមពីលើនេះ មុនពេលចាប់ផ្តើមដំណើរការ ត្រូវធ្វើកាបញ្ជាក់កំលាំងឌីអេឡិចទ្រិចឱ្យបានច្បាស់ ដោយការបញ្ចូលតង់ស្យុងណូមីណាល់ឱ្យសៀគ្វីនោះជាប់បន្តគ្នាចំនួន ១០ នាទី ។

ទោះជាយ៉ាងនេះក៏ដោយ ប្រសិនបើតង់ស្យុងណូមីណាល់របស់សៀគ្វីអគ្គិសនីគឺជាតង់ស្យុងទាប គេអាចធ្វើតេស្តដោយត្រឹមតែវាស់រ៉េស៊ីស្តង់អ៊ីសូឡង់ ឬចរន្តជ្រាបចេញប៉ុណ្ណោះ ។ ក្នុងករណីវាស់ចរន្តជ្រាបចេញ អាចរក្សាចរន្តនេះត្រឹមកំរិត ១ មីលីអាំពែរ ឬ ទាបជាងនេះ គឺជាការគ្រប់គ្រាន់ ។

## ៣. កំលាំងធន់និងកំដៅនៃបរិក្ខាអគ្គិសនី

បរិក្ខាអគ្គិសនីដែលតម្លើងនៅអនុស្ថានីយ ស្ថានីយបែងចែក និងកន្លែងប្រើប្រាស់អគ្គិសនីតង់ស្យុងមធ្យមនិងខ្ពស់ ត្រូវមានលទ្ធភាពធន់ នឹងកំដៅ ដែលបង្កើតឡើងដោយបរិក្ខារអគ្គិសនី ក្នុងការដំណើរការធម្មតា ។

## ៤. កំលាំងធន់មេកានិករបស់បរិក្ខារអគ្គិសនីទល់នឹងចរន្តឆ្លងប៉ះ

ហ្សេណេរ៉ាទ័រ ត្រង់ស្វូម៉ាទ័រ កុំប៉ង់សាទ័រថាមពលរ៉េអាក់ទីវ ប្រដាប់បើកបិទ របារតង់ស្យុង និងអ៊ីសូឡាទ័រដែលទ្ររបារតង់ស្យុង ដែលតម្លើងនៅអនុស្ថានីយ និងកន្លែងប្រើប្រាស់អគ្គិសនីតង់ស្យុងមធ្យមនិងខ្ពស់ ត្រូវមានលទ្ធភាពធន់នឹងកំលាំងទង្គិចមេកានិកដែលបង្កឡើងដោយចរន្តឆ្លងប៉ះ ។

## ៥. ការបង្ការការខូចខាតដោយសារធុងមានសម្ពាធ

បរិក្ខារអគ្គិសនីដែលប្រើឧស្ម័នជាអ៊ីសូឡង់ដែលតម្លើងនៅក្នុងអនុស្ថានីយ ស្ថានីយបែងចែក និងកន្លែងប្រើប្រាស់អគ្គិសនីតង់ស្យុងមធ្យម និងខ្ពស់ ត្រូវរៀបចំដូចខាងក្រោម ដើម្បីចៀសវាងនូវមហន្តរាយណាមួយដែលឈានដល់ការខូចខាត :

(ក) សំភារៈនិងរចនាសម្ព័ន្ធនៃផ្នែកទាំងឡាយដែលរងនូវសម្ពាធ ត្រូវមានលទ្ធភាពធន់នឹងសម្ពាធដំណើរការអតិបរមា និងត្រូវធានាសុវត្ថិភាព ផងដែរ

(ខ) ផ្នែកទាំងឡាយដែលរងនូវសម្ពាធត្រូវធន់នឹងច្រេះស៊ី

(គ) ឧស្ម័នអ៊ីសូឡង់ មិនត្រូវជាឧស្ម័នងាយឆេះ ច្រេះស៊ី និងជាឧស្ម័នប្រកបដោយគ្រោះថ្នាក់នោះទេ

(ឃ) ធុងផ្ទុកឧស្ម័នត្រូវធន់នឹងសម្ពាធឧស្ម័នដែលកើនឡើងនៅផ្នែកខាងក្នុងបរិក្ខាអ៊ីសូឡង់ឧស្ម័ន ក្នុងរយៈពេលមានកំហូចយូរ ។

# មាត្រា ១៦.. ឯកសារបច្ចេកទេសរបស់មធ្យោបាយអគ្គិសនី

ដើម្បីធានាការផ្គត់ផ្គង់អគ្គិសនីសំរាប់រយៈពេលវែង មធ្យោបាយអគ្គិសនីនិមួយៗត្រូវតែមានគំនូសប្លង់ចាំបាច់នានា កំណត់ត្រានៃការតម្លើង ក្បួន បច្ចេកទេស សៀវភៅណែនាំ កំណត់ត្រាការដំណើរការ ដែលចាំបាច់ សំរាប់ការងារថែទាំបរិក្ខាអគ្គិសនី ឱ្យបានត្រឹមត្រូវ ។ ឯកសារទាំងនេះ ត្រូវរក្សាទុកឱ្យបានត្រឹមត្រូវ ។

## មាត្រា ១៧.. ប្រព័ន្ធគមនាគមន៍

ដើម្បីធានាការផ្គត់ផ្គង់អគ្គិសនីឱ្យបានប្រសើរ ត្រូវតែមានមធ្យោបាយគមនាគមន៍សមស្របដែលមានប្រព័ន្ធ SCADA និងប្រព័ន្ធគមនាគមន៍សម្លេង សំរាប់ទំនាក់ទំនងក្នុងការងារផ្គត់ផ្គង់ ។

## ១ ប្រព័ន្ធ SCADA

ប្រព័ន្ធ SCADA ត្រូវបានប្រើសម្រាប់ត្រួតពិនិត្យ និងបញ្ជាមធ្យោបាយអគ្គិសនីទាំងឡាយ ដែលរួមមាន RTU, ខ្សែទូរគមនាគមន៍ និងបន្ទប់កុំព្យូទ័រ ។

១.១ RTU នៃប្រព័ន្ធ SCADA ត្រូវតម្លើងនៅក្នុងមធ្យោបាយអគ្គិសនីយ៉ាងណា ដើម្បីអាចត្រួតពិនិត្យមើលសភាពនៃប្រព័ន្ធបណ្តាញជាតិ និងអាចបញ្ជាមធ្យោបាយអគ្គិសនីទាំងឡាយ ពីមជ្ឈមណ្ឌលបែងចែកអគ្គិសនី ។

១.២ ត្រូវតម្លើងប្រព័ន្ធ SCADA ចាំបាច់នៅមជ្ឈមណ្ឌលបែងចែក និងមធ្យោបាយអគ្គិសនី ។

## ២ ខ្សែទូរគមនាគមន៍

ខ្សែទូរគមនាគមន៍ចាំបាច់នៃប្រព័ន្ធ SCADA និងប្រព័ន្ធគមនាគមន៍សម្លេង ត្រូវតម្លើងដូចខាងក្រោម :

### ២.១ ទីកន្លែងតម្លើង

ខ្សែបណ្តាញចាំបាច់នៃប្រព័ន្ធគមនាគមន៍និងប្រព័ន្ធទូរគមនាគមន៍ ត្រូវតម្លើងនៅទីកន្លែងដូចខាងក្រោម :

ក. រវាងមជ្ឈមណ្ឌលជាតិបញ្ជាអគ្គិសនី និងមជ្ឈមណ្ឌលបែងចែកអគ្គិសនី

ខ. រវាងមជ្ឈមណ្ឌលជាតិបញ្ជាអគ្គិសនី និងរោងចក្រអគ្គិសនីសម្រាប់ប្រព័ន្ធជាតិបញ្ជូនអគ្គិសនី

គ. រវាងមជ្ឈមណ្ឌលជាតិបញ្ជាអគ្គិសនី និងមជ្ឈមណ្ឌលបញ្ជាអគ្គិសនីរបស់ប្រទេសជិតខាង នៅពេលដែលប្រព័ន្ធអគ្គិសនី ត្រូវបានតភ្ជាប់ជាមួយប្រទេសជិតខាង ។ ប្រសិនបើមានកិច្ចព្រមព្រៀងណាមួយស្តីពីប្រព័ន្ធនេះជាមួយប្រទេសជិតខាង ការកំណត់នេះអាចមិនអនុវត្តបាន ។




**កំណត់សម្គាល់**

NCC : មជ្ឈមណ្ឌលបញ្ជាជាតិ

⟷ : ខ្សែបណ្ដាញសម្រាប់ប្រព័ន្ធគមនាគមន៍ក្នុងស្រុក

←‑ ‑→ : ខ្សែបណ្ដាញសម្រាប់ប្រព័ន្ធគមនាគមន៍សម្រាប់ប្រទេសជិតខាង

**រូបភាពទី ១ ៖ នៃការតម្លើងប្រព័ន្ធគមនាគមន៍និងទូរគមនាគមន៍**

## ២.២ ប្រភេទខ្សែ និងល័ក្ខខ័ណ្ឌរបស់ខ្សែសម្រាប់ខ្សែទូរគមនាគមន៍ក្នុងស្រុក

- ត្រូវតម្លើងខ្សែទូរគមនាគមន៍យ៉ាងហោចណាស់ ២ ខ្សែខុសគ្នា សម្រាប់ប្រព័ន្ធបណ្ដាញជាតិ
- ខ្សែសម្រាប់ប្រព័ន្ធទូរគមនាគមន៍ក្នុងស្រុកសម្រាប់ប្រព័ន្ធអគ្គិសនី ត្រូវអនុវត្តអនុលោមតាមការកំណត់ក្នុងតារាង ៣ ។

**តារាងទី ៣៖ ប្រភេទខ្សែបណ្តាញគមនាគមន៍និងទូរគមនាគមន៍សម្រាប់មធ្យោបាយអគ្គិសនី ដែលភ្ជាប់ជាមួយប្រព័ន្ធបណ្តាញជាតិ**

| | | រវាងមជ្ឈមណ្ឌលបញ្ជាជាតិនិង មជ្ឈមណ្ឌលបែងចែកអគ្គិសនី | | រវាងមជ្ឈមណ្ឌលបញ្ជាជាតិ និងស្ថានីយ | |
|---|---|---|---|---|---|
| | | ទិន្នន័យ | សម្លេង | ទិន្នន័យ | សម្លេង |
| ប្រភេទ ខ្សែ បណ្តាញ | ខ្សែអុបទិក | ១ ខ្សែ | ១ ខ្សែ | ១ ខ្សែ | ១ ខ្សែ |
| | ខ្សែអុបទិក | ១ ខ្សែ (ជ្រើសរើសក្នុង ចំណោម ៥ ប្រភេទ) | ១ ខ្សែ (ជ្រើសរើស ក្នុងចំណោម ៥ ប្រភេទ) | ១ ខ្សែ (ជ្រើសរើស ក្នុងចំណោម ៥ ប្រភេទ) | ១ ខ្សែ (ជ្រើសរើស ក្នុងចំណោម ៥ ប្រភេទ) |
| | ខ្សែលោហ: | | | | |
| | តាមរលកធាតុអាកាស | | | | |
| | ខ្សែអគ្គិសនី | | | | |
| | រលកសម្លេង | | | | |
| លក្ខខណ្ឌរបស់ខ្សែ | | ខ្សែដែលត្រូវប្រើសម្រាប់ប្រព័ន្ធអគ្គិសនី | | | |

### ៣. វិធានការណ៍ធានាគមនាគមន៍ក្នុងករណីមានអាសន្ន

មធ្យោបាយគមនាគមន៍ដែលចាំបាច់ដើម្បីចាត់ចែងកែលំអប្រព័ន្ធអគ្គិសនីឡើងវិញ នៅពេលមានគ្រោះមហន្តរាយ ចៃដន្យកើតឡើង ត្រូវតែមានស្ថិរភាពគ្រប់គ្រាន់ នៅក្នុងគ្រាមានអាសន្ន ។

## មាត្រា ១៨៖. ភាពត្រឹមត្រូវនៃនាឡិកាស្ទង់អគ្គិសនី

នាឡិកាស្ទង់អគ្គិសនីត្រូវមានភាពត្រឹមត្រូវយុត្តិធម៌និងសមធម៌ ។ ភាពត្រឹមត្រូវនៃនាឡិកាស្ទង់ជាទូទៅត្រូវមាន លក្ខណៈដូចខាងក្រោម :

**តារាងទី៤៖ភាពត្រឹមត្រូវនៃនាឡិកាស្ទង់អេឡិចត្រូមេកានិច និងនាឡិកាស្ទង់អេឡិចត្រូនិច**

| **ប្រភេទអតិថិជន** | **ថ្នាក់***  |
|---|---|
| អតិថិជនតង់ស្យុងខ្ពស់ | ០.៥ |
| អតិថិជនតង់ស្យុងមធ្យម | ១.០ |
| អតិថិជនតង់ស្យុងទាប | ២.០ |

* កំរិតល្អៀងនៃថ្នាក់នីមួយៗត្រូវអនុវត្តតាមស្តង់ដា **IEC**

# ផ្នែកទី២
# ការភ្ជាប់ខ្សែដី

## មាត្រា ១៩.. លក្ខខណ្ឌទូទៅនៃការភ្ជាប់ខ្សែដី

ដើម្បីបង្ការការឆក់អគ្គិសនី គ្រោះថ្នាក់ចំពោះខ្លួនប្រាណមនុស្ស ការកើតមានអគ្គិភ័យ និងកើតមានឧបស័គ្គដទៃទៀតចំពោះវត្ថុនានា បរិក្ខារអគ្គិសនីនីមួយៗ ត្រូវតែមានភ្ជាប់ខ្សែដី ឬមានវិធានការណ៍សមស្របដទៃទៀត ។

ការភ្ជាប់ខ្សែដីសំរាប់បរិក្ខារអគ្គិសនី ត្រូវតម្លើងយ៉ាងណាឱ្យចរន្តអាចរត់ចូលទៅក្នុងដីដោយស្រួលនិងពុំបង្កគ្រោះថ្នាក់ ។

## មាត្រា ២០.. ចំណាត់ថ្នាក់ការភ្ជាប់ខ្សែដី

ការភ្ជាប់ខ្សែដីសម្រាប់បរិក្ខារអគ្គិសនីនៃមធ្យោបាយអគ្គិសនីគ្រប់ប្រភេទ អាចចែកជា ៤ ថ្នាក់ ដូចមានបង្ហាញក្នុងតារាងខាងក្រោម :

**តារាងទី៥..ចំណាត់ថ្នាក់ការងារភ្ជាប់ខ្សែដី**

| ចំណាត់ថ្នាក់ការងារភ្ជាប់ខ្សែដី | តម្លៃរ៉េស៊ីស្តង់ភ្ជាប់ទៅដី | លក្ខខណ្ឌសំរាប់សំរួលតម្លៃរ៉េស៊ីស្តង់ |
|---|---|---|
| ថ្នាក់ **ក** | 10Ω ឬតូចជាង | |
| ថ្នាក់ **ខ** | 10Ω ឬតូចជាង (នៅពេលដែល $\frac{230}{I^{*1}}$ តូចជាង 10, រ៉េស៊ីស្តង់ភ្ជាប់ទៅដី ត្រូវមានតម្លៃស្មើនឹង $\frac{230}{I^{*1}}$ ឬតូចជាងនេះ ) | ក្នុងករណីដែលតង់ស្យុងផៀបទៅដីនៃសៀគ្វីអគ្គិសនីតង់ស្យុងទាបមួយមានតម្លៃលើសពី ២៣០ វ៉ុល ដោយសារការប៉ះរវាងសៀគ្វីតង់ស្យុងមធ្យម និងសៀគ្វីតង់ស្យុងទាបនៃត្រង់ស្វូម៉ាទ័រ, ប្រសិនបើមានតម្លើងឌីស្យុងទ័រច្រាលចរន្តតាមខ្សែដីដែលអាចកាត់ផ្តាច់សៀគ្វីអគ្គិសនីក្នុងរយៈពេលមិនលើសពី១វិនាទី ពេលនោះរ៉េស៊ីស្តង់ត្រូវស្មើនឹង $\frac{600}{I^{*1}}\Omega$ ឬតូចជាង ។ នៅពេលដែល $\frac{230}{I^{*1}}$ មានតម្លៃតូចជាង 5Ω ពេលនោះរ៉េស៊ីស្តង់ខ្សែដី មិនចាំបាច់មានតម្លៃតូចជាង 5Ω ឡើយ ។ |
| ថ្នាក់ **គ** | 10 Ω ឬតូចជាង | ក្នុងករណីត្រូវរៀបចំខ្សែដីក្នុងសៀគ្វីអគ្គិសនីតង់ស្យុងទាប, ហើយក្នុងសៀគ្វីនោះមានតម្លើងឌីសុងទ័រច្រាលចរន្តទៅដីដែលអាចកាត់ផ្តាច់សៀគ្វីអគ្គិសនីក្នុងរយៈពេល ០.៥ វិនាទីពេលនោះតម្លៃរ៉េស៊ីស្តង់ត្រូវស្មើនឹង 500Ω ឬតូចជាង ។ |
| ថ្នាក់ **ឃ** | 100Ω ឬតូចជាង | ក្នុងករណីត្រូវរៀបចំខ្សែដីក្នុងសៀគ្វីអគ្គិសនីតង់ស្យុងទាប,ហើយក្នុងសៀគ្វីនោះមានតម្លើងឌីសុងទ័រច្រាលចរន្តទៅដីដែលអាចកាត់ផ្តាច់សៀគ្វីអគ្គិសនីក្នុងរយៈពេល ០.៥វិនាទី ពេលនោះតម្លៃរ៉េស៊ីស្តង់ត្រូវស្មើនឹង 500Ω ឬតូចជាង ។ |

សំគាល់

*1 I - គឺជាចរន្តនៃការឆ្លងខ្សែមួយប៉ះទៅដី

## មាត្រា ២១. ការភ្ជាប់ខ្សែដីសម្រាប់ខ្សែបណ្តាញអគ្គិសនី

ប្រភេទខ្សែដី កន្លែងដែលត្រូវអនុវត្ត លក្ខខ័ណ្ឌនៃការតម្លើង តម្លៃរ៉េស៊ីស្តង់ភ្ជាប់ទៅដី សម្រាប់ខ្សែបណ្តាញអគ្គិសនី ត្រូវអនុវត្តដូចមានកំណត់ក្នុងតារាងខាងក្រោម :

**តារាងទី៦. ប្រភេទខ្សែដីសម្រាប់ខ្សែបណ្តាញអគ្គិសនី**

<table>
<tr><th>ប្រភេទខ្សែដី</th><th>កន្លែងអនុវត្ត</th><th>លក្ខខ័ណ្ឌតម្លើង</th><th>រ៉េស៊ីស្តង់ភ្ជាប់ទៅដី (Ω)</th></tr>
<tr><td>ខ្សែដីភ្ជាប់ប្រព័ន្ធ</td><td>ត្រង់ស្វូម៉ាទ័រតង់ស្យុងមធ្យម/ទាប</td><td>សំរាប់ខ្សែណឺតតង់ស្យុងទាបនៃប្រភេទខ្សែដី TN និង TT</td><td>តម្លៃរ៉េស៊ីស្តង់ត្រូវកំណត់តាមថ្នាក់ ខ នៃការងារភ្ជាប់ខ្សែដី</td></tr>
<tr><td rowspan="5">ខ្សែដីសុវត្ថិភាព</td><td rowspan="5">ផ្នែកអាចឆ្លងចរន្តដាក់នៅកណ្តាលវាល (*1)</td><td>សំរាប់តង់ស្យុងខ្ពស់ (*2)</td><td rowspan="2">តម្លៃរ៉េស៊ីស្តង់ត្រូវកំណត់តាមថ្នាក់ ក នៃការងារភ្ជាប់ខ្សែដី</td></tr>
<tr><td>សំរាប់តង់ស្យុងមធ្យម</td></tr>
<tr><td>សំរាប់តង់ស្យុងទាប លើសពី ៣០០ វ៉ុល</td><td>តម្លៃរ៉េស៊ីស្តង់ត្រូវកំណត់តាមថ្នាក់ គ នៃការងារភ្ជាប់ខ្សែដី</td></tr>
<tr><td rowspan="2">សំរាប់តង់ស្យុងទាបមិនលើសពី ៣០០ វ៉ុល</td><td rowspan="2">តម្លៃរ៉េស៊ីស្តង់ត្រូវកំណត់តាមថ្នាក់ ឃ នៃការងារភ្ជាប់ខ្សែដី</td></tr>
<tr></tr>
<tr><td>ខ្សែដីច្រាលចរន្ត</td><td>ឧបករណ៍ច្រាលចរន្ត</td><td>សំរាប់តង់ស្យុងមធ្យម</td><td>តម្លៃរ៉េស៊ីស្តង់ត្រូវកំណត់តាមថ្នាក់ ក នៃការងារភ្ជាប់ខ្សែដី</td></tr>
</table>

សំគាល់

(*1) ”ផ្នែកអាចឆ្លងចរន្តដាក់នៅកណ្តាលវាល”សំដៅផ្នែកទាំងឡាយដូចជាជើងទម្រដែក គម្របឬប្រអប់លោហៈស្រោបឧបករណ៍ដែលគេតម្លើងនៅក្នុងសៀគ្វីអគ្គិសនី ។

(*2) ការភ្ជាប់ខ្សែដីសំរាប់អនុស្ថានីយតង់ស្យុងខ្ពស់ និងស្ថានីយបែងចែកអគ្គិសនីត្រូវរៀបចំដោយឡែករៀងខ្លួនអាស្រ័យទៅតាមទំហំនៃចរន្តឆ្លងប៉ះ ។

## មាត្រា ២២. ការភ្ជាប់ខ្សែដីសំរាប់រោងចក្រអគ្គិសនី អនុស្ថានីយ ស្ថានីយបែងចែកនិងទីតាំងរបស់អ្នកប្រើប្រាស់តង់ស្យុងខ្ពស់និងតង់ស្យុងមធ្យម

### ១. ការភ្ជាប់ខ្សែដីសំរាប់បរិក្ខារអគ្គិសនី

#### ១.១ ការភ្ជាប់ខ្សែដីដើម្បីសុវត្ថិភាព

បរិក្ខាអគ្គិសនីដែលត្រូវតម្លើងនៅក្នុងរោងចក្រអគ្គិសនី អនុស្ថានីយ ស្ថានីយបែងចែក និងទីតាំងអ្នកប្រើប្រាស់តង់ស្យុងខ្ពស់និងមធ្យម ត្រូវមានតម្លើងនូវខ្សែដីការពារ ដូចរៀបរាប់ខាងក្រោម ដើម្បីកុំឱ្យមានហានិភ័យនៃកំណើនប៉ូតង់ស្យែលក្នុងល័ក្ខខ័ណ្ឌមិនធម្មតា កុំឱ្យមានគ្រោះថ្នាក់ដល់រាងកាយមនុស្ស និងកុំឱ្យមានការខូចខាតដល់វត្ថុដទៃទៀត ដោយសារការឆក់អគ្គិសនី និងអគ្គីភ័យ បណ្តាលមកពីការជ្រៀតចូលនៃតង់ស្យុងខ្ពស់ ។

### ១.១.១ ការភ្ជាប់ខ្សែដីសម្រាប់ផ្នែកអាចឆ្លងចរន្តដាក់នៅកណ្តាលវាលរបស់បរិក្ខាអគ្គិសនី

ផ្នែកអាចឆ្លងចរន្តដាក់នៅកណ្តាលវាលរបស់បរិក្ខាអគ្គិសនី ដូចជា ជើងទម្រដែក ប្រអប់ស្រោបលោហៈ ត្រូវតែភ្ជាប់ទៅដី ដោយការភ្ជាប់ខ្សែដី ។ ការភ្ជាប់ខ្សែដីសម្រាប់ផ្នែកអាចឆ្លងចរន្តដាក់នៅកណ្តាលវាលរបស់បរិក្ខាអគ្គិសនីដែលមានតង់ស្យុងផ្សេងៗ មានកំណត់នៅក្នុងតារាងខាងក្រោម :

**តារាងទី៧_ការភ្ជាប់ខ្សែដីសម្រាប់ផ្នែកអាចឆ្លងចរន្តដាក់នៅកណ្តាលវាលរបស់បរិក្ខាអគ្គិសនី**

| តង់ស្យុងបរិក្ខាអគ្គិសនី | ប្រភេទខ្សែដី |
|---|---|
| បរិក្ខាអគ្គិសនីតង់ស្យុងខ្ពស់ | ថ្នាក់ **ក** |
| បរិក្ខាអគ្គិសនីតង់ស្យុងមធ្យម | ថ្នាក់ **ក** |
| បរិក្ខាអគ្គិសនីតង់ស្យុងទាប (លើស300V ) | ថ្នាក់ **គ** |
| បរិក្ខាអគ្គិសនីតង់ស្យុងទាប (300V ឬតូចជាង ) | ថ្នាក់ **ឃ** |

### ១.១.២ ការភ្ជាប់ខ្សែដីសម្រាប់មធ្យោបាយផ្សេងទៀត

មធ្យោបាយផ្សេងទៀត ដូចជារចនាសម្ព័ន្ធលោហៈខាងក្រៅ របងលោហៈខាងក្រៅ ជញ្ជាំងការពារលោហៈ និងទម្រលោហៈសម្រាប់ដំណើរការ ក៏ត្រូវភ្ជាប់ខ្សែដីអនុលោមទៅតាមប្រភេទតង់ស្យុងនៃមធ្យោបាយ ឬបរិក្ខាអគ្គិសនីដែលកំណត់ក្នុងតារាងខាងលើ ។

### ១.១.៣ ការភ្ជាប់ខ្សែដីសម្រាប់ផ្នែកអាចឆ្លងចរន្តនៅក្នុងបរិក្ខាអគ្គិសនី

នៅចំណុចចាំបាច់ក្នុងសៀគ្វីអគ្គិសនី ការភ្ជាប់ខ្សែដីត្រូវអនុវត្ត ដូចការកំណត់ខាងក្រោម :

#### ក. ការភ្ជាប់ខ្សែដីសម្រាប់ត្រង់ស្វូម៉ាទ័រដែលប្រើជាបរិធាន (ត្រង់ស្វូម៉ាទ័រចរន្ត ឬតង់ស្យុង)

ការភ្ជាប់ខ្សែដីថ្នាក់ **ក** ត្រូវអនុវត្តនៅត្រង់ចំនុចជ្រើសរើសមួយនៅក្នុងសៀគ្វីអគ្គិសនីផ្នែកទី២ នៃត្រង់ស្វូម៉ាទ័រដែលប្រើជាបរិធានសម្រាប់តង់ស្យុងខ្ពស់ ឬតង់ស្យុងមធ្យម ។

ក្នុងករណីដែលការភ្ជាប់ខ្សែដីត្រូវបានប្រើសម្រាប់សៀគ្វីអគ្គិសនីផ្នែកទី ១ របស់ត្រង់ស្វូម៉ាទ័រដែលប្រើជាបរិធានសម្រាប់តង់ស្យុងខ្ពស់ឬតង់ស្យុងមធ្យម ត្រូវអនុវត្តការភ្ជាប់ខ្សែដីថ្នាក់ **ក** ។

### ខ. ការភ្ជាប់ខ្សែដីសម្រាប់ត្រង់ស្វូម៉ាទ័រផ្គត់ផ្គង់អគ្គិសនីឱ្យស្ថានីយ

ក្នុងករណីការភ្ជាប់ខ្សែដី ត្រូវបានប្រើសម្រាប់សៀគ្វីអគ្គិសនីផ្នែកទី២របស់ត្រង់ស្វូម៉ាទ័រដែលភ្ជាប់សៀគ្វីអគ្គិសនីតង់ស្យុងមធ្យមជាមួយសៀគ្វីអគ្គិសនីតង់ស្យុងទាប ការភ្ជាប់ខ្សែដីថ្នាក់ **ខ** ត្រូវយកមកអនុវត្ត ។

"សៀគ្វីអគ្គិសនីតង់ស្យុទាប" មានន័យថាសៀគ្វីអគ្គិសនីដែលផ្គត់ផ្គង់អគ្គិសនី ទៅឱ្យសៀគ្វីបញ្ជាដោយស្វ័យប្រវត្តិ សៀគ្វីបញ្ជាពីចម្ងាយ សៀគ្វីផ្តល់សញ្ញាសម្រាប់ត្រួតមើលពីចម្ងាយ និងសៀគ្វីដូចគ្នាផ្សេងទៀត ។

### គ. ការភ្ជាប់ខ្សែដីសម្រាប់របុំក្នុងត្រង់ស្វូដែលប្រើសំរាប់តែរក្សាលំនឹងដោយមិនភ្ជាប់ចេញក្រៅ

ក្នុងករណីដែលត្រង់ស្វូម៉ាទ័រតង់ស្យុងខ្ពស់និងតង់ស្យុងមធ្យមដែលមានរបុំភ្ជាប់គ្នាផ្កាយ–ផ្កាយ មានរបុំរក្សាលំនឹងមួយដែលគេរុំថែមដើម្បីបន្ថយអាំប៉េដង់នៃហ្វាសូន្យ ដោយមិនភ្ជាប់ចេញទៅសៀគ្វីក្រៅ (ហៅថា របុំរក្សាលំនឹងនិងមិនភ្ជាប់ចេញក្រៅ) របុំនេះត្រូវតែភ្ជាប់ទៅដីដោយការភ្ជាប់ខ្សែដីថ្នាក់ **ក** ។

## ១.២ ការភ្ជាប់ខ្សែដីសម្រាប់ចំណុចណឺតនៅក្នុងសៀគ្វីអគ្គិសនីតង់ស្យុងខ្ពស់ និងតង់ស្យុងមធ្យម

ក្នុងករណីដែលការភ្ជាប់ខ្សែដីត្រូវប្រើសម្រាប់ចំណុចណឺតនៃសៀគ្វីអគ្គិសនីតង់ស្យុងខ្ពស់ និងមធ្យមនៅក្នុងស្ថានីយអនុស្ថានីយ ស្ថានីយបែងចែក និងទីតាំងអ្នកប្រើប្រាស់តង់ស្យុងខ្ពស់ និងមធ្យម ដើម្បីធានាការដំណើរការមួយដ៏ទុកចិត្ត ដើម្បីទប់ទល់ករណីតង់ស្យុងមិនប្រក្រតី និងដើម្បីបន្ថយតង់ស្យុងធៀបទៅដីសម្រាប់ឧបករណ៍ការពារនៃសៀគ្វីអគ្គិសនី ត្រូវតម្លើងអេឡិចត្រូដខ្សែដីនៅនឹងកន្លែង ដើម្បីបង្ការនូវការប្រឈមមុខនឹងគ្រោះថ្នាក់ដល់មនុស្ស សត្វពាហន: និងបរិក្ខាដទៃទៀត ដែលអាចកើតឡើងដោយសារភាពខុសគ្នានៃប៉ូតង់ស្យែលរវាងចំណុចនោះជាមួយដីដែលនៅក្បែរ នៅពេលដែលមានកំហូចណាមួយកើតឡើង ។

## ១.៣ ការភ្ជាប់ខ្សែដីសម្រាប់បរិក្ខារអគ្គិសនីរបស់ប្រព័ន្ធខ្សែមួយចរន្តត្រឡប់មកវិញតាមដី SWER

ក្នុងករណីដែលបរិក្ខាអគ្គិសនីសម្រាប់ប្រព័ន្ធ SWER ត្រូវបានតម្លើងនៅក្នុងរោងចក្រអគ្គិសនី និងអនុស្ថានីយបរិក្ខាសម្រាប់ប្រព័ន្ធ SWER ទាំងនោះត្រូវតែមានភ្ជាប់ខ្សែដី ដើម្បីបង្ការនូវការប្រឈមមុខនឹងគ្រោះថ្នាក់ដល់មនុស្ស

សត្វពាហន: និងបរិក្ខាដទៃទៀត ដែលអាចមានដាយសារភាពខុសគ្នានៃប៉ូតង់ស្យែលរវាងបរិក្ខាអគ្គិសនីនោះជាមួយដីដែលនៅក្បែរ កើតឡើងដោយចរន្តនៃបន្ទុកកើនឡើង នៅពេលមានកំហូចណាមួយកើតឡើង ។

### ១.៤ ការភ្ជាប់ខ្សែដីសម្រាប់ឧបករណ៍ការពាររន្ទះ

រេស៊ីស្តង់នៃការភ្ជាប់ខ្សែដីសម្រាប់ឧបករណ៍ការពាររន្ទះ: ដូចជាខ្សែដីការពាររន្ទះដែលរាយពីលើ និងបង្គោលការពាររន្ទះ ដែលត្រូវតម្លើងនៅក្នុងស្ថានីយ អនុស្ថានីយ ស្ថានីយបែងចែក និងទីតាំងអ្នកប្រើប្រាស់តង់ស្យុងខ្ពស់ និងមធ្យម មិនត្រូវធំជាង (១០) អូមឡើយ ។

ទោះជាយ៉ាងនេះក៏ដោយ ក្នុងករណីដែលខ្សែដីរាយលើអាកាសត្រូវបាន ប្រើសម្រាប់ប្រព័ន្ធ SWER ដែរនោះការភ្ជាប់ខ្សែដីត្រូវអនុវត្តតាមការភ្ជាប់ខ្សែដីសម្រាប់ប្រព័ន្ធ SWER ដែលអធិប្បាយខាងលើ ។

### ១.៥ ការភ្ជាប់ខ្សែដីសម្រាប់ឧបករណ៍ចាប់ចរន្តច្រាល

រេស៊ីស្តង់នៃការភ្ជាប់ខ្សែដីសម្រាប់ឧបករណ៍ចាប់ចរន្តច្រាល សម្រាប់សៀគ្វីអគ្គិសនីតង់ស្យុងខ្ពស់ និងតង់ស្យុងមធ្យម ក្នុងស្ថានីយ អនុស្ថានីយ ស្ថានីយបែងចែក និងទីតាំងអ្នកប្រើប្រាស់តង់ស្យុងខ្ពស់ និងមធ្យម ត្រូវធ្វើយ៉ាងណាឱ្យតិចជាង (១០) អូម ច្រើនតាមដែលអាចធ្វើទៅបាន ដើម្បីបង្កាកុំឱ្យទៅជាឧបស័គ្គសម្រាប់ការដំណើរការរបស់ឧបករណ៍ចាប់ចរន្តច្រាល ។

## ២ លក្ខណៈពិសេសនៃការរៀបចំការភ្ជាប់ខ្សែដី

### ២.១ លក្ខណៈនៃខ្សែចម្លងរបស់ខ្សែដី

ខ្សែចម្លងរបស់ខ្សែដីដែលតម្លើងក្នុងសៀគ្វីអគ្គិសនីនៅក្នុងស្ថានីយ អនុស្ថានីយ ស្ថានីយបែងចែក និងទីតាំងអ្នកប្រើប្រាស់តង់ស្យុងខ្ពស់ និងមធ្យមត្រូវធ្វើពីខ្សែលោហៈដែលធន់នឹងច្រេះឬស្នឹម និងអាចចម្លងចរន្ត ប្រកបដោយសុវត្ថិភាព នៅពេលមានកំហូច ។

#### ក. កម្លាំងមេកានិករបស់ខ្សែចម្លងរបស់ខ្សែដី

ដើម្បីធានានូវកម្លាំងមេកានិកគ្រប់គ្រាន់ ត្រូវប្រើប្រាស់ខ្សែចម្លងនៃប្រព័ន្ធខ្សែដី តាមការកំណត់នៅក្នុងតារាងខាងក្រោម អនុលោមទៅតាមប្រភេទនៃការភ្ជាប់ខ្សែដី ដែលខ្សែចម្លងនោះត្រូវបានប្រើប្រាស់ ។

## តារាងទី៨ ខ្សែចម្លងដែលត្រូវប្រើសម្រាប់ការងារភ្ជាប់ខ្សែដី

| ប្រភេទខ្សែដី / ប្រភេទការងារភ្ជាប់ខ្សែដី | | ខ្សែលោហៈ | ខ្សែទង់ដែង | ខ្សែទង់ដែងសសៃច្រើន |
|---|---|---|---|---|
| | | កម្លាំងទប់ទំនាញ | អង្កត់ផ្ចិត | មុខកាត់ |
| ថ្នាក់ **ក** | ខ្សែដីសម្រាប់ចំណុចណឺតនៃសៀគ្វីអគ្គិសនីតង់ស្យុងខ្ពស់និង មធ្យមនៅក្នុងហ្វេរណេរ៉ទ័រ និងត្រង់ស្វូម៉ាទ័រ | មិនតូចជាង 3 kN | មិនតូចជាង 4 mm | មិនតូចជាង 14 $mm^2$ |
| | សម្រាប់បរិក្ខាផ្សេងទៀត | មិនតូចជាង 2 kN | មិនតូចជាង 3 mm | មិនតូចជាង 6 $mm^2$ |
| ថ្នាក់ **ខ** | ចំណុចណឺតនៃផ្នែកតង់ស្យុងទាបរបស់ត្រង់ស្វូម៉ាទ័របំប្លែងតង់ស្យុងមធ្យមទៅតង់ស្យុងទាប | មិនតូចជាង 2 kN | មិនតូចជាង 3 mm | មិនតូចជាង 6 $mm^2$ |
| ថ្នាក់ **គ** | | មិនតូចជាង 1 kN | មិនតូចជាង 2 mm | មិនតូចជាង 4 $mm^2$ |
| ថ្នាក់ **ឃ** | | មិនតូចជាង 1 kN | មិនតូចជាង 2 mm | មិនតូចជាង 4 $mm^2$ |

### ១. សមត្ថភាពទល់នឹងកំដៅនៃខ្សែចម្លងរបស់ខ្សែដី

ខ្សែចម្លងរបស់ខ្សែដីដែលក្នុងនោះនឹងមានចរន្តរត់កាត់ នៅពេលដែលល័ក្ខខ័ណ្ឌមិនធម្មតាកើតឡើង ដូចជា ខ្សែណឺតនៃបរិក្ខាអគ្គិសនី និងខ្សែណឺតនៃសៀគ្វីអគ្គិសនីតង់ស្យុងខ្ពស់និងមធ្យម ត្រូវមានសមត្ថភាពគ្រប់គ្រាន់ទល់នឹងកំដៅដែលកើតឡើងដោយចរន្តរត់ទៅដី នៅពេលមានល័ក្ខខ័ណ្ឌមិនប្រក្រតី ឬមានកំហូចកើតឡើងបន្ថែមពីលើកម្លាំងមេកានិច ។

## ២.២ ការតម្លើងខ្សែចម្លងរបស់ខ្សែដី

ខ្សែចម្លងរបស់ខ្សែដីសម្រាប់ "ត្រង់ស្វូម៉ាទ័រដែលប្រើជាបរិធាន " សម្រាប់ខ្សែណឺត សម្រាប់ឧបករណ៍ចាប់ចរន្តច្រាល និងសម្រាប់ប្រព័ន្ធ SWER ដែលត្រូវតម្លើងនៅក្នុងស្ថានីយ អនុស្ថានីយ ស្ថានីយបែងចែក និង

ទីតាំងអ្នកប្រើប្រាស់តង់ស្យុងខ្ពស់ និងមធ្យម ត្រូវកប់ដោយផ្ទាល់ទៅក្នុងដីដោយពុំតភ្ជាប់ទៅជើងទំររបស់បរិក្ខាអគ្គិសនី ។ ផ្នែកស្រោតនៃខ្សែដី ត្រូវតម្លើងយ៉ាងណាកុំឱ្យមានហានិភ័យដល់អ្នកដំណើរការ ដែលអាចងាយស្រួលក្នុងការប៉ះវាឡើយ ។

### ២.៣ ឧបករណ៍ខ្សែដីសម្រាប់ខ្សែណឺត

រ៉េស៊ីស្ទ័រនិងរ៉េអាក់ទ័រដែលត្រូវតភ្ជាប់ជាមួយខ្សែចម្លងរបស់ខ្សែដី នៅក្នុងស្ថានីយ អនុស្ថានីយ ស្ថានីយបែងចែក និងទីតាំងអ្នកប្រើប្រាស់តង់ស្យុងខ្ពស់និងមធ្យមត្រូវសមស្របនិងសុវត្ថិភាពចំពោះលំហូរនៃចរន្តអគ្គិសនី ដែលកើតឡើងនៅពេលមានកំហូចណាមួយកើតឡើង ។

ផ្នែកស្រោតនៃរ៉េស៊ីស្ទ័រនិងរ៉េអាក់ទ័រ ត្រូវតម្លើងយ៉ាងណាកុំឱ្យមាន ហានិភ័យដល់អ្នកដំណើរការ ដែលអាចងាយស្រួលក្នុងការប៉ះវា ។

### ២.៤ ការហាមឃាត់មិនឱ្យតម្លើងប្រដាប់បើកបិទលើខ្សែចម្លងរបស់ខ្សែដីសម្រាប់ខ្សែណឺត

មិនត្រូវតម្លើងប្រដាប់បើកបិទនិងហ្វុយស៊ីបលើខ្សែចម្លងរបស់ខ្សែដីសម្រាប់ខ្សែណឺត នៅក្នុងស្ថានីយ អនុស្ថានីយ ស្ថានីយបែងចែក និងទីតាំងអ្នកប្រើប្រាស់តង់ស្យុងខ្ពស់និងមធ្យមឡើយ លើកលែងតែប្រដាប់បើកបិទ ដែលត្រូវតម្លើងដើម្បី ផ្តាច់ឬភ្ជាប់រ៉េស៊ីស្ទ័រនិងរ៉េអាក់ទ័រសម្រាប់ខ្សែណឺត ។

### ២.៥ ការតភ្ជាប់រវាងខ្សែចម្លងរបស់ខ្សែដី

ខ្សែចម្លងរបស់ខ្សែដីនៃប្រព័ន្ធចរន្តត្រឡប់តាមដី SWER ដែលត្រូវតម្លើងនៅក្នុងរោងចក្រអគ្គិសនី និងអនុស្ថានីយ មិនត្រូវ ភ្ជាប់ទៅខ្សែចម្លងនៃប្រព័ន្ធខ្សែដីរបស់បរិក្ខាអគ្គិសនីដទៃទៀតឡើយ ។

## មាត្រា ២៣.. ការភ្ជាប់ខ្សែដីសម្រាប់ខ្សែបណ្តាញចែកចាយ និងទីតាំងរបស់អ្នកប្រើប្រាស់តង់ស្យុងទាប

### ១. លក្ខណៈពិសេសនៃការភ្ជាប់ខ្សែដី

ការភ្ជាប់ខ្សែដីសម្រាប់ខ្សែបណ្តាញចែកចាយនិងសម្រាប់ទីតាំងរបស់អ្នកប្រើប្រាស់តង់ស្យុងទាប ត្រូវតម្លើងតាមការកំណត់ ដូចខាងក្រោម :

## ១.១ អេឡិចត្រូដខ្សែដី

១.១.១ វត្ថុធាតុ និងទំហំនៃអេឡិចត្រូដខ្សែដី ត្រូវជ្រើសរើសយ៉ាងណាឱ្យធន់នឹងច្រេះស៊ី និងមានកម្លាំងមេកានិចរឹងមាំ ។

១.១.២ ខាងក្រោមនេះជាឧទាហរណ៍នៃអេឡិចត្រូដរបស់ខ្សែដី ដែលអាចប្រើបាន :

ក. បន្ទះលោហៈ

ខ. បង្គោល ឬបំពង់លោហៈ

គ. សន្លឹកឬខ្សែលោហៈ

ឃ. បណ្តាញគ្រឹះក្រោមដីនៃអគារ

ង. គ្រោងលោហៈក្រោមដីផ្សេងទៀតដែលសមស្រប និងយល់ព្រមដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## ១.២ ខ្សែចម្លងរបស់ខ្សែដី និងខ្សែចម្លងសម្រាប់ការពារ

ខ្សែចម្លងសម្រាប់ការពារនៅក្នុងការកំណត់នេះ គឺជាខ្សែចម្លងទាំងឡាយណាដែលគេប្រើសម្រាប់តភ្ជាប់បរិក្ខាអគ្គិសនី ជាមួយប្រព័ន្ធខ្សែដី ។

ក. ខ្សែចម្លងរបស់ខ្សែដី និងខ្សែម្លងសម្រាប់ការពារ ត្រូវតែជាខ្សែលោហៈដែលធន់នឹងច្រេះស៊ី និងអាចឱ្យចរន្តឆ្លងកាត់បានដោយសុវត្ថិភាពនៅពេលមានកំហូច ។

ខ. ខ្សែចម្លងដែលត្រូវប្រើសម្រាប់ធ្វើខ្សែដី ត្រូវអនុលោមតាមការកំណត់នៃវាក្យខ័ណ្ឌ គ និងនៅពេលកប់ក្នុងដីត្រូវមានមុខកាត់ ស្របទៅតាមស្របតាមតារាងទី ៩-ក ខាងក្រោម ។

**តារាងទី ៩-ក មុខកាត់អប្បបរមានៃខ្សែដីដែលកប់ដី**

| លក្ខខ័ណ្ឌ | មានការការពារមេកានិក | មិនមានការការពារមេកានិក |
|---|---|---|
| មានការការពារទល់នឹងច្រេះស៊ី | ២.៥ មម² Cu (ទង់ដែង)<br>១០ មម² Fe (ដែក) | ១៦ មម² Cu (ទង់ដែង)<br>១៦ មម² Fe (ដែក) |
| មិនមានការការពារទល់នឹងច្រេះស៊ី | ២៥ មម² Cu (ទង់ដែង)៥០ មម² Fe (ដែក) | |

គ. មុខកាត់របស់ខ្សែសម្រាប់ការពារ ត្រូវជ្រើសរើសតាមតារាងទី ៩-ខ ឬតាមចំណុច ឃ ។

## តារាងទី ៩.ខ មុខកាត់អប្បបរមានៃខ្សែចម្លងសម្រាប់ការពារ

| មុខកាត់ ខ្សែចម្លង S (មម$^{២}$) | មុខកាត់អប្បបរមានៃខ្សែចម្លងសម្រាប់ការពារ ( មម$^{២}$ ) | |
|---|---|---|
| | ប្រសិនបើខ្សែចម្លងសម្រាប់ការពារគឺជា វត្ថុធាតុដូចខ្សែចម្លងនៃបណ្តាញអគ្គិសនី | ប្រសិនបើខ្សែចម្លងសម្រាប់ការពារមិនមែនជាវត្ថុធាតុដូចខ្សែចម្លងនៃបណ្តាញ |
| $S \le 16$ | S | $k \times S$ |
| $16 < S \le 35$ | 16 | $k \times 16$ |
| $S > 35$ | S/2 | $k \times S/2$ |

*k ត្រូវជ្រើសរើសពីតារាងទី ៩-គ

## តារាងទី ៩.គ (មេគុណ k សម្រាប់តារាងទី ៩.ខ)

| វត្ថុធាតុរបស់ខ្សែចម្លង | អ៊ីសូឡង់របស់ខ្សែចម្លង | វត្ថុធាតុរបស់ខ្សែចម្លងសម្រាប់ការពារ | | | | | |
|---|---|---|---|---|---|---|---|
| | | អាលុយមីញ៉ូម | | ទង់ដែង | | ដែក | |
| | | PVC | ជ័រ | PVC | ជ័រ | PVC | ជ័រ |
| អាលុយមីញ៉ូម | PVC <300 mm2 | - | - | 0.58 | 0.48 | 1.56 | 1.32 |
| | PVC >300mm2 | - | - | 0.52 | 0.43 | 1.39 | 1.18 |
| | EPR/ XLPE | - | - | 0.71 | 0.60 | 1.92 | 1.92 |
| ទង់ដែង | PVC <300mm2 | 1.31 | 0.73 | - | - | 2.45 | 1.99 |
| | PVC >300mm2 | 1.18 | 0.65 | - | - | 2.11 | 1.78 |
| | EPR/ XLPE | 1.63 | 0.90 | - | - | 2.92 | 2.47 |

* សម្គាល់ : មេគុណ k ដែលកំណត់នៅទីនេះសម្រាប់ប្រើចំពោះតែខ្សែចម្លងសម្រាប់ការពារដែលមានស្រោមអ៊ីសូឡង់ប៉ុណ្ណោះ មិនសម្រាប់ខ្សែកាប និងខ្សែកាបជាចង្កោមដទៃទៀតឡើយ ។ ក្នុងករណីខ្សែចម្លងសម្រាប់ការពារដទៃទៀត មេគុណត្រូវយកតាមស្តង់ដា **IEC** ៦០៣៦៤-៥-៥៤ ។

ឃ. មុខកាត់នៃខ្សែចម្លងសម្រាប់ការពារគ្រប់ប្រភេទ ដែលមិនមែនជាផ្នែកនៃខ្សែកាប ឬមិននៅក្នុងប្រអប់ជាមួយខ្សែបណ្តាញ មិនត្រូវតូចជាងទំហំដែលកំណត់នៅក្នុងតារាង ៩-ឃ ឡើយ ។

## តារាង ៩-ឃ មុខកាត់របស់ខ្សែចម្លងសម្រាប់ការពារ
**(IEC60364-5-54)**

| មានការការពារមេកានិក | គ្មានការការពារមេកានិក |
|---|---|
| ២,៥ មម² ទង់ដែង<br>១៦ មម² អាលុយមីញ៉ូម | ៤ មម² ទង់ដែង<br>១៦ មម² អាលុយមីញ៉ូម |

### ១.៣ ការតម្លើងអេឡិចត្រូដនិងខ្សែចម្លងរបស់ប្រព័ន្ធខ្សែដី

ក្នុងករណីអាចមានគ្រោះថ្នាក់នៅពេលមនុស្សទៅប៉ះខ្សែចម្លង របស់ប្រព័ន្ធខ្សែដីនេះ អេឡិចត្រូដ និងខ្សែចម្លងរបស់ខ្សែដី ថ្នាក់ **ក** និង ថ្នាក់ **ខ** ត្រូវតម្លើងតាមការកំណត់ខាងក្រោម ៖

ក. អេឡិចត្រូដរបស់ខ្សែដីត្រូវកប់ទៅក្នុងដី ជម្រៅមិនតិចជាង ៧៥ សង់ទីម៉ែត្រ ។

ខ. ខ្សែចម្លងរបស់ប្រព័ន្ធខ្សែដី ត្រូវស្រោបដោយបំពង់ទីបជ័រ ឬដោយរបាំងការពារផ្សេងទៀតដែលមានគុណភាពអ៊ីសូឡង់ និងភាពធន់ប្រហាក់ប្រហែលឬខ្ពស់ជាងបំពង់ទីប ហើយដាក់ចាប់ពីជម្រៅ ៧៥ សង់ទីម៉ែត្រក្រោមដី ដល់កម្ពស់ ២ម លើដី ។

គ. ប្រសិនបើអេឡិចត្រូដនៃខ្សែដី តម្លើងជិតបង្គោលដែក ឬវត្ថុ លោហៈផ្សេងទៀត ខ្សែចម្លងរបស់ប្រព័ន្ធខ្សែដីត្រូវជាខ្សែ ស្រោមទាំងអស់ ។

ឃ. ប្រសិនបើអេឡិចត្រូដនៃខ្សែដីតម្លើងជិតបង្គោលដែកឬវត្ថុលោហៈផ្សេងទៀត អេឡិចត្រូដខ្សែដីត្រូវកប់នៅចម្ងាយមិនតិចជាង ១ ម៉ែត្រ ពីវត្ថុលោហៈទាំងនោះ ។

ដោយឡែក ចម្ងាយនេះអាចមិនតិចជាង ៣០ សង់ទីម៉ែត្រ ប្រសិនបើការតម្លើងអេឡិចត្រូដខ្សែដីស្ថិតនៅពីក្រោមគ្រឹះនៃវត្ថុនោះ ។

## ២. រ៉េស៊ីស្តង់នៃការភ្ជាប់ខ្សែដីថ្នាក់ ខ

ចរន្តឆ្លងនៃខ្សែមួយប៉ះដី ( I ) នៃសៀគ្វីអគ្គិសនីផ្នែកតង់ស្យុងមធ្យម ដែលប្រើសម្រាប់គណនារេស៊ីស្តង់នៃខ្សែដីថ្នាក់ ខ ចែងក្នុងមាត្រា ២០ នៃល័ក្ខខ័ណ្ឌលំអិតនេះ ត្រូវយកតាមតម្លៃជាក់ស្តែង ឬតាមតម្លៃដូចខាងក្រោម ៖

### ២.១ សៀគ្វីអគ្គិសនីតង់ស្យុងមធ្យមរបស់ប្រព័ន្ធពុំមានខ្សែណឺត

រ៉េស៊ីស្តង់ខ្សែដីថ្នាក់ ខ សម្រាប់ប្រព័ន្ធពុំមានខ្សែណឺត ត្រូវកំណត់ដូចខាងក្រោម ៖

ក. សៀគ្វីអគ្គិសនីដែលប្រើខ្សែចម្លងអគ្គិសនីក្រៅពីខ្សែកាប

សម្រាប់សៀគ្វីអគ្គិសនីដែលប្រើខ្សែចម្លងក្រៅពីខ្សែកាប រ៉េស៊ីស្តង់ខ្សែដីថ្នាក់ ខ ត្រូវមានតម្លៃស្មើ ១០ អូម ឬ តូចជាង ។

ខ. សៀគ្វីអគ្គិសនីដែលប្រើខ្សែកាបជាខ្សែចម្លងអគ្គិសនី

សម្រាប់សៀគ្វីអគ្គិសនីដែលប្រើខ្សែកាបជាខ្សែចម្លងអគ្គិសនី រ៉េស៊ីស្តង់ខ្សែដីថ្នាក់ ខ ត្រូវមានតម្លៃដូចក្នុងតារាង ៩-ង និងតារាង ៩-ច អាស្រ័យទៅតាមចម្ងាយសរុបនៃសៀគ្វីតង់ស្យុងមធ្យម ( គិតតែចម្ងាយដែលប្រើខ្សែកាបជាខ្សែចម្លងអគ្គិសនីប៉ុណ្ណោះ ) ដែលភ្ជាប់នឹងរបារដូចគ្នា ។

### តារាង ៩-ង ក្នុងករណីដែលរ៉េស៊ីស្តង់ខ្សែដីថ្នាក់ B កំណត់ដោយ ២៣០/ I

| L, (ប្រវែង) | <៣ គ.ម | ៣ គ.ម ≤ |
|---|---|---|
| រ៉េស៊ីស្តង់ដី ថ្នាក់ ខ (អូម) | ១០ | ៥ |

### តារាង ៩-ច ក្នុងករណីដែលរ៉េស៊ីស្តង់ខ្សែដីថ្នាក់ B កំណត់ដោយ ៦០០/ I*

| L, (ប្រវែង) | <៤,៥ គ.ម | ៤,៥ គ.ម ≤ |
|---|---|---|
| រ៉េស៊ីស្តង់ដី ថ្នាក់ ខ (អូម) | ១០ | ៥ |

* ក្នុងករណីមានឧបករណ៍ការពារចរន្តជ្រាបទៅដី ដែលផ្តាច់សៀគ្វី អគ្គិសនី ក្នុងរយៈពេល ១ វិនាទី ។

ក្នុងនោះ :

L: ប្រវែងសរុបនៃសៀគ្វីតង់ស្យុងមធ្យម ( គិតតែចម្ងាយដែលប្រើខ្សែកាបជាខ្សែចម្លងអគ្គិសនីប៉ុណ្ណោះ ) ដែលបានភ្ជាប់នឹងរបារដូចគ្នា ។

គ. សៀគ្វីអគ្គិសនីដែលប្រើខ្សែចម្លងផ្សេងពីខ្សែកាបផង និងខ្សែកាបផង ជាខ្សែចម្លងអគ្គិសនី

ក្នុងករណីនេះរ៉េស៊ីស្តង់ខ្សែដីថ្នាក់ ខ ត្រូវកំណត់តាមតារាង ៩ ង និង ៩ ច ទៅតាមប្រវែងសរុបនៃសៀគ្វីតង់ស្យុងមធ្យម ( គិតតែចម្ងាយដែលប្រើខ្សែកាបជាខ្សែចម្លងអគ្គិសនីប៉ុណ្ណោះ ) ដែលបានភ្ជាប់ នឹងរបារដូចគ្នា ។

## ២.២ សៀគ្វីអគ្គិសនីតង់ស្យុងមធ្យមដែលមានប្រព័ន្ធខ្សែណឺតភ្ជាប់ផ្ទាល់ជាមួយដី

ចរន្តនៃខ្សែមួយឆ្លងប៉ះដី ( $I_២$ ) នៃសៀគ្វីអគ្គិសនី ផ្នែកខាងតង់ស្យុងមធ្យម ដែលប្រើសម្រាប់គណនារ៉េស៊ីស្តង់នៃការភ្ជាប់ខ្សែដីថ្នាក់ ខ ចែងក្នុងមាត្រា ២០ នៃល័ក្ខខ័ណ្ឌលំអិតនេះ ត្រូវយកតាមតម្លៃជាក់ស្តែង ឬគណនាតាមរូបមន្តដូចខាងក្រោម :

$$I_{២} = \sqrt{I_{១}^{2} + \frac{V^{2}}{3R^{2}} \times 10^{6}}$$

* ចំនួនក្រោយក្បៀសតូចជាងចំណុចទសភាគ ត្រូវស ម្រួលឱ្យដល់លេខគត់

ក្នុងនោះ :

$I_{២}$: ចរន្តនៃខ្សែមួយឆ្លងប៉ះដី (អាំពែរ)

$I_{១}$: ចរន្តនៃខ្សែមួយឆ្លងប៉ះដី ក្នុងករណី ប្រព័ន្ធមិនមានខ្សែណឺតភ្ជាប់ជាមួយ ដីដែលគេអាចគណនាតាមរូបមន្ត ក្នុង ទ្រឹស្តី ( អាំពែរ )

V : តង់ស្យុងណូមីណាល់នៃសៀគ្វីអគ្គិសនី (គីឡូវ៉ុល)

R : តម្លៃរ៉េស៊ីស្តង់នៃរ៉េស៊ីស្តង់ដែលបាន ប្រើនៅចំណុចណឺត (រួមបញ្ចូលតម្លៃរ៉េស៊ីស្តង់ដីនៃចំណុចណឺត), (អូម)

## ៣. ប្រព័ន្ធខ្សែដីសម្រាប់ខ្សែបណ្តាញតង់ស្យុងទាប

ប្រព័ន្ធខ្សែដីស ម្រាប់ខ្សែបណ្តាញតង់ស្យុងទាប មាន ២ ប្រភេទ គឺ TT និង TN ។ ការងារភ្ជាប់ខ្សែដីនេះ ត្រូវគោរពតាមស្តង់ដា IEC 60364-1 ។

ក. ប្រព័ន្ធខ្សែដី ប្រភេទ TT ត្រូវមានចំណុចមួយភ្ជាប់ទៅដីដោយផ្ទាល់ និងផ្នែកអាចឆ្លងចរន្តដាក់នៅកណ្តាល វាល ត្រូវភ្ជាប់ទៅនឹងអេឡិច ត្រូដខ្សែដីដាច់ដោយឡែក ដោយមិនជាប់ទៅនឹងអេឡិច ត្រូដខ្សែដីរបស់ ប្រព័ន្ធ បណ្តាញឡើយ ។

ខ. ប្រព័ន្ធខ្សែដី ប្រភេទ TN ត្រូវមានចំណុចមួយ ត្រូវភ្ជាប់ទៅដីដោយផ្ទាល់ និងផ្នែកអាចឆ្លងចរន្តដាក់នៅ កណ្តាលវាល ត្រូវភ្ជាប់ទៅនឹងចំណុចនោះដោយខ្សែស ម្រាប់ការពារ ។ ការភ្ជាប់ខ្សែដីតាម ប្រព័ន្ធ TN មានពីរ ប្រភេទអាស្រ័យលើការរៀបចំខ្សែណឺតនិង ខ្សែស ម្រាប់ការពារដូចខាងក្រោម :

- ប្រព័ន្ធខ្សែដី ប្រភេទ TN-S : ក្នុង ប្រព័ន្ធនេះទាំងមូលគេ ត្រូវ ប្រើខ្សែស ម្រាប់ការពារដាច់ពីគ្នាដោយឡែក
- ប្រព័ន្ធខ្សែដី ប្រភេទ TN-C : ក្នុង ប្រព័ន្ធនេះតួនាទីរបស់ខ្សែណឺតនិងខ្សែស ម្រាប់ការពារគឺរួមគ្នា ។

គ. បរិក្ខារអគ្គិសនីតង់ស្យុងទាបដែល ត្រូវតម្លើងនៅទីតាំងរបស់អ្នក ប្រើ ប្រាស់ ត្រូវតម្លើង ស្របតាមស្តង់ដា IEC 60364 ។ ប្រសិនបើ បរិក្ខារអគ្គិសនីនេះភ្ជាប់ដោយផ្ទាល់នឹង ប្រព័ន្ធបណ្តាញរបស់អ្នកផ្គត់ផ្គង់ ប្រព័ន្ធខ្សែដី ត្រូវ ដូចគ្នានឹង ប្រព័ន្ធខ្សែដីរបស់អ្នកផ្គត់ផ្គង់ដែលតម្លើងស ម្រាប់ផ្នែកតង់ស្យុងទាប ។
បរិក្ខារអគ្គិសនីតង់ស្យុងទាបមិន ត្រូវតម្លើងតាមរបៀបមួយដែល ប្រព័ន្ធខ្សែដីមានលក្ខណៈខុសគ្នារវាង ប្រព័ន្ធខ្សែដីដែលតម្លើងនៅទីតាំងរបស់អ្នកផ្គត់ផ្គង់ និងទីតាំងរបស់អ្នក ប្រើ ប្រាស់ឡើយ ។

**សញ្ញាសម្គាល់ :**

- ខ្សែណឺត (N)
- ខ្សែការពារ (PE)
- ខ្សែរួមណឺត-ម៉ាស់ (PEN)







**រូបភាពទី ២ ~ ប្រព័ន្ធខ្សែដី TT**




**រូបភាពទី ៣ ~ ប្រព័ន្ធខ្សែដី TN-S**







**រូបភាពទី ៤ ~ ប្រព័ន្ធខ្សែដី TN-C**

## ផ្នែកទី៣
## ខ្សែចម្លង

## មាត្រា ២៤. ខ្សែចម្លងសម្រាប់មធ្យោបាយបញ្ជូននិងចែកចាយ

### ១ . បញ្ញត្តិទូទៅ

ខ្សែចម្លងសម្រាប់មធ្យោបាយបញ្ជូននិងចែកចាយអគ្គិសនីគឺត្រូវជាខ្សែកាប ខ្សែស្រោម ឬខ្សែស្រាត ។ មិនអនុញ្ញាតឱ្យប្រើខ្សែស្រាត សំរាប់ខ្សែបណ្តាញតង់ស្យុងទាបឡើយ ។

ខ្សែកាបនិងខ្សែស្រោមត្រូវមានសមត្ថភាពអ៊ីសូឡង់គ្រប់គ្រាន់ សមស្របទៅតាមល័ក្ខខ័ណ្ឌតង់ស្យុងដែលប្រើប្រាស់វា ។

### ២ . លក្ខណៈរបស់ខ្សែចម្លង

២.១ - ខ្សែចម្លងត្រូវតែធន់ទៅនឹងស៊ីតុណ្ហភាពដែលប្រើប្រាស់ធម្មតា ។

២.២ - រចនាសម្ព័ន្ធរបស់ខ្សែចម្លង

ក-ខ្សែស្រោម

រចនាសម្ព័ន្ធរបស់ខ្សែស្រោមត្រូវតែជាខ្សែចម្លងអគ្គិសនីដែល ស្រោបដោយវត្ថុធាតុអ៊ីសូឡង់ ។

ខ-ខ្សែកាបដែលប្រើសម្រាប់បណ្តាញតង់ស្យុងទាប

រចនាសម្ព័ន្ធរបស់ខ្សែកាបនេះ ត្រូវតែជាខ្សែចម្លងអគ្គិសនីស្រោបដោយអ៊ីសូឡង់ដែលការពារដោយស្រទាប់ដែក ។

គ.-ខ្សែកាបដែលត្រូវប្រើសម្រាប់បណ្តាញតង់ស្យុងមធ្យម

រចនាសម្ព័ន្ធរបស់ខ្សែកាបនេះត្រូវតែជាខ្សែចម្លងអគ្គិសនីស្រោបដោយអ៊ីសូឡង់ ដែលការពារដោយស្រទាប់ដែក និងដែលមានស្រទាប់បាំងការពារអគ្គិសនីធ្វើពីលោហៈស្រោបពីលើបណ្តូលខ្សែកាបនោះ ចំពោះខ្សែកាបដែលមានបណ្តូលមួយ និងស្រោបពីលើបណ្តូលទាំងអស់ដែលរមួលជាមួយគ្នា ឬស្រោបពីលើបណ្តូលនីមួយៗ ចំពោះខ្សែកាបដែលមានបណ្តូលច្រើន ។

២.៣ –ខ្សែចម្លងដែលជាផលិតផលសម្រេច អាចយកមកប្រើជាខ្សែបណ្ដាញបញ្ជូន ឬខ្សែបណ្ដាញចែកចាយ បាន លុះត្រាតែបានឆ្លងកាត់ការធ្វើតេស្តតង់ស្យុងចរន្តឆ្លាស់សមស្របមួយ ។

២.៤ – កម្លាំងទប់ទំនាញក្នុងមួយឯកតាផ្ទៃ (មេហ្កាប៉ាស្កាល់) នៃសសៃខ្សែអាលុយមីញ៉ូមដែលគេប្រើសម្រាប់ វេញជាខ្សែចម្លងនៃបណ្ដាញអាកាស ត្រូវតែមានតម្លៃមិនទាបជាងតម្លៃកំណត់ក្នុងតារាងទី ១០ ដែល អនុលោមតាមស្តង់ដា IEC ដែលពាក់ព័ន្ធ ។

**តារាងទី ១០ ៖ កម្លាំងទប់ទំនាញនៃសសៃខ្សែអាលុយមីញ៉ូម**

**(IEC ៦០៨៨៩)**

| អង្កត់ផ្ចិតណូមីណាល់ | | កម្លាំងទប់ទំនាញអប្បបរមា (មេហ្កាប៉ាស្កាល់) |
|---|---|---|
| លើសពី (មម) | រហូតដល់ (មម) | |
| – | ១,២៥ | ២០០ |
| ១,២៥ | ១,៥០ | ១៩៥ |
| ១,៥០ | ១,៧៥ | ១៩០ |
| ១,៧៥ | ២,០០ | ១៨៥ |
| ២,០០ | ២,២៥ | ១៨០ |
| ២,២៥ | ២,៥០ | ១៧៥ |
| ២,៥០ | ៣,០០ | ១៧០ |
| ៣,០០ | ៣,៥០ | ១៦៥ |
| ៣,៥០ | ៥,០០ | ១៦០ |

## មាត្រា ២៥៖. ការតភ្ជាប់ខ្សែចម្លង

ខ្សែចម្លងត្រូវតភ្ជាប់គ្នាតាមវិធីដូចខាងក្រោម ៖

ក. ខ្សែចម្លងត្រូវតភ្ជាប់គ្នាឱ្យបានជាប់ណែនល្អ ហើយរ៉េស៊ីស្តង់របស់ខ្សែចម្លងដែលតរួចមិនត្រូវកើនឡើងលើសពី រ៉េស៊ីស្តង់របស់ខ្សែចម្លងដែលពុំមានការតភ្ជាប់ឡើយ ។

ខ. ត្រូវធ្វើយ៉ាងណាមិនឱ្យសមត្ថភាពអ៊ីសូឡង់របស់ខ្សែកាប និងខ្សែស្រោមបន្ទាប់ពីតរួច ថយចុះទាបជាងសមត្ថភាព អ៊ីសូឡង់នៃខ្សែដែលពុំទាន់មានការតភ្ជាប់ឡើយ ។

គ. ក្នុងការតភ្ជាប់ខ្សែចម្លងដែលផលិតពីវត្ថុធាតុខុសគ្នា ត្រូវធ្វើយ៉ាងណាមិនឱ្យកើតមានច្រេះអេឡិចត្រូគីមីឡើយ ។

# មាត្រា ២៦_. មេគុណសុវត្ថិភាពរបស់ខ្សែស្រាត និងខ្សែដី នៃបណ្តាញអាកាស

## ១_ បញ្ញត្តិទូទៅ

ចំពោះកំលាំងទប់ទំនាញនៃខ្សែចម្លងនិងខ្សែដីសំរាប់បណ្តាញអាកាស លើកលែងតែខ្សែកាបចេញ មេគុណសុវត្ថិភាពមិនត្រូវទាបជាង ២.៥ ទេ ។

## ២_. បន្ទុកលើបណ្តាញបញ្ជូនអាកាស និងមេគុណសុវត្ថិភាព

### ២.១- បន្ទុកសន្មត់ និងមេគុណសុវត្ថិភាព

ខ្សែចម្លងសម្រាប់បណ្តាញបញ្ជូនអាកាស និងខ្សែដីតម្លើងលើអាកាស (លើកលែងតែខ្សែកាប ចំពោះមាត្រានេះចាប់ពីនេះតទៅ) ត្រូវតម្លើងយ៉ាងណាឱ្យមានកម្លាំងទាញដែលអនុញ្ញាតឱ្យមេគុណសុវត្ថិភាពមានកំរិត ដូចដែលកំណត់ក្នុងចំណុច ២.១.២ នៅពេលដែលវារងនូវបន្ទុកសន្មត់ដូចដែលមានកំណត់នៅចំណុច ២.១.១ ខាងក្រោម នៅក្នុងល័ក្ខខ័ណ្ឌសីតុណ្ហភាពមធ្យមក្នុងតំបន់ ។

### ២.១.១- បន្ទុកសន្មត់

បន្ទុកសន្មត់សំរាប់ការគណនាកម្លាំងទប់ទំនាញ នៃខ្សែចម្លងរបស់បណ្តាញបញ្ជូនអាកាស និងខ្សែដីតម្លើងលើអាកាស ត្រូវតែជាបន្ទុកដែលជាផលបូកនៃបន្ទុកបញ្ឈរដែលមានបញ្ជាក់ក្នុងចំណុច(ក) និងបន្ទុកផ្តេក ដែលមានបញ្ជាក់ក្នុងចំណុច (ខ) ខាងក្រោម :

ក. បន្ទុកបញ្ឈរត្រូវជាទំងន់របស់ខ្សែចម្លងអគ្គិសនី

ខ. បន្ទុកផ្តេកត្រូវជាបន្ទុកផ្តេកនៃសម្ពាធខ្យល់អតិបរិមាលើផ្ទៃបញ្ឈរ របស់ខ្សែចម្លង ។

### ២.១.២- មេគុណសុវត្ថិភាព

កម្លាំងទប់ទំនាញ (កម្លាំងទប់ទំនាញខ្ពស់បំផុត, កំលាំងទាញផ្តាច់) នៃខ្សែចម្លងរបស់បណ្តាញបញ្ជូនអាកាស និងខ្សែដីតម្លើលើអាកាសត្រូវមានមេគុណសុវត្ថិភាព ២,៥ ឬច្រើនជាង ។

### ២.១.៣- ល្បឿនខ្យល់ជាមូលដ្ឋាន

ល្បឿនខ្យល់ជាមូលដ្ឋាន សម្រាប់ការគ្រោងរៀបចំបណ្តាញអាកាសតង់ស្យុងខ្ពស់ ត្រូវដូចការកំណត់ក្នុងតារាង ១០ ។

**តារាងទី ១១ ~ ល្បឿនខ្យល់ជាមូលដ្ឋាន**

| | |
|---|---|
| ល្បឿនខ្យល់ប្រចាំឆ្នាំអតិបរិមា គិតជាមធ្យមសម្រាប់១០នាទី (ក្នុងរយៈពេលខួប ៥០ ឆ្នាំ) | 32 m/sec |

នៅក្នុងល័ក្ខខ័ណ្ឌខាងក្រោមនេះ ល្បឿនខ្យល់ជាមូលដ្ឋានខាងលើ អាចត្រូវផ្លាស់ប្តូរ :

ក - នៅពេលទិន្នន័យអង្កេតគ្រប់គ្រាន់ត្រូវបានប្រមូលរួច

ខ - នៅពេលត្រូវការឱ្យមានកំរិតស្ថិរភាពខ្ពស់ជាង

គ - នៅពេលដែលគម្រោងចាំបាច់ត្រូវសមស្របជាមួយគម្រោង របស់ប្រទេសជិតខាង




**រូបភាពទី ៥ ~ បន្ទុកសន្ធត់**

## មាត្រា ២៧.. ការប្រើប្រាស់ក្បែរគ្នា និងការប្រើប្រាស់រួមគ្នា នៃបណ្តាញអគ្គិសនីឬបណ្តាញគមនាគមន៍

### ១. បណ្តាញតង់ស្យុងខ្ពស់ បណ្តាញតង់ស្យុងមធ្យម និងបណ្តាញតង់ស្យុងទាប

ការប្រើប្រាស់ក្បែរគ្នា និងការប្រើប្រាស់រួមគ្នា នៃបណ្តាញអគ្គិសនី ត្រូវអនុវត្តតាមវិធីដូចខាងក្រោម :

#### ១.១- បណ្តាញតង់ស្យុងខ្ពស់និងបណ្តាញតង់ស្យុងមធ្យម

ក- នៅពេលដែលបណ្តាញតង់ស្យុងខ្ពស់ និងបណ្តាញតង់ស្យុងមធ្យមត្រូវតម្លើងនៅលើបង្គោលទ្រជាមួយគ្នា ពេលនោះ បណ្តាញតង់ស្យុងមធ្យមត្រូវតម្លើងនៅក្រោមបណ្តាញតង់ស្យុងខ្ពស់ និងនៅលើដៃទ្រផ្សេងគ្នា ។

ខ- គម្លាតរវាងបណ្តាញអាកាសតង់ស្យុងខ្ពស់ និងបណ្តាញអាកាសតង់ស្យុងមធ្យមមិនត្រូវមានតម្លៃតូចជាងតម្លៃដែលបានកំណត់ក្នុងមាត្រា ៣៦ នៃល័ក្ខខ័ណ្ឌលំអិតនៃស្តង់ដាបច្ចេកទេសអគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជានេះឡើយ ទោះជានៅត្រង់ចំណុចណាមួយក្នុងចន្លោះបង្គោលក៏ដោយ ។

គ- ខ្សែចម្លងរបស់បណ្តាញអាកាសតង់ស្យុងខ្ពស់ត្រូវតែជាខ្សែ ដែលមានសសៃវេញចូលគ្នា ដែលមានកម្លាំងទប់ទំនាញយ៉ាងតិច ៣០ គីឡូញូតុន លើកលែងតែវាជាខ្សែកាប ។

ឃ- តង់ស្យុងណូមីណាល់របស់បណ្តាញតង់ស្យុងខ្ពស់ ដែលប្រើប្រាស់ ក្បែរគ្នា ឬរួមគ្នា មិនត្រូវលើសពី ១១៥ គីឡូវ៉ុលឡើយ ។

#### ១.២- បណ្តាញតង់ស្យុងមធ្យម និងបណ្តាញតង់ស្យុងទាប

១.២.១- នៅពេលដែលបណ្តាញតង់ស្យុងមធ្យមនិងបណ្តាញតង់ស្យុងទាប ត្រូវតម្លើងនៅលើបង្គោលទ្រជាមួយគ្នា ពេលនោះ បណ្តាញតង់ស្យុងទាប ត្រូវតម្លើងនៅក្រោមបណ្តាញតង់ស្យុងមធ្យម និងនៅលើដៃទ្រផ្សេងពីគ្នា ។

១.២.២- ខ្សែចម្លងនៃបណ្តាញតង់ស្យុងទាបត្រូវតែអនុលោមតាមបញ្ញត្តិខាងក្រោម លើកលែងតែក្នុងករណីដែលខ្សែកាបត្រូវបានប្រើប្រាស់ :

ក - ក្នុងករណីដែលចន្លោះបង្គោលនៃបណ្តាញតង់ស្យុងទាប មានប្រវែងខ្លីជាង ៥០ ម៉ែត្រ ពេលនោះ កម្លាំងទប់ទំនាញ មិនត្រូវតូចជាង ៥ គីឡូញូតុន ឡើយ ។

ខ – ក្នុងករណីដែលចន្លោះបង្គោលនៃបណ្តាញតង់ស្យុងទាប មានប្រវែង ៥០ ម៉ែត្រ ឬវែងជាង ពេលនោះកម្លាំងទប់ទំនាញ មិនត្រូវតូចជាង ៨ គីឡូញូតុន ឡើយ ។

១.២.៣– ផ្នែកនៃបណ្តាញតង់ស្យុងទាបណាដែលបានតម្លើងនៅលើបង្គោលទ្រតែមួយរបស់បណ្តាញអាកាសតង់ស្យុងខ្ពស់ ត្រូវតែភ្ជាប់ខ្សែដីថ្នាក់ **ខ** ហើយរ៉េស៊ីស្តង់របស់វាមិនត្រូវច្រើនជាង ១០ អូម ឡើយ ។

១.២.៤– គម្លាតរវាងខ្សែចម្លងនៃបណ្តាញអាកាសតង់ស្យុងមធ្យម និងខ្សែចម្លងនៃបណ្តាញអាកាសតង់ស្យុងទាបណាមួយ ត្រង់ចំណុចណាមួយនៅក្នុងចន្លោះបង្គោល ទោះជាក្នុងស្ថានភាពណាក៏ដោយ មិនត្រូវតូចជាងតម្លៃដែលកំណត់នៅក្នុងមាត្រា ៤៧ នៃល័ក្ខខ័ណ្ឌលំអិតនេះឡើយ ។

## ១.៣– បណ្តាញតង់ស្យុងខ្ពស់ និងបណ្តាញតង់ស្យុងទាប

១.៣.១– មិនត្រូវតម្លើងបណ្តាញតង់ស្យុងទាបណាមួយនៅលើបង្គោលទ្រតែមួយជាមួយខ្សែបណ្តាញតង់ស្យុងខ្ពស់ឡើយ ។

១.៣.២– ករណីលើកលែងនៃការប្រើប្រាស់ក្បែរគ្នារបស់បណ្តាញតង់ស្យុងខ្ពស់និងបណ្តាញតង់ស្យុងទាប
ការប្រើប្រាស់ក្បែរគ្នានៃបណ្តាញតង់ស្យុងខ្ពស់និងបណ្តាញតង់ស្យុងទាប ត្រូវបានអនុញ្ញាតតែក្នុងករណីបានចាត់នូវវិធានការណ៍ ដូចខាងក្រោម ដើម្បីបង្កើនភាពរឹងមាំរបស់មធ្យោបាយ ។

(១) ខ្សែចម្លងនៃបណ្តាញតង់ស្យុងទាបត្រូវតែអនុលោមតាមបញ្ញត្តិខាងក្រោម លើកលែងតែក្នុងករណីប្រើខ្សែកាប :

ក – ក្នុងករណីដែលចន្លោះបង្គោលនៃបណ្តាញតង់ស្យុងទាប មានប្រវែងខ្លីជាង ៥០ ម៉ែត្រ ពេលនោះកម្លាំងទប់ទំនាញមិនត្រូវតូចជាង ៥ គីឡូញូតុន ឡើយ ។

ខ – ក្នុងករណីដែលចន្លោះបង្គោលនៃបណ្តាញតង់ស្យុងទាប មានប្រវែង ៥០ ម៉ែត្រ ឬវែងជាង ពេលនោះកម្លាំងទប់ ទំនាញ មិនត្រូវតូចជាង ៨ គីឡូញូតុន ឡើយ ។

(២) ផ្នែកនៃបណ្តាញតង់ស្យុងទាបណាដែលបានតម្លើងនៅលើបង្គោលទ្រ តែមួយរបស់បណ្តាញអាកាសតង់ស្យុងខ្ពស់ ត្រូវតែភ្ជាប់ខ្សែដីថ្នាក់ **ខ** ហើយរ៉េស៊ីស្តង់របស់វាមិនត្រូវច្រើន ជាង ១០ អូម ឡើយ ។

(៣) គម្លាតរវាងខ្សែចម្លងរបស់បណ្តាញអាកាសតង់ស្យុងខ្ពស់ និងខ្សែចម្លងរបស់បណ្តាញអាកាសតង់ស្យុងទាប ត្រង់ចំណុចណាមួយ នៅក្នុងចន្លោះបង្គោល ទោះជាក្នុងស្ថានភាពណាក៏ដោយ មិនត្រូវតូចជាង ៤.៥ ម៉ែត្រ ឡើយ ។

(៤) ខ្សែចម្លងរបស់បណ្តាញអាកាសតង់ស្យុងខ្ពស់ត្រូវតែជាខ្សែសសៃវេញចូលគ្នា ដែលមានកម្លាំងទប់ទំនាញយ៉ាងតិច ៣០ គីឡូញូតុន លើកលែងតែវាជាខ្សែកាប ។

(៥) តង់ស្យុងណូមីណាល់របស់បណ្តាញតង់ស្យុងខ្ពស់ មិនត្រូវលើសពី ១១៥ គីឡូវ៉ុលឡើយ ។ ក្នុងករណីបណ្តាញតង់ស្យុងខ្ពស់មាន ២សៀគ្វី ត្រូវអនុវត្តនូវវិធីរៀបចំហ្វាផ្ទុយគ្នា ។

(៦) ចម្ងាយនៃការនៅក្បែរគ្នារវាងបណ្តាញតង់ស្យុងខ្ពស់ និងបណ្តាញ តង់ស្យុងទាប ត្រូវធ្វើការសម្រេចដោយយកចិត្តទុកដាក់អំពីតង់ ស្យុង អាំងឌុចស្យុង។

(៧) ការលើកលែងអាចត្រូវបានអនុញ្ញាត ក្នុងស្ថានភាពដែលមិនអាច ចៀសវាងបាន ដូចខាងក្រោម:

ក. ពុំមានទីកន្លែងសមស្របសម្រាប់តម្លើងបណ្តាញតង់ស្យុងទាបនៅក្នុងតំបន់ទីក្រុង ពីព្រោះមានផ្ទះនៅជាប់ៗគ្នា ហើយមានគន្លងសមស្របតែមួយគឺតាមបណ្តោយផ្លូវសម្រាប់បណ្តាញតង់ស្យុងទាប ប៉ុន្តែបណ្តាញបញ្ជូនតង់ស្យុងខ្ពស់ត្រូវបានតម្លើងនៅទីនោះរួចហើយ ។

ខ. ក្នុងស្ថានភាពផ្សេងទៀតដែលមានការយល់ព្រមពីអាជ្ញាធរអគ្គិសនីកម្ពុជា ។

## ២. ខ្សែបណ្តាញអគ្គិសនី និងខ្សែបណ្តាញគមនាគមន៍

ការប្រើប្រាស់ក្បែរគ្នានិងរួមគ្នានៃបណ្តាញអគ្គិសនី និងបណ្តាញគមនាគមន៍ ត្រូវអនុវត្តតាមវិធីដូចខាងក្រោម ។ ក្នុងករណីបណ្តាញគមនាគមន៍ជាខ្សែកាបអុបទិច ហើយដាក់ចូលជាមួយខ្សែបណ្តាញអគ្គិសនី ឬខ្សែដី វិធីខាងក្រោមនេះមិនចាំបាច់អនុវត្តឡើយ ។

ក- នៅពេលបណ្តាញតង់ស្យុងមធ្យម ឬតង់ស្យុងទាប និងបណ្តាញគមនាគមន៍ ត្រូវតម្លើងលើបង្គោលទ្រជាមួយគ្នា ពេលនោះបណ្តាញតង់ស្យុងមធ្យម ឬបណ្តាញតង់ស្យុងទាប ត្រូវតែតម្លើងពីលើបណ្តាញគមនាគមន៍ និងត្រូវតម្លើងលើដៃទ្រផ្សេងគ្នា ។

ខ- មិនត្រូវតម្លើងបណ្តាញគមនាគមន៍នៅលើបង្គោលទ្រ ជាមួយ នឹងបណ្តាញតង់ស្យុងខ្ពស់ឡើយ ។

# មាត្រា ២៨. បណ្តាញក្រោមដី

## ១. ខ្សែចម្លងរបស់បណ្តាញក្រោមដី

ត្រូវប្រើខ្សែកាបសម្រាប់បណ្តាញអគ្គិសនីក្រោមដី ។

## ២. ការតម្លើងក្នុងបំពង់ និងក្នុងប្រព័ន្ធលូទឹក

ក- ក្នុងករណីដែលបណ្តាញក្រោមដីត្រូវតម្លើងក្នុងបំពង់ បំពង់ទីបសំរាប់ការអូសខ្សែកាបក្នុងបំពង់ត្រូវតែមានភាពមាំគ្រប់គ្រាន់ដើម្បីទប់ទល់នឹងសម្ពាធកិនពីលើនៃយានជំនិះ និងវត្ថុធ្ងន់ៗដទៃទៀត ។

ខ- ក្នុងករណីដែលភាពមាំរបស់បំពង់ទីបមិនអាចទុកចិត្តបាន បណ្តាញក្រោមដីត្រូវតម្លើងក្នុងជំរៅមិនឱ្យតិចជាង ១,២ម៉ែត្រឡើយ ដើម្បីបង្ការនូវគ្រោះថ្នាក់បណ្តាលមកពីសម្ពាធកិនពីលើនៃយានជំនិះ និងវត្ថុធ្ងន់ៗដទៃទៀត។

គ- ក្នុងករណីដែលបណ្តាញក្រោមដីត្រូវតម្លើងក្នុងប្រព័ន្ធលូទឹកដូចបង្ហាញក្នុងរូបភាពទី ៦ ខ លូទឹកដែលសម្រាប់ដាក់ខ្សែកាបនោះត្រូវតែធន់នឹងសម្ពាធកិនពីលើនៃយានជំនិះនិងវត្ថុធ្ងន់ៗដទៃទៀត ។




**រូបភាពទី ៦ ក ៖ ឧទាហរណ៍នៃការតម្លើងបណ្តាញក្រោមដីដាក់ក្នុងបំពង់**




**រូបភាពទី ៦ ខ ៖ ឧទាហរណ៍នៃការតម្លើងបណ្តាញក្រោមដីនៅក្នុងប្រព័ន្ធលូទឹក**

## ៣. ការកប់ក្នុងដីផ្ទាល់

៣.១- ក្នុងករណីដែលបណ្តាញក្រោមដីត្រូវតម្លើងដោយកប់ក្នុងដីផ្ទាល់ ពេលនោះបណ្តាញនោះត្រូវតម្លើងតាមវិធីដូចខាងក្រោម ។

ក- ត្រូវដាក់បន្ទះការពារសមស្របពីលើបណ្តាញក្រោមដី ឬអនុវត្តវិធានការណ៍សមស្របដទៃទៀត ដើម្បីការពារបណ្តាញក្រោមដីទល់នឹងការប៉ះទង្គិចមេកានិចទាំងឡាយ ។

ខ- នៅកន្លែងដែលអាចមានគ្រោះថ្នាក់ដល់ខ្សែកាបដោយសម្ពាធកិនពីលើនៃយានជំនិះនិងវត្ថុធ្ងន់ៗដទៃទៀត បណ្តាញក្រោមដី ត្រូវតម្លើងនៅជំរៅមួយដែលមិនរាក់ជាង ១.២ ម៉ែត្រ ដោយឡែក "ទីកន្លែងផ្សេងទៀត" បណ្តាញក្រោមដីត្រូវតម្លើងនៅជំរៅ មួយដែលមិនរាក់ជាង ០.៦ ម៉ែត្រ ។

៣.២- ជម្រៅរបស់បណ្តាញក្រោមដីទាំងឡាយ ដែលបានរៀបរាប់ក្នុងចំណុច ៣.១.ខ ខាងលើនេះ មានន័យថាជាជម្រៅនៃបណ្តាញទាំងនេះ វាស់ពីបន្ទះការពារខ្សែកាប ។

៣.៣- ទីកន្លែងដូចខាងក្រោមត្រូវរាប់បញ្ចូលទៅក្នុង "ទីកន្លែងផ្សេងទៀត" នៃចំណុច ៣.១.ខ ខាងលើ ។

ក- ចិញ្ចើមផ្លូវ

ខ- ផ្លូវដែលគ្មានរថយន្តឆ្លងកាត់




ឥដ្ឋ, បន្ទះផ្តល់សញ្ញាធ្វើពីប្លាស្ទិច ។ល។




រូបទី ៦ គ ៑ ពន្យល់អំពីជម្រៅដែលត្រូវកប់កាបក្នុងដីផ្ទាល់

**តារាងទី ១២ ក ៑ ជម្រៅនៃការកប់កាបក្នុងដីផ្ទាល់**

| | |
|---|---|
| ទីកន្លែងដែលមានគ្រោះថ្នាក់ដោយទទួលរងនូវកម្លាំងសង្កត់របស់យានជំនិះ និងវត្ថុផ្សេងៗ | D = ១,២ម ឬធំជាង |
| ទីកន្លែងដទៃទៀត | D = ០,៦ម ឬធំជាង |

## ៤៑ គម្លាតរវាងខ្សែកាបមួយទៅខ្សែកាបមួយទៀតចំពោះបណ្តាញដែលមានខ្សែកាបក្រោមដីច្រើន

៤.១- គម្លាតអប្បបរិមារវាងខ្សែកាបក្រោមដីថ្មីមួយជាមួយបណ្តាញអគ្គិសនីដទៃទៀត ត្រូវកំណត់ ដូចតារាងខាងក្រោម :

### តារាងទី ១២ ខ ៊ គម្លាតរវាងខ្សែកាបក្រោមដីមួយនៅខ្សែកាបក្រោមដីមួយទៀតចំពោះបណ្តាញដែលមានខ្សែកាបក្រោមដីច្រើន

(ឯកតា: ម)

| បណ្តាញថ្មី | បណ្តាញអគ្គិសនីផ្សេងទៀត | | |
|---|---|---|---|
| | តង់ស្យុងទាប | តង់ស្យុងមធ្យម | តង់ស្យុងខ្ពស់ |
| តង់ស្យុងទាប | ០,១៥ | ០,៣ | ០,៣ |
| តង់ស្យុងមធ្យម | ០,៣ | ០,៣ | ០,៣ |
| តង់ស្យុងខ្ពស់ | ០,៣ | ០,៣ | ០,៣ |

៤.២ ក្នុងករណីដែលបណ្តាញអគ្គិសនីមួយនៃបណ្តាញអគ្គិសនីពីរ តម្លើងនៅក្នុងបំពង់រឹងមិនឆេះ មិនទាមទារឱ្យមានគម្លាតអប្បបរមាឡើយ ។

## ៥៊ គម្លាតរវាងបណ្តាញកាបក្រោមដីជាមួយវត្ថុដទៃទៀត

ក- គម្លាតអប្បបរមារវាងបណ្តាញកាបក្រោមដីមួយ ជាមួយមធ្យោបាយដទៃទៀត ត្រូវមានតម្លៃដូចក្នុងតារាងខាងក្រោម :

### តារាងទី ១២ គ ៊ គម្លាតរវាងបណ្តាញកាបក្រោមដីជាមួយវត្ថុដទៃទៀត

(ឯកតា ម៉ែត្រ)

| ខ្សែកាបថ្មី | វត្ថុដទៃទៀត | | | |
|---|---|---|---|---|
| | គមនាគមន៍ | ហ្គាស | ទឹក | លូទឹក |
| តង់ស្យុងទាប | * (០,១)<br>០,៣ | មិនត្រូវឱ្យមានការប៉ះផ្ទាល់ | | |
| តង់ស្យុងមធ្យម | *០,១<br>០,៦ | ១,០ | ០,៣ | ០,៣ |
| តង់ស្យុងខ្ពស់ | ០,៦ | ១,០ | ០,៣ | ០,៣ |

* ចាំបាច់ត្រូវមានការយល់ព្រមពីម្ចាស់បណ្តាញគមនាគមន៍

ខ- ក្នុងករណីបណ្តាញអគ្គិសនីតម្លើងក្នុងបំពង់ទីបរឹងមិនឆេះ ហើយបំពង់ទីបនោះមិនប៉ះផ្ទាល់ជាមួយវត្ថុដទៃទៀត មិនទាមទារឱ្យមានគម្លាត អប្បបរមាឡើយ ។

គ- ក្នុងករណីបណ្តាញគមនាគមន៍ជាខ្សែរុំបញ្ចូលជាមួយខ្សែអគ្គិសនី មិនទាមទារឱ្យមានគម្លាតអប្បបរមាឡើយ ។

## ៦. ការតភ្ជាប់ខ្សែកាបក្រោមដី

ការតភ្ជាប់ខ្សែកាបក្រោមដី ត្រូវតែអនុវត្តតាមវិធីដូចខាងក្រោម បន្ថែមពីលើមាត្រា ២៥ នៃ លលសប នេះ ។

ក- សម្ភារៈសម្រាប់ធ្វើការតភ្ជាប់ ត្រូវតែអាចធន់នឹងកម្លាំងពីខាង ក្រៅដែលនឹងអាចកើនឡើង នៅក្នុងល័ក្ខខ័ណ្ឌដែលបានគិត ទុកជាមុនបាន ។

ខ- ខ្សែកាបដែលបានតភ្ជាប់រួចត្រូវតែមានល័ក្ខខ័ណ្ឌល្អ ដែលអាចឱ្យចរន្តឆ្លងកាត់បាន ដូចខ្សែកាបដើម ដែលពុំទាន់ត ។

គ- ខ្សែកាបដែលបានតភ្ជាប់រួច ត្រូវមានលក្ខណៈមិនជ្រាបទឹក ដូចខ្សែកាបដែលពុំទាន់ត ។

## ៧. រចនាសម្ព័ន្ធនៃប្រអប់តំណរកាបក្រោមដី

ក្នុងករណីត្រូវតម្លើងប្រអប់តំណរកាបក្រោមដី ប្រអប់តំណរត្រូវមានរចនាសម្ព័ន្ធ ដូចខាងក្រោម :

ក- ប្រអប់តំណរកាបក្រោមដី ត្រូវតែអាចធន់នឹងកម្លាំងសង្កត់នៃ យានជំនិះ និងវត្ថុធ្ងន់ដទៃទៀត ។

ខ- នៅពេលដែលក្នុងលទ្ធភាពខ្លះ ឧស្ម័នដែលអាចផ្ទុះឬឆេះអាចមាននៅក្នុងប្រអប់នោះ ហើយទំហំរបស់ប្រអប់ គឺ ១ម៣ ឬធំជាង ត្រូវតែតម្លើងកង្ហារសម្រាប់បឺតឧស្ម័ននេះចេញ ។

គ- គម្របប្រអប់តំណរកាបក្រោមដីត្រូវតម្លើងយ៉ាងណា ដែលជនទី៣ មិនអាចបើកវាចេញដោយស្រួល ។

## ៨. ការភ្ជាប់ខ្សែដីសម្រាប់មធ្យោបាយនៅក្រោមដី

ខ្សែដីការពារសុវត្ថិភាពថ្នាក់ **ឃ** ត្រូវតម្លើងភ្ជាប់ទៅនឹងផ្នែកលោហធាតុ នៃមធ្យោបាយនោះ ដូចជាបំពង់ទីបលូទឹក និងប្រអប់តំណរ និងបន្ទះដែកការពារកាប ។

# ជំពូក ៣

# មធ្យោបាយបញ្ជូន

# តង់ស្យុងខ្ពស់

## មាត្រា ២៩. ឧបករណ៍ការពារសម្រាប់បរិក្ខារអគ្គិសនី

### ១. វិធានការណ៍សម្រាប់ការពារខ្សែចម្លងនិងបរិក្ខារអគ្គិសនីឆលងនឹងចរន្តលើស

នៅចំណុចចាំបាច់ទាំងឡាយក្នុងសៀគ្វីអគ្គិសនី ត្រូវតម្លើងឌីសុងទ័រការពារចរន្តលើសដែលការពារខ្សែចម្លង និង បរិក្ខារអគ្គិសនី កុំឱ្យមានការខូចខាតដោយការឡើងកំដៅហួសពីព្រោះមានចរន្តលើស និងការបង្ការកុំឱ្យកើតមានអគ្គីភ័យ ។

### ២.ប្រដាប់ការពារនិងផ្តល់សញ្ញាសម្រាប់ត្រង់ស្វូម៉ាទ័រ និងបរិក្ខាផលិតអនុភាពអសកម្ម(កុងដង់សាទ័រ)

ត្រង់ស្វូម៉ាទ័រ និងបរិក្ខាផលិតអនុភាពអសកម្ម ដែលតម្លើងនៅក្នុងស្ថានីយ និងទីតាំងអ្នកប្រើប្រាស់តង់ស្យុងខ្ពស់ និងមធ្យម ត្រូវបំពាក់នូវឧបករណ៍ស្វ័យប្រវត្តិ សំរាប់កាត់ផ្តាច់ត្រង់ស្វូម៉ាទ័រនិងបរិក្ខាផលិតអនុភាពអសកម្ម ពីសៀគ្វីអគ្គិសនី ក្នុងល័ក្ខខ័ណ្ឌមិនប្រក្រតីដែលអាចបង្កគ្រោះថ្នាក់និងការរំខានដ៏ធ្ងន់ធ្ងរដល់ការផ្គត់ផ្គង់អគ្គិសនី បន្ថែមពីលើប្រព័ន្ធការពារដ៏សមស្របដទៃទៀត ដូចមានបង្ហាញនៅក្នុងតារាង “១៣” ។

**តារាងទី ១៣ ៖ ប្រព័ន្ធការពារសំរាប់ត្រង់ស្វូម៉ាទ័រនិងបរិក្ខាផលិតអនុភាពអសកម្ម**

| ចំណាត់ថ្នាក់ | | ភាពមិនប្រក្រតី | ប្រដាប់ការពារនិងផ្តល់សញ្ញា | |
|---|---|---|---|---|
| | | | ប្រដាប់កាត់ផ្តាច់ស្វ័យប្រវត្តិ | ប្រដាប់ផ្តល់សញ្ញា |
| ត្រង់ស្វ័រម៉ាទ័រមេ | ត្រង់ស្វ័រម៉ាទ័រធម្មតា | ចរន្តលើស | ○ | --- |
| | | ការឆ្លងខាងក្នុង | ○ | --- |
| | | ការកើនសីតុណ្ហភាព | --- | ○ |
| | ត្រង់ស្វូម៉ាទ័រដែលមានប្រព័ន្ធធ្វើឱ្យត្រជាក់ (ប្រព័ន្ធធ្វើឱ្យត្រជាក់ដែលក្នុងនោះសារធាតុត្រជាក់ត្រូវធ្វើឱ្យត្រជាក់របុំនិងស្នូលដែករបស់ត្រង់ស្វូម៉ាទ័រផ្ទាល់តែម្តង ហើយសារធាតុនះមានកម្លាំងជំរុញឱ្យវិល) | នៅពេលប្រព័ន្ធធ្វើឱ្យត្រជាក់មិនដំណើរការឬសីតុណ្ហភាពរបស់ត្រង់ស្វូម៉ាទ័រ កើនឡើងគួរឱ្យកត់សំគាល់ | --- | ○ |

| | | | | |
|---|---|---|---|---|
| បរិក្ខាផលិតអនុភាពអសកម្ម | ត្រង់ស្វូម៉ាទ័រធម្មតា | ចរន្តលើស ឬតង់ស្យុងលើស ឬការឆ្លងខាងក្នុង | ○ | --- |
| | លក្ខខ័ណ្ឌធម្មតា | ចរន្តលើស | ○ | --- |
| | | ការឆ្លងខាងក្នុង | ○ | --- |
| | | ការកើនសីតុណ្ហភាព | --- | ○ |
| សីនរ៉េអាក់ទ័រ (រ៉េអាក់ទ័រតជាខ្សែ) | សីនរ៉េអាក់ទ័រដែលមានប្រព័ន្ធធ្វើឱ្យត្រជាក់ (ប្រព័ន្ធធ្វើឱ្យត្រជាក់ ដែលក្នុងនោះសារធាតុត្រជាក់ត្រូវធ្វើឱ្យត្រជាក់របុំនិងស្នូលដែករបស់សីនរ៉េអាក់ទ័រផ្ទាល់តែម្តង ហើយសារធាតុនះមានកម្លាំងជំរុញឱ្យវិល) | នៅពេលប្រព័ន្ធ ត្រជាក់មិនដំណើរការ ឬ សីតុណ្ហភាពរបស់សីនរ៉េអាក់ទ័រកើនឡើងគួរឱ្យ កត់សំគាល់ | --- | ○ |

**សំគាល់ :** ○ : ត្រូវតម្លើង

-- : មិនចាំបាច់

# មាត្រា ៣០.. ការរៀបចំបង្គោលទ្រខ្សែអាកាសតង់ស្យុងខ្ពស់

## ១. លក្ខខ័ណ្ឌជាមូលដ្ឋាន

ក- បង្គោលទ្រខ្សែអាកាសត្រូវតែរៀបចំឡើងដោយយកចិត្តទុកដាក់លើ បន្ទុកទាំងឡាយ ដូចខាងក្រោម:

**តារាង ១៤ ក - ប្រភេទបន្ទុក**

| **ប្រភេទបន្ទុក** | **សមាសភាពបន្ទុក** |
|---|---|
| បន្ទុកបញ្ឈរ | ទំងន់បង្គោលទ្រ |
| | ទំងន់ខ្សែចំលង,ខ្សែភ្ជាប់ដី និងគ្រឿងបន្ទាប់បន្សំដែលទ្រ ដោយបង្គោលទម្រ |
| | ទំងន់ចានអ៊ីសូឡាទ័រ និងប្រដាប់ទ្រផ្សេងៗដែលទ្រដោយ បង្គោលទម្រ |
| | ផ្នែកបញ្ឈរនៃកំលាំងទាញអតិបរមានៃខ្សែទាញទប់បង្គោល ប្រសិនបើមាន |

| | |
|---|---|
| បន្ទុកផ្តេកទទឹង | សម្ពាធចរន្តខ្យល់លើបង្គោលទម្រ នៅក្រោមល្បឿនខ្យល់ បក់អតិបរមា |
| | សម្ពាធចរន្តខ្យល់លើខ្សែចំលង និងខ្សែដី ដែលទ្រដោយបង្គោលទ្រ ក្រោមល្បឿនខ្យល់បក់អតិបរមា |
| | សម្ពាធចរន្តខ្យល់លើទំនាញលើចានទ្រ និងប្រដាប់ភ្ជាប់ផ្សេងៗដែលទ្រដោយបង្គោលទ្រ |
| | ផ្នែកផ្តេកទទឹងនៃកំលាំងទាញអតិបរមារបស់ខ្សែចំលង និងខ្សែដីដែលទ្រដោយបង្គោលទ្រ និងខ្សែទាញទប់បង្គោល ប្រសិនបើមាន |
| បន្ទុកផ្តេកបណ្តោយ | សម្ពាធចរន្តខ្យល់លើបង្គោលទ្រ នៅក្រោមល្បឿនខ្យល់អតិបរមា |
| | ផ្នែកផ្តេកបណ្តោយនៃកំលាំងទាញអតុល្យភាព អតិបរមារបស់ខ្សែចំលងនិងខ្សែដីដែលទ្រដោយបង្គោលទ្រ និងកំលាំងទំនាញអតិបរមា នៃខ្សែទាញទប់បង្គោលទ្រ ប្រសិនបើមាន |

ខ- បង្គោលទម្រនិងគ្រឹះនៃខ្សែបណ្តាញអាកាសតង់ស្យុងខ្ពស់ត្រូវតែរៀបចំឡើង ដោយគិតគូរដល់តម្លៃនៃសម្ពាធខ្យល់ ឈរលើមូលដ្ឋាននៃល្បឿនខ្យល់កំណត់ក្នុងមាត្រា ២៦ ។

គ- បង្គោលទ្រនិងគ្រឹះនៃខ្សែបណ្តាញអាកាសតង់ស្យុងខ្ពស់ ត្រូវតែរៀបចំឡើងយ៉ាងណាដើម្បីឱ្យបង្គោលទាំងនោះអាចធន់នឹងបន្ទុកអតិបរមា ដោយគិតគូរអំពីមេគុណសុវត្ថិភាពសមស្រប ។

ឃ- ក្នុងករណីដែលខ្សែបណ្តាញអាកាសតង់ស្យុងខ្ពស់ ត្រូវតម្លើងនៅកន្លែងមានល័ក្ខខ័ណ្ឌអាក្រក់បំផុត ដូចជានៅតាមតំបន់មាត់ទន្លេ តំបន់ ខ្យល់បក់ខ្លាំង និងតំបន់ដទៃទៀត ពេលនោះបង្គោលទម្រនិងគ្រឹះរបស់វាត្រូវតែរៀបចំយ៉ាងណា ដើម្បីឱ្យវាអាចធន់នឹងល័ក្ខខ័ណ្ឌពិបាកៗទាំងនោះ ។

## ២. ផ្នែកនានានៃបង្គោលទ្រ

ផ្នែកនានានៃបង្គោលទម្រត្រូវបំពេញបានតាមការកំណត់នៅចំនុចខាងក្រោម ឬត្រូវមានសមត្ថភាពប្រហាក់ប្រហែលគ្នាជាមួយការកំណត់នេះ ។

### ២.១ លក្ខណៈសំខាន់នៃផ្នែកនានារបស់បង្គោលទម្រ

ដែកសំប៉ែត, ដែកផ្គុំរាងផ្សេងៗ, បំពង់ដែក, បន្ទះដែក, របារ ដែក និងប៊ូឡុង ដែលរួមគ្នាបង្កើតជាបង្គោលដែកខ្ពស់ៗ ឬបង្គោលដែក ប្រើសម្រាប់ខ្សែបញ្ជូនអាកាស ត្រូវមានលក្ខណៈសមស្របតាមការកំណត់របស់ ISO (អង្គការអន្តរជាតិសម្រាប់កាងារស្តង់ដា) ស្តង់ដា ៥ ឬស្តង់ដាដទៃទៀតដែលប្រហាក់ប្រហែលនឹងស្តង់ដានេះ ។

## ២.២ កម្រាស់នៃដែកផ្សំនានា

ដែកផ្គុំរាងផ្សេងៗ, បំពង់ដែក និងបន្ទះដែក ដែលប្រើសម្រាប់ផ្គុំ ជាបង្គោលទម្រដែកខ្ពស់ៗឬបង្គោលដែកសម្រាប់ខ្សែបញ្ជូន អាកាស ត្រូវមានកម្រាស់និងមានទំហំដឺទៃទៀត តាមការកំណត់ខាងក្រោម :

### ២.២.១ កម្រាស់អប្បបរិមានៃដែកផ្គុំរាងផ្សេងៗ

ក. ដែកផ្គុំនានាដែលប្រើជាគ្រឿងផ្សំសំខាន់របស់បង្គោលដែក (ក្នុងនេះក៏គិតបញ្ចូលគ្រឿងផ្សំសំខាន់របស់ដៃទម្រដែរដែលត្រូវអនុវត្តដូចគ្នាតាមការកំណត់ក្នុងមាត្រានេះ) ត្រូវមានកម្រាស់៤មម ។

ខ. ដែកផ្គុំនានាដែលប្រើជាគ្រឿងផ្សំសំខាន់របស់បង្គោលទម្រខ្ពស់ៗ ត្រូវមានកម្រាស់ ៥ មម ។

គ. ដែកផ្គុំនានាដែលប្រើជាគ្រឿងផ្សំផ្សេងៗទៀតរបស់បង្គោលទម្រ ត្រូវមានកម្រាស់ ៣ មម ។

### ២.២.២ កម្រាស់អប្បបរិមានៃបំពង់ដែក

ក. បំពង់ដែកនានាដែលប្រើជាគ្រឿងផ្សំសំខាន់របស់បង្គោលដែក ត្រូវមានកម្រាស់ ២ មម ។

ខ. បំពង់ដែកនានាដែលប្រើជាគ្រឿងផ្សំសំខាន់របស់បង្គោលទ្រខ្ពស់ៗ ត្រូវមានកម្រាស់ ២.៤ មម ។

គ. បំពង់ដែកនានាដែលប្រើជាគ្រឿងផ្សំផ្សេងៗទៀតរបស់បង្គោលទ្រ ត្រូវមានកម្រាស់ ១.៦ មម ។

### ២.២.៣ អត្រាភាពស្តួច(Slenderness ratio) របស់ដែកផ្សំនានា

អត្រាភាពស្តួចរបស់ដែកផ្សំគឺជាសន្ទស្សន៍មួយ បង្ហាញអំពីភាពខ្ពស់ ស្រាវនៃរូបរាងរបស់វា ។ អត្រាភាពស្តួចរបស់ដែកផ្សំមួយ គឺ ជាផលចែកនៃប្រវែងជាមួយនឹងកាំនៃមុខកាត់របស់ដែកផ្សំនោះ ។ អត្រាភាពស្តួចកាន់តែធំមានន័យថាប្រវែងដែកផ្សំកាន់តែវែងឬមុខ កាត់ដែកកាន់តែតូច ដូច្នេះរូបរាងវាកាន់តែស្តួចវែង ធ្វើឱ្យរាងវាកាន់តែខ្សោយ ។ អត្រាភាពស្តួចកាន់តែតូច មានន័យថា ប្រវែងដែកផ្សំកាន់តែខ្លី ឬមុខកាត់វាកាន់តែធំ ដូច្នេះ រូបរាងវាកាន់តែកន្តុលខ្លី ធ្វើឱ្យរាងវាកាន់តែតែមាំ ។

អត្រាភាពស្តួចរបស់ដែកផ្សំទាំងឡាយដែលរងការសង្កត់ត្រូវ : មិនធំជាង២០០ សម្រាប់ដែកផ្សំទាំងឡាយដែលប្រើនៅបាតក្រោម, មិនធំជាង២២០ សម្រាប់ដែកផ្សំទាំងឡាយដែលរងការសង្កត់ប៉ុន្តែមិននៅបាតក្រោម (មិនគិតដែកផ្សំទាំងឡាយដែលប្រើជាលក្ខណៈ បន្ទាប់បន្សំ) និងមិនធំជាង ២៥០ សម្រាប់ដែកផ្សំដែលប្រើជា លក្ខណៈបន្ទាប់បន្សំ ។

### ២.២.៤ កម្រាស់អប្បបរិមានៃសន្លឹកដែក (បន្ទះដែក)

កម្រាស់នៃសន្លឹកដែក មិនត្រូវតូចជាង ១ មម ឡើយ ។

## ២.៣ កម្លាំងនៃដែករួមផ្សំ និងប៊ូឡុង

កម្លាំងនៃដែកផ្សំនិងប៊ូឡុងទាំងឡាយ ដែលប្រើសំរាប់បង្គោលដែក និងសសរដែក របស់ខ្សែបណ្តាញបញ្ជូនអាកាស ត្រូវមានកម្លាំង ដូចមានកំណត់ក្នុងតារាង ១៤ ខ ខាងក្រោម ៖

**តារាង ១៤ ខ**

| ចំណាត់ថ្នាក់កម្លាំង | | កម្លាំង |
|---|---|---|
| កម្លាំង ទាញ សងខាង | **នៅពេលដែល $\sigma Y \le 0.7\sigma B$** | $\sigma Y$ |
| | **នៅពេលដែល $\sigma Y > 0.7\sigma B$** | $0.7\sigma B$ |
| កម្លាំងសង្កត់សងខាង | | $\sigma Y$ |
| កម្លាំងពត់ចុងម្ខាង | | $\sigma Y$ |
| កម្លាំងកាត់ | **នៅពេលដែល $\sigma Y \le 0.7\sigma B$** | $\sigma Y / \sqrt{3}$ |
| | **នៅពេលដែល $\sigma Y > 0.7\sigma B$** | $0.7\sigma B / \sqrt{3}$ |
| កម្លាំងទ្រ | | $1.65\sigma Y$ |
| កម្លាំងប្រឆាំងឱ្យកោង | $0 < \lambda_k < \Lambda$ | $\sigma Y\left[K_0 - K_1\left\{\lambda_k \Big/ \left(\pi \Big/ \sqrt{(E/\sigma Y)}\right)\right\} - K_2\left\{\lambda_k \Big/ \left(\pi \Big/ \sqrt{(E/\sigma Y)}\right)\right\}^2\right]$ |
| | $\Lambda \le \lambda_k$ | $1.5\pi^2 E / 2.2\lambda_k^2$ |

ដែល

$\sigma Y$: កម្លាំងនៃចំណុចព្រមចុះចាញ់របស់ដែកផ្សំនិងប៊ូឡុង

$\sigma B$: កម្លាំងទប់ទំនាញរបស់ដែកផ្សំ និងប៊ូឡុង

$\lambda_k$: អត្រាភាពស្តួចដែលនៅមានប្រសិទ្ធភាព ( $= L_k / r$ )

$L_k$: ប្រវែងដែលមិនទាន់អាចគ្រេចរបស់ដែកផ្សំ

$r$: កាំរបស់មុខកាត់ដែកផ្សំ

$E$: អត្រាភាពយឺត ($20.6 \times 10^2$ N/m$^2$)

$\Lambda$: $\pi\sqrt{(1.5E / 2.2K\sigma Y)}$

មេគុណ $K, K_0, K_1, K_2$ កំណត់តាមតារាង ១៤-គ ។

## តារាង ១៤ គ ~ មេគុណ $K, K_0, K_1, K_2$ សម្រាប់តារាង ១៤ ខ

| | K | $K_0$ | $K_1$ | $K_2$ |
|---|---|---|---|---|
| ដែកផ្សំដែលមិនងាយសម្របតាម (បំពង់ដែក ,ដែកមុខកាត់រាង កាកបាទ ។ល។) | 0.6 | 1 | 0 | 0.352 |
| ដែកផ្សំដែលអាចសម្របតាមខ្លះ (ដែកពីរជ្រុង ប្រើសម្រាប់ផ្គុំផ្នែកខាងក្រោមនៃបង្គោល ។ល។) | 0.5 | 0.945 | 0.0123 | 0.316 |
| ដែកផ្សំដែលងាយសម្របតាម (ដែក២ជ្រុង ប្រើសម្រាប់ផ្នែកខ្វែងនៃបង្គោល ។) (*) | 0.3 | 0.939 | 0.424 | 0 |

(*) ត្រូវចំណាំថា កម្លាំងច្របាច់ឱ្យកោងមិនត្រូវច្រើនជាង $0.6\sigma Y$ សម្រាប់ដែកផ្សំដែលងាយសម្របតាមឡើយ

## ២.៤ កម្លាំងរបស់ផ្នែកទាំងឡាយនៃគ្រឹះដែលប្រើសម្រាប់សរសរដែក ឬបង្គោលដែកខ្ពស់ៗ

ផ្នែកទាំងឡាយនៃគ្រឹះរបស់សរសរដែកឬបង្គោលដែកខ្ពស់ៗ សម្រាប់ខ្សែបណ្តាញបញ្ជូនអាកាសត្រូវមានកម្លាំង ដូចការកំណត់ខាងក្រោម:

### ក-កម្លាំងរបស់បេតុង

កម្លាំងរបស់បេតុងនៅចំណុចព្រមចុះចាញ់ត្រូវគិតតាមកម្លាំងស្តង់ដាដែលបានកំណត់របស់បេតុង (កម្លាំងក្រោយ៤សប្តាហ៍ Fc) និងស្របតាមតារាង ១៤ ឃ ។

## តារាង ១៤ ឃ ~ កម្លាំងរបស់បេតុង

| ប្រភេទកម្លាំង | កម្លាំងរបស់បេតុង [$\times 10^6 N/m^2$] |
|---|---|
| កម្លាំងសង្កត់សងខាង | Fc/2 |
| កម្លាំងទាញសងខាង | Fc/20 |
| កម្លាំងកាត់ | Fc/20 and 0.74+1.5Fc/100 |

### ខ-កម្លាំងចងភ្ជាប់គ្នារបស់បេតុង

កម្លាំងចងភ្ជាប់គ្នារបស់បេតុងនៅចំណុចព្រមចុះចាញ់ ត្រូវគិតតាមកម្លាំងស្តង់ដាដែលបានគ្រោងរបស់បេតុង (កម្លាំងក្រោយ៤សប្តាហ៍ Fc) និងស្របតាមតារាង ១៤ ង

## តារាង ១៤ ខ ~ កម្លាំងចងភ្ជាប់គ្នារបស់បេតុង

[$\times 10^6 N/m^2$]

| | ដែកភ្ជុំ | | តំណតភ្ជាប់ |
|---|---|---|---|
| | ដែកមូលនៅគែមលើ | ដែកមូលធម្មតា | |
| ដែកមូល | 6Fc/100 និងមិនធំជាង 1.32 | 9Fc/100 និងមិនធំជាង 1.99 | 6Fc/100 និងមិនធំជាង 1.32 |
| ដែកមូល ថ្នាំងអំពៅ | Fc/10 និងមិនធំជាង 1.32+3Fc/75 | 3Fc/20 និងមិនធំជាង 1.99+3Fc/50 | Fc/10 និងមិនធំជាង 1.32+3Fc/75 |
| ដែករាង ផ្សេងៗទៀត | | | 3Fc/100 និងមិនធំជាង 0.66 |

### គ-កម្លាំងនៃដែករាងផ្សេងៗ ដែកសន្លឹក និងរបារដែក

កម្លាំងនៃដែករាងផ្សេងៗ ដែកសន្លឹក និងរបារដែក នៅចំណុចព្រមចុះចាញ់ ត្រូវអនុលោមតាមតារាង ១៤ ច ខាងក្រោម:

## តារាង ១៤ ច ~ កម្លាំងនៃដែករាងផ្សេងៗ ដែកសន្លឹក និងរបារដែក

| | | កម្លាំងទាញសងខាងនៅចំណុចព្រមចុះចាញ់ ($N/mm^2$) | កម្លាំងសង្កត់សងខាងនៅចំណុចព្រមចុះចាញ់ ($N/mm^2$) |
|---|---|---|---|
| ដែកមូល | | σY និងមិនធំជាង 234 | σY និងមិនធំជាង 234 |
| ដែកមូល ថ្នាំងអំពៅ | អង្កត់ផ្ចិត≥29 mm | σY និងមិនធំជាង 294 | σY និងមិនធំជាង 294 |
| | 29 mm > អង្កត់ផ្ចិត > 25 mm | σY | σY |
| | 25 mm≥ អង្កត់ផ្ចិត | σY និងមិនធំជាង 322 | σY និងមិនធំជាង 322 |
| ផ្សេងៗទៀត | | σY និងមិនធំជាង 0.7σB | σY |

σY: កម្លាំងនៃសំភារៈនៅចំណុចព្រមចុះចាញ់

σB: កម្លាំងទាញរបស់សំភារៈ

### ឃ-កម្លាំងរបស់ប៊ូឡុង

កម្លាំងរបស់ប៊ូឡុងត្រូវអនុលោមតាមតារាង ១៤ ខ ។

# ៣. បន្ទុកនៃសម្ពាធខ្យល់

## ៣.១ តម្លៃនៃសម្ពាធខ្យល់

បន្ទុកនៃសម្ពាធខ្យល់ត្រូវតែជាតម្លៃដែលបានគណនាផ្អែកលើសម្ពាធខ្យល់ដែលបានកំណត់ក្នុងតារាង ១៤ឆ ។

តារាងនេះមិនបាច់អនុវត្តឡើយ នៅពេលដែលការគណនាធ្វើឡើង ដោយផ្អែកលើតម្លៃដែលបានធ្វើតេស្ត សម្ពាធខ្យល់ (ក្នុងបំពង់ខ្យល់) ដោយប្រើល្បឿនខ្យល់មិនតូចជាង 32 m/s. ។
ផ្នែកដែលទទួលរងល្បឿនខ្យល់ ត្រូវតែជាផ្នែកបញ្ឈរដែលបានគ្រោង នៃដែកផ្សំរបស់បង្គោល ។ សម្រាប់ដែកទ្រអ៊ីសូឡាទ័ររបស់បង្គោលបេតុងនិងបង្គោលដែក លើកលែងតែបង្គោលដែករាងមូល និងបង្គោលដែកខ្ពស់ៗ ផ្នែកដែលទទួលរងល្បឿនខ្យល់ ត្រូវតែជាត្រូវតែជាផ្នែកបញ្ឈរ ដែលបានគ្រោងនៃរចនាសម្ព័ន្ធខាងមុខ ដែលរងខ្យល់ ។

### តារាង ១៤ ឆ ~ សម្ពាធខ្យល់សម្រាប់គណនាបន្ទុកនៃសម្ពាធខ្យល់

<table>
<tr><th colspan="4">សម្ពាធចរន្តខ្យល់</th><th>សម្ពាធខ្យល់ក្នុង $1\ m^2$ នៃផ្នែកបញ្ឈរ ដែលបានគ្រោងរបស់ដែលផ្សំ (N)</th></tr>
<tr><td rowspan="10">បង្គោលទ្រ</td><td rowspan="4">បង្គោលដែក</td><td colspan="2">បង្គោលរាងមូល</td><td>520</td></tr>
<tr><td colspan="2">បង្គោលរាងត្រីកោណ ឬរាងចតុកោណព្នាយ</td><td>1,220</td></tr>
<tr><td colspan="2">បង្គោលរាងចតុកោណស្មើដែលធ្វើពីដែកបំពង់</td><td>970</td></tr>
<tr><td colspan="2">បង្គោលដទៃទៀត</td><td>1,540</td></tr>
<tr><td rowspan="2">បង្គោលបេតុង</td><td colspan="2">បង្គោលរាងមូល</td><td>520</td></tr>
<tr><td colspan="2">បង្គោលបួនជ្រុងស្មើ</td><td>1290</td></tr>
<tr><td rowspan="4">បង្គោលដែក ខ្ពស់ៗ</td><td colspan="2">បង្គោលចម្រឹងដែកផ្គុំពីដែករាងផ្សេងៗ</td><td>2,350 *</td></tr>
<tr><td colspan="2">បង្គោលចម្រឹងដែកផ្គុំពីដែកបំពង់</td><td>1,340 *</td></tr>
<tr><td rowspan="2">បង្គោលតែមួយដើម</td><td>បង្គោលមូល</td><td>520</td></tr>
<tr><td>បង្គោលឆកោណឬអដ្ឋកោណ</td><td>970</td></tr>
</table>

<table>
<tr><td rowspan="2">ខ្សែចម្លងអគ្គិសនី និងខ្សែដទៃទៀត</td><td>ខ្សែអគ្គិសនីដែលមានខ្សែចម្លងច្រើនសសៃ (កំណត់ត្រឹមខ្សែណា ដែលមានខ្សែចម្លង២ត្រូវបានរៀបចំតាមខ្សែដេកជាមួយគ្នា ដោយមានចម្ងាយរវាងគ្នា មិនធំជាងង២០ដង នៃអង្កត់ផ្ចិតខាងក្រៅរបស់វា ។</td><td>610</td></tr>
<tr><td>ខ្សែចម្លងផ្សេងៗទៀត</td><td>680</td></tr>
<tr><td colspan="2">អ៊ីសូឡាទ័រ</td><td>900</td></tr>
<tr><td colspan="2" rowspan="2">ដែកទ្រអ៊ីសូឡាទ័រសម្រាប់បង្គោលដែក (កំណត់ត្រឹមតែបង្គោលមូល)និងបង្គោលបេតុង</td><td>1,030 ពេលប្រើវាជាធាតុតែមួយ</td></tr>
<tr><td>1,410 ក្នុងករណីផ្សេងទៀត</td></tr>
</table>

*តម្លៃនេះអនុវត្តសម្រាប់បង្គោលតង់ស្យុងខ្ពស់ ១១៥គីឡូវ៉ុល ដែលមានកំពស់ទាបជាង ៤០ម៉ែត្រ

### ៣.២ បន្ទុកនៃសម្ពាធខ្យល់បក់បញ្ឆៀង

នៅពេលខ្យល់បក់លើខ្សែបណ្តាញអគ្គិសនីតាមមុំ ៦០° បន្ទុកនៃសម្ពាធខ្យល់ក្នុងរូបភាពជាបន្ទុកធម្មតាសន្មតរបស់បង្គោលដែកខ្ពស់ៗ ត្រូវជាបន្ទុកដែលបានមកពីការគណនាដោយគុណនឹងមេគុណបន្ទុកនៃសម្ពាធខ្យល់ (ក្នុងករណីបង្គោលរាង៤ជ្រុងស្មើ) ក្នុងតារាង ១៤ ជ ។

### តារាង ១៤ ជ ~ មេគុណរបស់បន្ទុកនៃសម្ពាធខ្យល់

<table>
<tr><th colspan="3">ចំណាត់ថ្នាក់បន្ទុកនៃសម្ពាធខ្យល់</th><th>មេគុណបន្ទុកនៃសម្ពាធខ្យល់នៅពេលខ្យល់បក់កែងនឹងខ្សែបណ្តាញអគ្គិសនី (ក្នុងករណី បង្គោលរាង៤ជ្រុងស្មើ)</th></tr>
<tr><td rowspan="3">បន្ទុកនៃសម្ពាធខ្យល់លើបង្គោលដែកខ្ពស់ៗ</td><td rowspan="2">បន្ទុកនៃសម្ពាធខ្យល់លើតួបង្គោល</td><td>បង្គោលធ្វើពីដែកផ្សេងៗ</td><td>1.6</td></tr>
<tr><td>បង្គោលធ្វើពីបំពង់ដែក</td><td>1.4</td></tr>
<tr><td colspan="2">បន្ទុកនៃសម្ពាធខ្យល់លើដៃទម្រ</td><td>0.5 (សម្រាប់បន្ទុកនៃសម្ពាធខ្យល់លើខ្សែបណ្តាញអគ្គិសនី)</td></tr>
<tr><td colspan="3">បន្ទុកនៃសម្ពាធខ្យល់លើខ្សែ</td><td>0.75</td></tr>
</table>

## ៤. បន្ទុកលើបង្គោលទ្រ និងមេគុណសុវត្ថិភាព

បន្ទុកទាំឡាយលើបង្គោលទ្រ និងមេគុណសុវត្ថិភាពត្រូវតែបំពេញឱ្យបានតាមចំនុចដូចខាងក្រោម ឬមានការអនុវត្តប្រហាក់ប្រហែលនឹងចំនុចខាងក្រោម :

### ៤.១ ប្រភេទ និងការរួមគ្នានៃបន្ទុកសន្មត់ទាំងឡាយ

ប្រភេទនិងការរួមគ្នានៃបន្ទុកសន្មត់ទាំងឡាយ ដែលប្រើសម្រាប់គណនាកម្លាំងនៃបង្គោលទ្រសម្រាប់ខ្សែបណ្តាញបញ្ជូនអាកាស ត្រូវគោរពតាមការកំណត់ខាងក្រោម:

បន្ទុកសន្មត់ទាំងឡាយលើបង្គោលទ្រត្រូវចាត់ថ្នាក់ដូចការកំណត់ក្នុង តារាង ១៤ ឈ ។ ការរួមគ្នារបស់បន្ទុកទាំងនេះលើបង្គោលទ្រ ត្រូវអនុលោមតាមការកំណត់ ក្នុងតារាង ១៤ ញ អាស្រ័យទៅតាមចំណាត់ថ្នាក់និងប្រភេទនៃបង្គោលទ្រ ។

**តារាង ១៤ ឈ ៖ ចំណាត់ថ្នាក់នៃបន្ទុកសន្មត់ទាំងឡាយលើបង្គោលទ្រ**

| ប្រភេទនៃបន្ទុក | មាតិកា | និមិត្តសញ្ញា |
|---|---|---|
| បន្ទុកបញ្ឈរ | ទំងន់នៃបង្គោលទ្រ | **Wt** |
| | ទំងន់របស់ខ្សែចំលង ខ្សែភ្ជាប់ដី និងគ្រឿងបន្ទាប់បន្សំដែលទ្រដោយបង្គោលទ្រ | **Wc** |
| | ទំងន់ចានអ៊ីសូឡាទ័រ និងប្រដាប់ទ្រផ្សេងៗដែលទ្រដោយបង្គោលទ្រ | **Wi** |
| | ផ្នែកបញ្ឈរនៃកំលាំងទាញអតិបរមានៃខ្សែចម្លង និងខ្សែដី | **Va** |
| | ផ្នែកបញ្ឈរនៃកំលាំងទាញអតិបរមានៃខ្សែទប់របស់បង្គោល ប្រសិនបើមាន | **Ws** |
| បន្ទុកផ្តេកទទឹង | សម្ពាធខ្យល់លើបង្គោលទ្រ នៅក្រោមល្បឿនខ្យល់បក់អតិបរមា | **Ht** |
| | សម្ពាធខ្យល់លើខ្សែចំលង និងខ្សែដី ដែលទ្រដោយបង្គោលទ្រ ក្រោមល្បឿនខ្យល់អតិបរមា | **Hc** |
| | សម្ពាធខ្យល់លើចានអ៊ីសូឡាទ័រ និងប្រដាប់ភ្ជាប់ផ្សេងៗដែលទ្រដោយបង្គោលទម្រ | **Hi** |
| | ផ្នែកផ្តេកទទឹងនៃកំលាំងទាញអតិបរមារបស់ខ្សែចំលង និងខ្សែដីដែលទ្រដោយបង្គោលទ្រ និងខ្សែទាញបង្គោល ប្រសិនបើមាន | **Ha**<br>**Hs** |
| | បន្ទុករមួល បណ្តាលមកពីអតុល្យភាពនៃកម្លាំងទាញអតិបរិមារបស់ខ្សែចម្លងហ្វាណាមួយ | **q** |
| បន្ទុកផ្តេកបណ្តោយ | សម្ពាធខ្យល់លើបង្គោលទ្រ នៅក្រោមល្បឿនខ្យល់អតិបរមា | **Ht'** |
| | ផ្នែកផ្តេកបណ្តោយនៃកំលាំងទាញអតិបរមា នៃខ្សែទប់ដែលទប់បង្គោលទ្រ ប្រសិនបើមាន | **Ws'** |
| | អតុល្យភាពនៃកម្លាំងទាញអតិបរិមារបស់ខ្សែ ចម្លងនៃហ្វាទាំងអស់ និងខ្សែដី | **P1** |
| | អតុល្យភាពនៃកម្លាំងទាញអតិបរិមារបស់ ខ្សែចម្លងនៃហ្វាណាមួយ | **P2** |
| | បន្ទុករមួល បណ្តាលមកពីអតុល្យភាពនៃកម្លាំងទាញអតិបរិមារបស់ខ្សែចម្លងនៃហ្វាណាមួយ | **q1** |

## តារាង ១៣ ៧ ~ ការរួមគ្នានៃបន្ទុកទាំងឡាយដែលមានលើបង្គោលទ្រ

| ចំណាត់ថ្នាក់បង្គោលទ្រ | ប្រភេទបង្គោល | លក្ខខ័ណ្ឌក្នុងការគ្រោង | | ការរួមគ្នានៃបន្ទុកសន្មត់ | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | លក្ខខ័ណ្ឌនៃបន្ទុក | ទិសដៅខ្យល់ | បន្ទុកបញ្ឈរ | | | | បន្ទុកផ្តេកទទឹង | | | | | បន្ទុកផ្តេកបណ្តោយ | | | | |
| | | | | $W_t$ | $W_c$ Wi | $V_a$ | $W_s$ | $H_t$ | $H_c$ Hi | $H_a$ | $H_s$ | q | $H'_t$ | P1 | P2 | q1 | $W'_s$ |
| បង្គោលបេតុង បង្គោលដែក | ប្រភេទបង្គោលទប់ទំនាញនិងទ្រ | លក្ខខ័ណ្ឌធម្មតា | ផ្តេកទទឹង | ○ | ○ | ○ | ○ | ○ | ○ | ○ | ○ | | | | | | |
| | | | ផ្តេកបណ្តោយ | ○ | ○ | ○ | ○ | | | ○ | | | ○ | | | | ○ |
| | ប្រភេទបង្គោលចុងគេ | លក្ខខ័ណ្ឌធម្មតា | ផ្តេកទទឹង | ○ | ○ | ○ | ○ | ○ | ○ | | ○ | | | ○ | | | |
| | | | ផ្តេកបណ្តោយ | ○ | ○ | ○ | ○ | | | | | | ○ | ○ | | | ○ |
| បង្គោលដែកខ្ពស់ៗ បង្គោលដែកទោល | ប្រភេទបង្គោលទប់ទំនាញនិងទ្រ | លក្ខខ័ណ្ឌធម្មតា | ផ្តេកទទឹង /60° | ○ | ○ | ○ | ○ | ○ | ○ | ○ | ○ | | | | | | |
| | | | ផ្តេកបណ្តោយ | ○ | ○ | ○ | ○ | | | ○ | | | ○ | | | | ○ |
| | | លក្ខខ័ណ្ឌមិនប្រក្រតី | ផ្តេកទទឹង | ○ | ○ | ○ | ○ | ○ | ○ | ○ | ○ | ○ | | | ○ | ○ | |
| | | | ផ្តេកបណ្តោយ | ○ | ○ | ○ | ○ | | | ○ | | ○ | ○ | | ○ | ○ | ○ |
| | ប្រភេទបង្គោលចុងគេ | លក្ខខ័ណ្ឌធម្មតា | ផ្តេកទទឹង | ○ | ○ | ○ | ○ | ○ | ○ | | ○ | | | ○ | | | |
| | | | ផ្តេកបណ្តោយ | ○ | ○ | ○ | ○ | | | | | | ○ | ○ | | | ○ |
| | | លក្ខខ័ណ្ឌមិនប្រក្រតី | ផ្តេកទទឹង | ○ | ○ | ○ | ○ | ○ | ○ | | ○ | ○ | | ○ | | ○ | |
| | | | ផ្តេកបណ្តោយ | ○ | ○ | ○ | ○ | | | | | ○ | ○ | ○ | | ○ | ○ |

**ដែល:**

**ប្រភេទបង្គោលនៅខាងចុងគេ :** បង្គោលទ្រដែលមានបន្ទុកអតុល្យភាពធំនៅក្នុងទិសដៅផ្តេកបណ្តោយ ឧទាហរណ៍ : បង្គោលទី១ចេញពីអនុស្ថានីយ ។

**លក្ខខ័ណ្ឌមិនប្រក្រតី :** ការសន្មត់នៅពេលគ្រោងប្លង់បង្គោលថា មានខ្សែ ១ ឬ ២ ណាមួយនៃខ្សែចម្លង និងខ្សែដី នឹងដាច់ធ្លាក់ ។

**ចំណាំ:** សញ្ញារង្វង់ "○" បង្ហាញថាបន្ទុកសន្មត់នោះកើតឡើងក្នុងពេលតែមួយ ដែលអាចរួមចូលគ្នា ។

ត្រូវជ្រើសរើស ទិសដៅខ្យល់ណាដែលធ្វើឱ្យមានបន្ទុកសន្ទត់ ធំជាងគេ ។
នៅកន្លែងណាដែលខ្សែទាញរៀបចំមិនសមាមាត្រគ្នា នៅលើបង្គោលទ្រ បន្ទុកបញ្ឈរនឹងត្រូវបន្ថែមទៅលើបន្ទុក ដែលមានក្នុងតារាង ១៤ ញ និងបន្ទុករមួលធម្មតាត្រូវបន្ថែមលើប្រភេទបង្គោលចុងគេ ។

## ៤.២ កម្លាំងទាញអតុល្យភាពអតិបរិមា និងកម្លាំងផ្សេងៗទៀត

កម្លាំងទាញអតុល្យភាពអតិបរិមា និងកម្លាំងផ្សេងៗទៀតដែលប្រើនៅក្នុង ៤.១ ត្រូវអនុលោមទៅតាម លក្ខខ័ណ្ឌខាងក្រោម :

**៤.២.១** កម្លាំងទាញនិងកម្លាំងរមួលអតុល្យភាពអតិបរិមា ត្រូវអនុលោម ទៅតាមតារាង ១៤ ដ ។

### តារាង ១៤ ដ ~ កម្លាំងទាញនិងកម្លាំងរមួលអតុល្យភាពអតិបរិមា

| ចំណាត់ថ្នាក់នៃបង្គោលទ្រ | ប្រភេទបង្គោលទ្រ | កម្លាំងទាញនិងកម្លាំងរមួលអតុល្យភាព | |
|---|---|---|---|
| | | បន្ទុកធម្មតាសន្ទត់ | បន្ទុកមិនប្រក្រតីសន្ទត់ |
| បង្គោលដែកខ្ពស់ៗ | ប្រភេទបង្គោលទប់ទំនាញនិងទ្រ | មិនមានកំណត់ | ផ្នែកផ្ដេកបណ្ដោយនៃកំលាំងរបស់កម្លាំងទប់អតុល្យភាពនិងកម្លាំងរមួលដែលកើតមកពីការកាត់ខ្សែ |
| | ប្រភេទបង្គោលចុងគេ | ផ្នែកផ្ដេកបណ្ដោយនៃកំលាំងរបស់កម្លាំងអតុល្យភាពស្មើនឹងកម្លាំងសន្ទត់អតិបរិមាសម្រាប់ខ្សែទាញនីមួយៗ | |
| បង្គោលបេតុងនិងបង្គោលដែក | ប្រភេទបង្គោលទប់ទំនាញនិងទ្រ | មិនមានកំណត់ | មិនមានកំណត់ |
| | ប្រភេទបង្គោលចុងគេ | ផ្នែកផ្ដេកបណ្ដោយនៃកំលាំងរបស់កម្លាំងទប់អតុល្យភាពស្មើនឹងកម្លាំងទប់សន្ទត់អតិបរិមាសម្រាប់ខ្សែទាញនីមួយៗ | |

**៤.២.២** សម្រាប់បង្គោលដែកខ្ពស់ៗ, ការកាត់ខ្សែអគ្គិសនីត្រូវអនុលោម ទៅតាមលក្ខខ័ណ្ឌកំណត់ខាងក្រោម អាស្រ័យទៅតាមចំនួន ហ្វាសរុបរបស់ខ្សែចម្លងអគ្គិសនី (មានន័យថាហ្វាសម្រាប់ សៀគ្វីនីមួយៗ ហើយហ្វានិមួយៗនេះក៏ត្រូវគោរពតាមលក្ខខ័ណ្ឌ ខាងក្រោមដែរ) ។

ក. ខ្សែជីព្សួរលើអាកាស មិនត្រូវកាត់ព្រមគ្នាក្នុងពេលតែមួយជាមួយនឹងខ្សែចម្លងអគ្គិសនីឡើយ បើកាត់ គឺត្រូវកាត់តែខ្សែមួយ ។

ខ. កន្លែងដែលហ្វាទាំងអស់របស់ខ្សែចម្លងអគ្គិសនីមានចំនួនមិនលើសពី ១២, ត្រូវកាត់ខ្សែហ្វាតែ១ ហ្វាណាដែលបង្កើតភាពតានតឹងខ្លាំងជាងគេទៅលើដែកផ្សំនីមួយៗ (អាចកាត់ខ្សែចម្លង២ ក្នុងករណីមានខ្សែចម្លងអគ្គិសនីច្រើនក្នុងហ្វា១ សំរាប់បង្គោលដែកខ្ពស់ៗ លើកលែងតែប្រភេទបង្គោលចុងគេ)

គ. កន្លែងដែលហ្វាទាំងអស់របស់ខ្សែចម្លងអគ្គិសនី មានចំនួនលើសពី១២, (លើកលែងករណីដែលបញ្ជាក់ក្នុងចំណុចឃ) អាចកាត់ហ្វាចំនួន២ដែលនៅក្នុងសៀគ្វីផ្សេងគ្នា ហ្វាណាដែលបង្កើតភាពតានតឹងខ្លាំងជាងគេទៅលើដែកផ្សំនីមួយៗ (អាចកាត់ខ្សែចម្លង២ ក្នុងករណីមានខ្សែចម្លងអគ្គិសនីច្រើនក្នុងហ្វា១ សំរាប់បង្គោលដែកខ្ពស់ៗ លើកលែងតែប្រភេទបង្គោលចុងគេ)

ឃ. កន្លែងដែលការរៀបចំខ្សែចម្លងអគ្គិសនីមានហ្វាចំនួន ៩ ឬច្រើនជាង បិតនៅក្នុងជួរដេកបណ្តោយ និងហ្វាចំនួន២នៅជួរដេកទទឹង, អាចកាត់ហ្វា១ក្នុងចំណោមហ្វា៦ដែលនៅខាងលើគេនៅក្នុងជួរដេកបណ្តោយ ( អាចកាត់ខ្សែចម្លង២ ក្នុងករណីមានខ្សែចម្លងអគ្គិសនីច្រើនក្នុងហ្វា១សំរាប់បង្គោលដែកខ្ពស់ៗ លើកលែងតែប្រភេទបង្គោលចុងគេ) និងហ្វា១ទៀតនៃហ្វាដទៃទៀត (អាចកាត់ខ្សែចម្លង២ ក្នុងករណីមានខ្សែចម្លងអគ្គិសនីច្រើនក្នុងហ្វា១ សំរាប់បង្គោលដែកខ្ពស់ៗ លើកលែងតែប្រភេទបង្គោលចុងគេ) ដែលបង្កើតភាពតានតឹងខ្លាំងជាងគេទៅលើដែកផ្សំនីមួយៗ ។

**៤.២.៣** កម្លាំងទាញអតុល្យភាពដែលកើតឡើងដោយសារការកាត់ខ្សែ ត្រូវស្មើនឹងកម្លាំងទប់ទំនាញអតិបរិមា ។ ទោះជាយ៉ាងណាក៏ដោយ កម្លាំងទាញអតុល្យភាពអាចស្មើនឹង ០.៦ ដង នៃកម្លាំងទប់ទំនាញអតិបរមា ប្រសិនបើ ដោយអនុលោមតាមវិធីទាញខ្សែ, ចំណុចទប់របស់ខ្សែផ្លាស់ប្តូរទីតាំង នៅពេលខ្សែត្រូវបានកាត់ ឬក៏ខ្សែរអិលចេញពីចំណុចទប់ ។

## ៤.៣ មេគុណសុវត្ថិភាពនៃបង្គោលទ្រ

កម្លាំងរបស់ដែកផ្សំនៅចំណុចព្រមចុះចាញ់ នៃបង្គោលបេតុង បង្គោលដែក និងបង្គោលដែកខ្ពស់ៗ ដែលប្រើសម្រាប់ខ្សែបញ្ជូន អាកាសត្រូវអនុលោមតាមមេគុណសុវត្ថិភាពបញ្ជាក់ក្នុងតារាង ១៣ ចំពោះ សម្រាប់បន្ទុកសន្មត់ដែលកំណត់ក្នុងចំណុច ៤.១ ដល់ ៤.២ ។

### តារាង ១៤ ឋ ~ មេគុណសុវត្ថិភាពនៃបង្គោលទ្រ

| ចំណាត់ថ្នាក់របស់បង្គោលទ្រ | ល័ក្ខខ័ណ្ឌនៃបន្ទុក | មេគុណសុវត្ថិភាព |
|---|---|---|
| បង្គោលបេតុង បង្គោលដែក | បន្ទុកសន្ធត់ធម្មតា | **2.0** |
| បង្គោលដែកខ្ពស់ៗ | បន្ទុកសន្ធត់ធម្មតា | **1.5** |
| | បន្ទុកសន្ធត់ក្នុងល័ក្ខខ័ណ្ឌមិនប្រក្រតី | **1.0 (1.5 សម្រាប់ដៃទ្រ)** |

## ៥. បន្ទុកលើគ្រឹះរបស់បង្គោលទ្រ និងមេគុណសុវត្ថិភាព

### ៥.១ បន្ទុកលើគ្រឹះរបស់បង្គោលទ្រ

បន្ទុកលើគ្រឹះរបស់បង្គោលទ្រសម្រាប់ខ្សែបញ្ជូនអាកាសត្រូវគណនា ដោយការបូកបញ្ចូលគ្នានៃបន្ទុកសន្ធត់ទាំងឡាយរបស់បង្គោលទ្រ ដែលបញ្ជាក់ក្នុងវាក្យខ័ណ្ឌ ៤ ហើយចំនួនអតិបរិមានៃផលបូក ត្រូវជាបន្ទុកសន្ធត់ធម្មតា និងជាបន្ទុកសន្ធត់ក្នុងល័ក្ខខ័ណ្ឌមិនប្រក្រតី សម្រាប់គ្រឹះបង្គោល ។

### ៥.២ មេគុណសុវត្ថិភាពរបស់គ្រឹះបង្គោល

មេគុណសុវត្ថិភាពរបស់គ្រឹះបង្គោលទ្រសម្រាប់ខ្សែបញ្ជូនអាកាសត្រូវបំពេញឱ្យបានតាមចំនួនកំណត់ក្នុងតារាង ១៤ ឌ សម្រាប់កម្លាំងនៅចំណុចព្រមចុះចាញ់របស់វា ។

### តារាង ១៤ ឌ ~ មេគុណសុវត្ថិភាពរបស់គ្រឹះបង្គោល

| ចំណាត់ថ្នាក់ នៃបង្គោលទ្រ | មេគុណសុវត្ថិភាព | |
|---|---|---|
| | **បន្ទុកសន្ធត់ធម្មតា** | **បន្ទុកសន្ធត់ក្នុងល័ក្ខខ័ណ្ឌមិនប្រក្រតី** |
| បង្គោលមេតុង និងបង្គោលដែក | **2.0** | **-** |
| បង្គោលដែកខ្ពស់ៗ | **2.0** | **1.33** |

### ៥.៣ ការគិតចំពោះទម្ងន់របស់គ្រឹះបង្គោល

ទម្ងន់របស់គ្រឹះបង្គោលដែលប្រើសម្រាប់គណនាមេគុណសុវត្ថិភាព ត្រូវគិតអនុលោមតាមការកំណត់ដូចខាងក្រោម :

ក. សម្រាប់គ្រឹះបង្គោលដែលទទួលរងបន្ទុកទាញឡើង ទម្ងន់របស់ គ្រឹះបង្គោលចំនួនមិនតិចជាង ២/៣ (ឬទម្ងន់ទាំងមូលរបស់គ្រឹះបង្គោលដែកខ្ពស់ៗសម្រាប់បន្ទុកក្នុងល័ក្ខខ័ណ្ឌមិនប្រក្រតី) អាចគិតបញ្ចូលទៅក្នុងកម្លាំងទប់ការទាញឡើងនេះ ។

ខ. សម្រាប់គ្រឹះបង្គោលដែលត្រូវរងបន្ទុកសង្កត់ពីលើ ទម្ងន់របស់គ្រឹះបង្គោល ត្រូវគិតបញ្ចូលទៅក្នុងបន្ទុកសង្កត់ពីលើនេះ ។

# មាត្រា ៣១.. ការគ្រោងរៀបចំប្រដាប់ទ្រសម្រាប់សំរាប់ទ្រខ្សែចម្លង និង/ឬ សម្រាប់ទ្រខ្សែដី នៃខ្សែបណ្តាញអាកាសតង់ស្យុងខ្ពស់

## ១. មេគុណសុវត្ថិភាពនៃប្រដាប់ទ្រសម្រាប់ខ្សែចម្លង និង/ឬ ខ្សែដី នៃខ្សែបណ្តាញអាកាសតង់ស្យុងខ្ពស់

**១.១** មេគុណសុវត្ថិភាពសម្រាប់កំលាំងទប់ទំទាញ (កម្លាំងទាញអតិបរិមា ឬកម្លាំកាច់អតិបរិមា) របស់ប្រដាប់ទ្រខ្សែចម្លងនិងខ្សែដីនៃខ្សែបណ្តាញអាកាសតង់ស្យុងខ្ពស់ ត្រូវស្មើនឹង ២.៥ ឬធំជាង។

២.១ មេគុណសុវត្ថិភាពដែលចែងខាងលើនេះត្រូវគណនាដូចខាងក្រោម:

(ក) ចានអ៊ីសូឡាទ័រទប់ទំទាញ (ចានអ៊ីសូឡាទ័រដែលទប់ការទាញរបស់ខ្សែចំលង)

[មេគុណសុវត្ថិភាព] = [កំលាំងទប់ការទាញបំបាក់] / [កំលាំងទាញអតិបរិមានៅចំនុចទ្រ ]

(ខ) ចានអ៊ីសូឡាទ័រព្យួរ (ចានអ៊ីសូឡាទ័រដែលប្រើសំរាប់ព្យួរខ្សែចំលង)

[មេគុណសុវត្ថិភាព] = [កំលាំងទប់ការទាញបំបាក់] / [ការផ្តុំបន្ទុកនៃបន្ទុកបញ្ឈរ និងបន្ទុកផ្តេកទទឹង]

(គ) ចានអ៊ីសូឡាទ័រទ្រ

[មេគុណសុវត្ថិភាព] = [កំលាំងទប់ការពត់បំបាក់] / [បន្ទុកផ្តេកទទឹង ឬបន្ទុកបញ្ឈរដែលធ្វើសកម្មភាពកែងនឹងអ័ក្សអាប់ស៊ីសរបស់ចានអ៊ីសូឡាទ័រ]

## ២. កម្លាំងមេកានិចរបស់ចានអ៊ីសូឡាទ័រសម្រាប់ខ្សែបញ្ជូនអាកាស

### ២.១ បន្ទុកសន្មត់

បន្ទុកសន្មត់ដែលប្រើសម្រាប់គណនាកម្លាំងរបស់ចានអ៊ីសូឡាទ័រ សម្រាប់ខ្សែបញ្ជូនអាកាសត្រូវអនុលោមទៅតាមល័ក្ខខ័ណ្ឌដូចខាងក្រោម :

ក- បន្ទុកបញ្ឈរ

បន្ទុកបញ្ឈរត្រូវជាផលបូករវាងទម្ងន់របស់ខ្សែចម្លង ទម្ងន់របស់ចានអ៊ីសូឡាទ័រ និងផ្នែកបញ្ឈរនៃកំលាំងដែលកើតឡើងដោយកំលាំងទាញសន្មត់អតិបរិមារបស់ខ្សែចំលង ។

ខ- បន្ទុកផ្តេកទទឹង

បន្ទុកផ្តេកទទឹងត្រូវជាផលបូករបស់បន្ទុកនៃសម្ពាធខ្យល់របស់ខ្សែចម្លង និងចានអ៊ីសូឡាទ័រ និងផ្នែកផ្តេកនៃកំលាំងដែលកើតឡើង ដោយកំលាំងទាញសន្មត់អតិបរមារបស់ខ្សែចម្លង ។ បន្ទុកនៃសម្ពាធខ្យល់ត្រូវគណនាផ្អែកលើចំនួនដែលកំណត់ក្នុងតារាង ១៤ ឆ ។

គ- កំលាំងទាញសន្មត់អតិបរិមារបស់ខ្សែចម្លង

កំលាំងទាញសន្មត់អតិបរិមារបស់ខ្សែចំលង គឺជាកំលាំងទាញរបស់ខ្សែបញ្ជូនដែលជាការផ្គុំនៃបន្ទុកបញ្ឈរដែលកើតឡើងដោយទម្ងន់របស់ខ្សែចម្លង និងបន្ទុកផ្តេកដែលកើតឡើងដោយសម្ពាធខ្យល់ផ្តេក ចែងក្នុងតារាង ១៤ ឆ នៅក្នុងសីតុណ្ហភាពមធ្យមក្នុងតំបន់ ។

## មាត្រា ៣២.. ការការពារទល់នឹងរន្ទះសម្រាប់ខ្សែបណ្តាញអាកាសតង់ស្យុងខ្ពស់

ដើម្បីបន្ថយចំនួនកំហូចអគ្គិសនី និងដើម្បីការពារបរិក្ខាកុំឱ្យខូចបណ្តាលមកពីកំហូចនេះ ចំពោះខ្សែបណ្តាញអាកាសតង់ស្យុងខ្ពស់ ត្រូវអនុវត្តវិធានការណ៍ ដូចខាងក្រោម :

ក- ត្រូវតម្លើងខ្សែដីសំរាប់ខ្សែបណ្តាញអាកាសតង់ស្យុងខ្ពស់។

ខ- ត្រូវតម្លើងក្បាលកោងច្រាលអគ្គិសនី នៅចុងទាំងសង្ខាងនៃបង្គុំចានអ៊ីសូឡង់របស់ខ្សែបណ្តាញអាកាសតង់ស្យុងខ្ពស់ ។

គ- ត្រូវតម្លើងចង្កូវដែកដើម្បីចាប់ខ្សែចំលងដោយប្រដាប់រឹតភ្ជាប់នៃបង្គុំចានអ៊ីសូឡាទ័រនៃខ្សែបណ្តាញអាកាសតង់ស្យុងខ្ពស់ ។

## មាត្រា ៣៣~. ខ្សែស្រាតនៃខ្សែបណ្តាញអាកាសតង់ស្យុងខ្ពស់

### ១. ប្រដាប់ទប់រំញ័រ

ត្រូវតម្លើងប្រដាប់ទប់រំញ័រតាមចំនួននិងប្រភេទសមស្របដើម្បីបង្ការការចុះខ្សោយនៃខ្សែស្រាតនិងខ្សែដី សំរាប់ខ្សែបណ្តាញអាកាសតង់ស្យុងខ្ពស់ ដែលបណ្តាលមកពីរំញ័រដោយខ្យល់ ។

### ២. ការតភ្ជាប់

ក្នុងករណីដែលខ្សែស្រាតនិងខ្សែដីត្រូវតភ្ជាប់គ្នាទៅវិញទៅមកឬតភ្ជាប់គ្នាជាមួយខ្សែស្រោមឬខ្សែកាប ការតភ្ជាប់នេះ ត្រូវគោរពតាមការតម្រូវនានាដូចខាងក្រោមនេះ បន្ថែមលើការតម្រូវនៃមាត្រា២៥របស់ លលសបអ នេះ ។

- ក- ខ្សែស្រាតនិងខ្សែដីត្រូវតភ្ជាប់គ្នា ដោយបំពង់តភ្ជាប់ប្រភេទមានក្រចាប់រិតឱ្យណែនឬដោយប្រដាប់ច្របាច់បញ្ចូលគ្នា ។
- ខ- កំលាំងទំនាញនៃតំណខ្សែស្រាតនិងខ្សែដីត្រូវស្មើនឹង ៩៥% ឬលើសនៃកំលាំងទំទាញរបស់ខ្សែស្រាត និងខ្សែដីដែលបានតភ្ជាប់ ។ ទោះបីយ៉ាងនេះក៏ដោយមិនត្រូវយកការតម្រូវនេះ ទៅអនុវត្តចំពោះករណីដែលកំលាំងទាញអតិបរមាដែលនឹងត្រូវរៀបចំនោះតូចជាងច្រើនធៀបទៅនឹងកំលាំងទំនាញខ្ពស់បំផុត នៃខ្សែស្រាតនិងខ្សែដីនោះទេ ដូចជាខ្សែខ្លីៗសំរាប់ចំលងចរន្តខ្សែភ្ជាប់ពីបង្គោលចុងក្រោយទៅនឹងអនុស្ថានីយ ឬផ្សេងៗទៀត ។

## មាត្រា ៣៤~. គម្លាតរវាងខ្សែស្រាតនិងបង្គោលទ្រនៃខ្សែបណ្តាញ អាកាសតង់ស្យុងខ្ពស់

គម្លាតរវាងខ្សែស្រាតជាមួយបង្គោលទ្រ ខ្សែទប់ និង/ឬជន្ទល់បង្គោល នៃខ្សែបណ្តាញអាកាសតង់ស្យុងខ្ពស់ត្រូវមានចំនួនដូចខាងក្រោម ។ គម្លាតនេះត្រូវតែធានាឱ្យបានទោះជាក្នុងករណីណាមួយដែលខ្សែចំលងយោកទៅយោកមកជាអតិបរមាក្រោមល្បឿនខ្យល់បក់អតិបរមាក៏ដោយ ។

### តារាង ១៥ ៖ គម្លាតរវាងខ្សែស្រាតជាមួយបង្គោលទ្រ

| តង់ស្យុងណូមីណាល់ | គម្លាត |
|---|---|
| ១១៥គីឡូវ៉ុល | មិនតិចជាង ០.៧០ម៉ែត្រ |
| ២៣០គីឡូវ៉ុល | មិនតិចជាង ១.៤៥ម៉ែត្រ |

គម្លាតរវាងខ្សែដីជាមួយខ្សែចំលងដែលបិតនៅជិតជាងគេ ក្នុងចន្លោះបង្គោលជាមួយគ្នា ត្រូវតែធំជាងគម្លាតដែលកំណត់ឱ្យចំណុចទ្រនៅចុងទាំងសងខាងនៃចន្លោះបង្គោល ។

## មាត្រា ៣៥៖. កំពស់ខ្សែបណ្តាញអាកាសតង់ស្យុងខ្ពស់

កំពស់ខ្សែចំលងនៃខ្សែបណ្តាញអាកាសតង់ស្យុងខ្ពស់ ត្រូវមានកំរិតដូចខាងក្រោម :

### ១. កំពស់នៅក្នុងតំបន់ទីក្រុង

កំពស់ខ្សែចម្លងនៃខ្សែបណ្តាញអាកាសតង់ស្យុងខ្ពស់នៅក្នុងតំបន់ ទីក្រុងមិនត្រូវតូចជាងកំពស់ដោយបូកបន្ថែម ០.០៦០ ម៉ែត្រ ថែម ពីលើកំពស់ ៦.៥០ ម៉ែត្រ សំរាប់រាល់ការកើន១០គីឡូវ៉ុល លើសពី ៣៥ គីឡូវ៉ុល ឡើយ ។

### តារាង ១៦ ក ៖ កម្ពស់នៅក្នុងតំបន់ទីក្រុង

| តង់ស្យុណូមីណាល់ | កម្ពស់ |
|---|---|
| ១១៥គីឡូវ៉ុល | មិនតិចជាង ៧.០០ ម៉ែត្រ |
| ២៣០គីឡូវ៉ុល | មិនតិចជាង ៧.៧០ ម៉ែត្រ |

## ២. កំពស់នៅក្នុងតំបន់ដែលជនទី៣ពិបាកចូលទៅជិត

កំពស់ខ្សែចម្លងនៃខ្សែបណ្តាញអាកាសតង់ស្យុងខ្ពស់នៅក្នុងតំបន់ដែលជនទី៣ពិបាកចូលទៅជិត មិនត្រូវតូចជាងកំពស់ដោយបូកបន្ថែម ០.០៦០ ម៉ែត្រ ថែមពីលើកំពស់ ៥.៥០ ម៉ែត្រ សំរាប់រាល់ការ កើន១០គីឡូវ៉ុល លើសពី ៣៥ គីឡូវ៉ុលឡើយ ។

**តារាង ១៦ ខ ៖ កំពស់នៅក្នុងតំបន់ដែលជនទី៣ពិបាកចូលទៅជិត**

| តង់ស្យុណមីណាល់ | កម្ពស់ |
|---|---|
| ១១៥គីឡូវ៉ុល | មិនតិចជាង ៦.០០ ម៉ែត្រ |
| ២៣០គីឡូវ៉ុល | មិនតិចជាង ៦.៧០ ម៉ែត្រ |

## ៣. កំពស់ឆ្លងពីលើផ្លូវថ្នល់ និង/ឬ ផ្លូវរថភ្លើង

កំពស់ខ្សែចម្លងរបស់ខ្សែបណ្តាញអាកាសតង់ស្យុងខ្ពស់ដែលកាត់ទទឹងលើផ្លូវថ្នល់ និង/ឬ ផ្លូវរថភ្លើងមិនត្រូវតូចជាងកំពស់ដោយបូកបន្ថែម ០.០៦ ម៉ែត្រ ថែមពីលើកំពស់ ១៣ ម៉ែត្រសំរាប់ រាល់ការកើន ១០ គីឡូវ៉ុលលើសពី ៣៥ គីឡូវ៉ុលឡើយ ។

**តារាង ១៦ គ ៖ កំពស់ឆ្លងពីលើផ្លូវថ្នល់ និង/ឬ ផ្លូវរថភ្លើង**

| តង់ស្យុណមីណាល់ | កម្ពស់ |
|---|---|
| ១១៥គីឡូវ៉ុល | មិនតិចជាង ១៣.៥០ ម៉ែត្រ |
| ២៣០គីឡូវ៉ុល | មិនតិចជាង ១៤.២០ ម៉ែត្រ |

## ៤. កំពស់ឆ្លងពីលើទន្លេនិង/ឬសមុទ្រ

កំពស់ខ្សែចម្លងរបស់ខ្សែបណ្តាញអាកាសតង់ស្យុងខ្ពស់ដែលកាត់ទទឹងទន្លេ និង/ឬ សមុទ្រ ត្រូវដូចខាងក្រោម:

## តារាង ១៦ ឃ ៖  កំពស់ឆ្លងពីលើទន្លេនិង/ឬសមុទ្រ

| កន្លែងដែលគ្មាននាវាឆ្លងកាត់ | | កន្លែងដែលមាននាវាឆ្លងកាត់ | |
|---|---|---|---|
| គិតចាប់ពីកំរិតកំពស់ទឹក ខ្ពស់បំផុត | | គិតចាប់ពីចំណុចខ្ពស់បំផុតនៃនាវា ដែលស្ថិតលើកំរិតកំពស់ទឹកខ្ពស់បំផុត (*១) | |
| មិនត្រូវតូចជាងកំពស់ដោយបូកបន្ថែម ០.០៦ម៉ែត្រថែមពីលើកំពស់ ៥.៥ម៉ែត្រសំរាប់រាល់ ការកើន១០គីឡូវ៉ុល លើសពី ៣៥គីឡូវ៉ុល ឡើយ ។ | | មិនត្រូវតូចជាងកំពស់ដោយបូកបន្ថែម ០.០៦ ម៉ែត្រ ថែមពីលើកំពស់ ៣ម៉ែត្រ សំរាប់រាល់ការកើន១០គីឡូវ៉ុល លើសពី ៣៥គីឡូវ៉ុលឡើយ ។ | |
| តង់ស្យុងមីណាល់ | កម្ពស់ | តង់ស្យុងមីណាល់ | កម្ពស់ |
| ១១៥គីឡូវ៉ុល | មិនតិចជាង ៦.០០ ម៉ែត្រ | ១១៥គីឡូវ៉ុល | មិនតិចជាង ៣.៥០ ម៉ែត្រ |
| ២៣០គីឡូវ៉ុល | មិនតិចជាង ៦.៧០ ម៉ែត្រ | ២៣០គីឡូវ៉ុល | មិនតិចជាង ៤.២០ ម៉ែត្រ |

(*១)ចំណុចខ្ពស់បំផុតនៃនាវាត្រូវសំរេចយកចំនួនមួយដែលថ្លឹងថ្លែងដល់ លទ្ធភាពក្នុងពេលអនាគត

### ៥. ចំណាំ

កំពស់ទាំងអស់ដែលបានរៀបរាប់ខាងលើត្រូវតែធានាឱ្យបាន ទោះជាក្នុងករណីណាមួយដែលមានការយារធ្លាក់ចុះជាអតិបរមានៃខ្សែចម្លងស្ថិតក្នុងសីតុណ្ហភាពអតិបរមាដែលកំណត់ ។

## មាត្រា ៣៦៖. គម្លាតរវាងខ្សែបណ្តាញអាកាសតង់ស្យុងខ្ពស់ និងមធ្យោបាយដទៃទៀត ឬដើមឈើ

### ១. បញ្ញត្តិទូទៅ

គម្លាតរវាងខ្សែចម្លងនីមួយៗនៃខ្សែបណ្តាញអាកាសតង់ស្យុងខ្ពស់ ជាមួយមធ្យោបាយដទៃទៀត ឬដើមឈើ ត្រូវតែដូចការកំណត់ខាងក្រោម :

#### ក- គម្លាតជាមួយមធ្យោបាយដទៃទៀត

គម្លាតរវាងខ្សែចម្លងនីមួយៗនៃខ្សែបណ្តាញអាកាសតង់ស្យុងខ្ពស់ និងមធ្យោបាយដទៃទៀតមិនត្រូវតូចជាងគម្លាត ដែលបូកបន្ថែម ០.០៦ម៉ែត្រ ថែមលើប្រវែង៣ម៉ែត្រសំរាប់រាល់ ការកើន ១០គីឡូវ៉ុល លើសពី ៣៥គីឡូវ៉ុល ឡើយ។

## តារាង ១៧ ក ~ គម្លាតជាមួយមធ្យោបាយដទៃទៀត

| តង់ស្យុណមីណាល់ | កម្ពស់ |
| --- | --- |
| ១១៥គីឡូវ៉ុល | មិនតិចជាង ៣.៥០ ម៉ែត្រ |
| ២៣០គីឡូវ៉ុល | មិនតិចជាង ៤.២០ ម៉ែត្រ |

### ខ- គម្លាតជាមួយដើមឈើ

គម្លាតរវាងខ្សែចម្លងនីមួយៗនៃខ្សែបណ្តាញអាកាសតង់ស្យុងខ្ពស់ និងដើមឈើមិនត្រូវតូចជាងប្រវែងដែលបូកបន្ថែម ០.០៦ម៉ែត្រ ថែមលើប្រវែង ២ម៉ែត្រសំរាប់រាល់ការកើន ១០ គីឡូវ៉ុល លើសពី ៣៥គីឡូវ៉ុល ឡើយ ។

## តារាង ១៧ ខ ~ គម្លាតជាមួយដើមឈើ

| តង់ស្យុណមីណាល់ | កម្ពស់ |
| --- | --- |
| ១១៥គីឡូវ៉ុល | មិនតិចជាង ២.៥០ ម៉ែត្រ |
| ២៣០គីឡូវ៉ុល | មិនតិចជាង ៣.២០ ម៉ែត្រ |

## គ- ចំណាំ

គម្លាតដែលបានរៀបរាប់ខាងលើត្រូវតែធានាឱ្យបានទោះជាក្នុងករណីណាមួយមានការយារធ្លាក់ចុះជាអតិបរមានៃខ្សែចម្លងដែលស្ថិតក្នុងសីតុណ្ហភាពអតិបរមា និង/ឬការយោកទៅយោកមកអតិបរមានៃខ្សែចំលងស្ថិតក្រោមល្បឿនខ្យល់អតិបរមាដែលបានកំណត់ក៏ដោយ ។




**រូបភាពទី ៧ ~ ការនៅជិតផ្ទាល់**

## ២. ការនៅជិត និងការឆ្លងកាត់ ជាមួយអាគារ

### ២.១ សំរាប់ខ្សែបណ្តាញអាកាសតង់ស្យុងខ្ពស់លើសពី ២៣០ គីឡូវ៉ុល

ខ្សែបញ្ជូនអាកាសដែលមានតង់ស្យុងណាមួយណាលើសពី ២៣០ គីឡូវ៉ុល ត្រូវតម្លើងមិនឱ្យតិចជាង៣ម៉ែត្រពី ចំងាយផ្តេកពីអាគារ ។




**រូបភាពទី ៨ ~ ការនៅជិតអាគារ (តង់ស្យុង២៣០គីឡូវ៉ុល)**

### ២.២ ខ្សែបណ្តាញអាកាសតង់ស្យុងខ្ពស់ ១១៥ គីឡូវ៉ុល

ខ្សែបញ្ជូនអាកាសដែលមានតង់ស្យុងណូមីណាល់ ១១៥ គីឡូវ៉ុល ត្រូវតម្លើងឱ្យមានគម្លាតមិនតិចជាង ៦ម៉ែត្រ ពីដំបូលអាគារ នៅពេលដែលខ្សែបណ្តាញអាកាសតង់ស្យុងខ្ពស់ ១១៥ គីឡូវ៉ុល នៅស្របជាមួយអាគារចម្ងាយ ៣ ម៉ែត្រ ឬកាត់ពីលើអាគារ ។




**រូបភាពទី ៩ ៖ ការឆ្លងកាត់អាគារ (១១៥គីឡូវ៉ុល)**

## ៣. ការនៅជិតឬការឆ្លងកាត់ពីលើរវាងខ្សែបណ្តាញតង់ស្យុងមធ្យម និងខ្សែបណ្តាញតង់ស្យុងខ្ពស់

គម្លាតរវាងខ្សែចម្លងនីមួយៗនៃខ្សែបណ្តាញតង់ស្យុងខ្ពស់ ជាមួយខ្សែបណ្តាញតង់ស្យុងមធ្យមឬខ្សែបណ្តាញតង់ស្យុងខ្ពស់ដទៃទៀត មិនត្រូវមានគម្លាតតិចជាងគម្លាតដែលបានគណនាដោយបូកបន្ថែម ០.០៦ ម៉ែត្រ ថែមលើប្រវែង ២ម៉ែត្រ សំរាប់រាល់ការកើន ១០គីឡូវ៉ុល លើសពី ៣៥ គីឡូវ៉ុល ។

## តារាង ១៨ ៖ គម្លាតរវាងខ្សែចម្លង

| | តង់ស្យុងណូមីណាល់ (គីឡូវ៉ុល) | គម្លាត (ម៉ែត្រ) |
|---|---|---|
| Ll | **115** | មិនតិចជាង ២.៥ |
| | **230** | មិនតិចជាង ៣.២ |




**រូបភាពទី ១០ ៖ ការនៅក្បែរគ្នា និងការឆ្លងកាត់ រវាងខ្សែបណ្តាញតង់ស្យុងមធ្យម និងខ្សែបណ្តាញតង់ស្យុងខ្ពស់**

# មាត្រា ៣៧៖. ការបង្ការចំពោះគ្រោះថ្នាក់និងការរំខានពីអាំងឌុចស្យុងអេឡិចត្រូស្តាទិច និង អាំងឌុចស្យុងអេឡិចត្រូម៉ាញេទិច

## ១. អាំងឌុចស្យុងអេឡិចត្រូស្តាទិច

ខ្សែបណ្តាញតង់ស្យុងខ្ពស់ ត្រូវតម្លើងយ៉ាងណាទប់ស្កាត់នូវគ្រោះថ្នាក់ចំពោះខ្លួនប្រាណមនុស្ស និង/ឬការរំខានលើខ្សែបណ្តាញគមនាគមន៍ដែលតម្លើងក្បែរខ្សែបណ្តាញតង់ស្យុងខ្ពស់ ដោយសារអាំងឌុចស្យុងអេឡិចត្រូស្តាទិច ។

ត្រូវយកចិត្តទុកដាក់អនុវត្តវិធានការណ៍សមស្របទាំងឡាយ រួមមាន ចំនុច ក និង ខ ខាងក្រោម ព្រមទាំងមាត្រា ២៧ នៃ លលសបអក ផង ។

ក. ដែនអគ្គិសនីដែលកើតឡើងដោយខ្សែបណ្តាញអាកាសតង់ស្យុង ខ្ពស់ស្ថិតនៅកំពស់ ១ម ពីលើដីមិនត្រូវមាន តម្លៃខ្ពស់ជាង ៣ គ.វ៉/ម ឡើយ លើកលែងតែចំពោះខ្សែបណ្តាញអាកាសតង់ស្យុងខ្ពស់នៅកន្លែងផ្សេងៗ ដែលជនទី៣អាចពិបាកចូលទៅជិតបានដូចជានៅលើភ្នំ ក្នុងដីកសិដ្ឋាន ជាដើម។

ខ. វត្ថុធាតុចំលងអគ្គិសនីដែលស្ថិតនៅពីលើអាគារក្រោមខ្សែបណ្តាញអាកាសតង់ស្យុងខ្ពស់ត្រូវតែភ្ជាប់ទៅដីតាមថ្នាក់ D ស្របទៅតាមមាត្រា ២១ នៃ លលសបអក នេះ ។

## ២. អាំងឌុចស្យុងអេឡិចត្រូម៉ាញេទិច

ត្រូវតម្លើងខ្សែបណ្តាញតង់ស្យុងខ្ពស់យ៉ាងណា ដើម្បីទប់ស្កាត់គ្រោះថ្នាក់ចំពោះខ្លួនប្រាណមនុស្ស និង/ឬការរំខាន ទាំងឡាយដែលបណ្តាលមកពីអាំងឌុចស្យុងអេឡិចត្រូម៉ាញ៉េទិចទៅលើខ្សែបណ្តាញតង់ស្យុងទាប និង/ឬ ខ្សែបណ្តាញ គមនាគមន៍ដែលបានតម្លើងក្បែរខ្សែបណ្តាញតង់ស្យុងខ្ពស់ ។ ត្រូវអនុវត្តវិធានការណ៍សមស្របទាំងឡាយរាប់ទាំងមាត្រា ២៧ នៃ លលសបអក នេះ ផង ។

# មាត្រា ៣៨.. ឧបករណ៍ចាប់ចរន្តច្រាល

## ១. បញ្ញត្តិទូទៅ

ត្រូវតម្លើង ឧបករណ៍ចាប់ចរន្តច្រាល នៅកន្លែងសមស្របទាំងឡាយនៃខ្សែបណ្តាញអគ្គិសនី ។

## ២. ការតម្លើងឧបករណ៍ចាប់ចរន្តច្រាល

### ២.១ ចំណុចតម្លើង ឧបករណ៍ចាប់ចរន្តច្រាល

នៅក្នុងសៀគ្វីតង់ស្យុងមធ្យមនិងខ្ពស់ ឧបករណ៍ចាប់ចរន្តច្រាលត្រូវតម្លើងនៅតាមចំណុចដូចបានរាយបង្ហាញខាង ក្រោម ឬនៅទីកន្លែងណាមួយដែលនៅជិតចំណុចទាំងនោះ ដើម្បីការពារកុំឱ្យខូចខាតនូវបរិក្ខារអគ្គិសនី ដែល តម្លើងនៅក្នុងសៀគ្វីអគ្គិសនីក្នុងស្ថានីយ អនុស្ថានីយ ស្ថានីយបែងចែក និងទីតាំងអ្នកប្រើប្រាស់តង់ស្យុងខ្ពស់ និង តង់ស្យុងមធ្យម ដោយកំណើនតង់ស្យុងឡើងហួស ។

ទោះជាយ៉ាងនេះក៏ដោយ ការកំណត់នេះមិនត្រូវអនុវត្តឡើយក្នុង ករណីដែលពុំមានការប្រឈមមុខនឹងការខូចខាតបរិក្ខាអគ្គិសនីទាំងនោះ ។

ក. ចំណុចទទួលនិងចំណុចចេញរបស់ខ្សែបណ្តាញអាកាស នៅក្នុងស្ថានីយ អនុស្ថានីយ ស្ថានីយបែងចែក ។

ខ. ចំណុចទទួលនៅលើទីតាំងអ្នកប្រើប្រាស់តង់ស្យុងខ្ពស់ និង មធ្យមដែលអគ្គិសនីត្រូវបានផ្គត់ផ្គង់ពីខ្សែបណ្តាញអាកាសតង់ស្យុងខ្ពស់ និងមធ្យម ។

គ. ទីកន្លែងដែលប្រឈមមុខនឹងគ្រោះថ្នាក់ដោយសារឧបករណ៍ចាប់ចរន្តច្រាលដែលតម្លើងតាមចំណុចខាងលើ ពុំមានប្រសិទ្ធភាពការពារដល់ ។




**រូបភាពទី ១១ ៈ ចំណុចតម្លើងរបស់ឧបករណ៍ចាប់ចរន្តច្រាល**

## ២.២ ការភ្ជាប់ខ្សែដីរបស់ឧបករណ៍ចាប់ចរន្តច្រាល

ការភ្ជាប់ខ្សែដីរបស់ឧបករណ៍ចាប់ចរន្តច្រាលត្រូវតម្លើង ទៅតាមល័ក្ខខ័ណ្ឌមាត្រា ២១, ២២ នៃលលសបអនេះ ។

រ៉េស៊ីស្តង់ខ្សែដីដែលត្រូវភ្ជាប់សម្រាប់ឧបករណ៍ចាប់ចរន្តច្រាល ក្នុងសៀគ្វីអគ្គិសនីតង់ស្យុងខ្ពស់និងតង់ស្យុងមធ្យម នៅក្នុងស្ថានីយ អនុស្ថានីយ ស្ថានីយបែងចែក និងទីតាំងអ្នកប្រើប្រាស់តង់ស្យុងខ្ពស់ និងមធ្យម ត្រូវមានតម្លៃតូចជាង 10Ω ច្រើនតាមដែលអាចធ្វើទៅបាន ដើម្បីកុំឱ្យប៉ះពាល់ដល់ដំណើរការរបស់ឧបករណ៍ចាប់ចរន្តច្រាល ។

# ជំពូក ៤

# មធ្យោបាយចែកចាយ

# តង់ស្យុងមធ្យម

# និងតង់ស្យុងទាប

## មាត្រា ៣៩. បង្គោលទ្រ

### ១. បន្ទុកលើខ្សែបណ្តាញចែកចាយអាកាស

បង្គោលទ្រនៃខ្សែបណ្តាញអាកាសតង់ស្យុងមធ្យមនិងទាបត្រូវគ្រោងឡើង ដោយយកមកគិតនូវបន្ទុកទាំងឡាយដែលមានបង្ហាញក្នុងតារាង ១៩ ក ។

**តារាង ១៩ ក ‿ ប្រភេទបន្ទុក**

| ប្រភេទបន្ទុក | បរិយាយ |
|---|---|
| បន្ទុក បញ្ឈរ | ទម្ងន់របស់បង្គោលទ្រ |
| | ទម្ងន់របស់ខ្សែបណ្តាញនិងខ្សែដី និងគ្រឿងបន្ទាប់បន្សំ ផ្សេងៗដែលទ្រដោយបង្គោលទ្រ |
| | ទម្ងន់របស់គ្រឿងអ៊ីសូឡាទ័រផ្សេងៗ ដៃទ្រនានា និង ឧបករណ៍ចែកចាយដែលទ្រដោយបង្គោលទ្រ |
| | សមាសធាតុបញ្ឈរនៃកម្លាំងទាញអតិបរមារបស់ខ្សែទប់ដែលទប់បង្គោលទ្រ |
| បន្ទុក ផ្តេកទទឹង | សម្ពាធរបស់ខ្យល់លើបង្គោលទ្រក្រោមល្បឿនខ្យល់អតិបរមា |
| | សម្ពាធរបស់ខ្យល់លើខ្សែចម្លងនិងខ្សែដីដែលទ្រដោយបង្គោលទ្រក្រោមល្បឿនខ្យល់អតិបរមា |
| | សម្ពាធរបស់ខ្យល់លើអ៊ីសូឡាទ័រ ដៃទ្រនានា និង ឧបករណ៍ចែកចាយដែលទ្រដោយបង្គោលទ្រ ក្រោមល្បឿនខ្យល់អតិបរមា |
| | សមាសធាតុផ្តេកទទឹងនៃកម្លាំងទំនាញអតិបរមារបស់ខ្សែចម្លង និងខ្សែដីដែលទ្រដោយបង្គោលទ្រ និងខ្សែទប់ដែលទប់បង្គោលទ្រ ប្រសិនបើមាន |
| បន្ទុកផ្តេក បណ្តោយ | បន្ទុករបស់ខ្យល់លើបង្គោលទ្រក្រោមល្បឿនខ្យល់អតិបរមា |
| | សមាសធាតុផ្តេកបណ្តោយនៃកម្លាំងទំនាញអតិបរមារបស់ខ្សែចម្លងនិងខ្សែដីដែលទ្រដោយបង្គោលទ្រ និងកម្លាំងទាញអតិបរមានៃខ្សែទប់ដែលទប់បង្គោលទ្រ ប្រសិនបើមាន |

តាមរយៈការគណនា ទីមួយ ត្រូវគណនាបន្ទុកនៅពេលសម្ពាធខ្យល់ធ្វើសកម្មភាពលើខ្សែបណ្តាញចែកចាយតាមទិសផ្តេកទទឹង និងទីពីរ ត្រូវគណនាបន្ទុកនៅពេលសម្ពាធខ្យល់ធ្វើសកម្មភាពលើខ្សែបណ្តាញចែកចាយតាមទិសផ្តេកបណ្តោយ បន្ទុកណាមួយនៃបន្ទុកទាំង ២ ដែលបង្កើតនូវភាពតានតឹងធំជាងគេលើផ្នែកផ្សំរបស់បង្គោលទ្រ ត្រូវកំណត់ថាជាបន្ទុកសន្មត់ធម្មតា ។

## ២. មេគុណសុវត្ថិភាពនៃគ្រឹះរបស់បង្គោលទ្រូ

- មេគុណសុវត្ថិភាពនៃគ្រឹះរបស់បង្គោលទ្រសម្រាប់ខ្សែបណ្តាញ អាកាសតង់ស្យុងទាប ត្រូវស្មើនឹង ២ ឬក៏ធំជាងធៀបទៅ នឹងសម្ពាធខ្យល់ ។

- មេគុណសុវត្ថិភាពនៃគ្រឹះរបស់បង្គោលទ្រសម្រាប់ខ្សែបណ្តាញ អាកាសតង់ស្យុងមធ្យម ត្រូវស្មើនឹង ២ ឬធំជាងធៀបទៅ នឹងបន្ទុកដែលបានរៀបរាប់ក្នុងតារាង ១៩ ក ។
- តារាង ១៩ ខ ខាងក្រោមនេះសំរាប់អនុវត្តចំពោះការ តម្លើងបង្គោលឈើ បង្គោលដែក និងបង្គោលបេតុងនៅលើដីទន់ ។ ការតម្លើងនៅកន្លែងផ្សេងពីនេះ និងការតម្លើងបង្គោលប្រភេទផ្សេងពីនេះ មិនអនុវត្តតាមតារាងនេះឡើយ ។

**តារាង ១៨ ខ**

| ប្រភេទ បង្គោល | បន្ទុកដែលគ្រោះនៃបង្គោលទ្រូ | ប្រវែង បង្គោល | ជំរៅត្រូវដាំ | ចន្លោះពីបង្គោលមួយ ទៅបង្គោល មួយទៀត |
|---|---|---|---|---|
| បង្គោលឈើ | ---- | ១៥ ម៉ែត្រ ឬតិចជាង | យ៉ាងតិច ១/៦ នៃប្រវែងសរុប | ខ្សែបណ្តាញតង់ស្យុងមធ្យមក្នុងតំបន់ទីក្រុង៖ ចន្លោះពីបង្គោលមួយទៅបង្គោលមួយទៀតមិនត្រូវលើសពី ៧៥ម ឡើយ។ |
| | | លើសពី១៥ម៉ែត្រ ដល់១៦ម៉ែត្រ | យ៉ាងតិច២.៥ម៉ែត្រ | |
| បង្គោលដែក | ---- | ១៥ម៉ែត្រ ឬ តិចជាង | យ៉ាងតិច ១/៦ នៃប្រវែងសរុប | ខ្សែបណ្តាញតង់ស្យុងទាបក្នុងតំបន់ទីក្រុង៖ ចន្លោះពីបង្គោលមួយទៅបង្គោលមួយទៀតមិនត្រូវលើសពី ៤០ម ឡើយ។ |
| | | លើសពី១៥ម៉ែត្រ ដល់១៦ម៉ែត្រ | យ៉ាងតិច២.៥ម៉ែត្រ | |
| បង្គោល បេតុងមាន សរសៃដែក | ៦.៥ គីឡូញូតុន ឬតូច ជាងនេះ | ១៥ម៉ែត្រ ឬតិចជាង | យ៉ាងតិច១/៦ នៃប្រវែងសរុប | ខ្សែបណ្តាញផ្សេងទៀត៖ មិនត្រូវលើសពី ១៥០ម ឡើយ។ |
| | | លើសពី១៥ម៉ែត្រ ដល់១៦ម៉ែត្រ | ២.៥ម៉ែត្រ យ៉ាងតិចបំផុត | |
| | | លើសពី១៦ម៉ែត្រ ដល់២០ម៉ែត្រ | ២.៨ម៉ែត្រ យ៉ាងតិចបំផុត | |

## ៣. កំលាំងទប់នៃបង្គោលបេតុងមានសរសៃដែក

- បង្គោលបេតុងមានសរសៃដែកសំរាប់ខ្សែបណ្តាញតង់ស្យុង ទាប ត្រូវតែមានកំលាំងអាចទប់នឹងបន្ទុកសម្ពាធខ្យល់

- បង្គោលបេតុងមានសរសៃដែកសំរាប់ខ្សែបណ្តាញតង់ស្យុងមធ្យម ត្រូវមានកំលាំងអាចទប់នឹងបន្ទុកដែលបានរៀបរាប់ក្នុង មាត្រា ៣១ នៃ លលសបអ នេះ ។

- បង្គោលបេតុងមានសរសៃដែក ត្រូវមានកំលាំងអាចទប់នឹងចំនួន ២ដងនៃកំលាំងបន្ទុកដែលបានគ្រោង ។

## ៤. មេគុណសុវត្ថិភាព

### ៤.១ ខ្សែចម្លង

កម្លាំទប់ទំនាញ (កម្លាំងទប់ទំនាញអតិបរិមា,កម្លាំងទប់ការកាច់បំបាក់) របស់ខ្សែចម្លងនៃបណ្តាញចែកចាយអាកាស និងខ្សែដីព្យួរលើអាកាស ត្រូវមានមេគុណសុវត្ថិភាពស្មើនឹង ២,៥ ឬធំជាង ។

### ៤.២ បង្គោលទ្រ

(១) បង្គោលទ្រសម្រាប់ខ្សែបណ្តាញអាកាសតង់ស្យុងទាប ត្រូវមានកំលាំងទប់បន្ទុកស្មើនឹង ១.២ ដងនៃសម្ពាធខ្យល់សម្រាប់បង្គោលឈើ និងកំលាំងទប់បន្ទុកស្មើនឹងសម្ពាធខ្យល់ សម្រាប់បង្គោលប្រភេទផ្សេងៗទៀត ។

(២) បង្គោលឈើដែលប្រើសម្រាប់ទ្រខ្សែបណ្តាញតង់ស្យុងមធ្យម ត្រូវតម្លើងដោយអនុលោមទៅតាមការកំណត់នៅក្នុងចំណុច ដូចខាងក្រោម :

ក. មេគុណសុវត្ថិភាពទល់នឹងសម្ពាធខ្យល់ ត្រូវមានចំនួន មិនតូចជាង ១,៣ និង

ខ. អង្កត់ផ្ចិតនៃចុងបង្គោលផ្នែកខាងលើ ត្រូវមានកម្រាស់ មិនតូចជាង ១២ សង់ទីម៉ែត្រ

(៣) គេអាចប្រើបង្គោលបេតុងមានសរសៃដែក និងបង្គោលដែក សំរាប់ទ្រខ្សែបណ្តាញអាកាសតង់ស្យុងមធ្យម នៅពេលដែលកំលាំងទប់របស់វាអាចទប់នឹងបន្ទុកសន្ទត់ធម្មតា ។

## ៥. ល្បឿនខ្យល់ជាមូលដ្ឋាន

ល្បឿនខ្យល់ជាមូលដ្ឋានដែលប្រើប្រាស់ក្នុងការគណនាបន្ទុករបស់ខ្យល់លើខ្សែបណ្តាញចែកចាយអាកាស ត្រូវមានចំនួនដូចខាងក្រោម :

**តារាង ១៩ គ ~ ល្បឿនខ្យល់ជាមូលដ្ឋាន**

| | |
|---|---|
| ល្បឿនខ្យល់ប្រចាំឆ្នាំអតិបរិមា គិតជាមធ្យមក្នុង ១០ នាទី (ក្នុងរយៈពេលខួប ៥០ ឆ្នាំ) | **32 m/sec** |

ល្បឿនខ្យល់ជាមូលដ្ឋានខាងលើនេះ ត្រូវផ្លាស់ប្តូរ នៅក្នុងល័ក្ខខ័ណ្ឌដូចខាងក្រោម :

ក, នៅពេលទិន្នន័យល្បឿនខ្យល់ដែលបានឃ្លាំមើលគ្រប់គ្រាន់ត្រូវបាន ប្រមូលរួច

ខ, នៅពេលត្រូវការពិសេសនូវស្ថិរភាពធំជាងមុន

គ, នៅពេលទីតាំងនោះមានឥទ្ធិពលណាមួយធ្វើឱ្យល្បឿនខ្យល់ថយចុះ ។

## ៦. ការបន្ថែមកម្លាំងទប់ដោយខ្សែទប់សម្រាប់បង្គោលទ្រ

បង្គោលទ្រត្រូវមានខ្សែទប់ដើម្បីចែករំលែកកម្លាំងទប់ជាមួយខ្សែទប់ ដោយអនុលោមតាមតារាង ១៩ ឃ ។ ក្នុងករណីនេះ កម្លាំងទប់របស់បង្គោលទ្រខ្លួនឯងត្រូវអាចទប់យ៉ាងហោចណាស់ក៏ពាក់កណ្តាលនៃបន្ទុករបស់ខ្យល់ដែរ ។

### ៦.១ ការតម្លើងខ្សែទប់និងមេគុណសុវត្ថិភាពនៃខ្សែទប់

#### ក. ការតម្លើងខ្សែទប់

ត្រូវតម្លើងខ្សែទប់ដើម្បីបន្ថែមកម្លាំងទប់ទៅឱ្យគ្រឹះបង្គោលទ្រ ប្រសិនបើលទ្ធផលនៃការគណនាមេគុណសុវត្ថិភាពរបស់គ្រឹះបង្គោលទ្រមានតម្លៃតូចជាង ២ ក្រោមល័ក្ខខ័ណ្ឌដូចខាងក្រោម :

**តារាង ១៩ ឃ ~ ល័ក្ខខ័ណ្ឌនៃការតម្លើងខ្សែទប់**

| **ល័ក្ខខ័ណ្ឌ** | **វិធីតម្លើង** | **មេគុណសុវត្ថិភាពរបស់ខ្សែទប់** |
|---|---|---|
| ក-បង្គោលទ្រដែលគ្មានកម្លាំងគ្រប់គ្រាន់ដើម្បីទប់សម្ពាធខ្យល់ | ត្រូវតម្លើងខ្សែទប់ដែលអាចទប់នឹងសម្ពាធខ្យល់ឱ្យបានត្រឹមត្រូវទៅតាមមុំនៃខ្សែបណ្តាញ | ២,៥ ឬធំជាង |
| ខ-បង្គោលទ្រដែលចន្លោះបង្គោលសងខាងខុសគ្នាច្រើន | ត្រូវតម្លើងខ្សែទប់ដែលអាចទប់នឹងកម្លាំងកើតមកពីអតុល្យភាពនៃកម្លាំងទាញនៅផ្នែកទាំងសងខាងនៃទិសដៅរបស់ខ្សែ | ១,៥ ឬធំជាង |

| | | |
|---|---|---|
| គ-បង្គោលទ្រដែលខ្សែបណ្ដាញទាំងសងខាងបង្កើតមុំធំជាង៥ដឺក្រេ | ត្រូវតម្លើងខ្សែទប់ដែលអាចទប់នឹងកម្លាំងកើតមកពីទំនាញសន្ទត់អតិបរិមានៃខ្សែនីមួយៗនៅផ្នែកផ្ទុយគ្នារបស់ខ្សែ | |
| ឃ បង្គោលទ្រដែលឋិតនៅខាងចុងខ្សែ | ត្រូវតម្លើងខ្សែទប់ដែលអាចទប់នឹងកម្លាំងទាញសន្ទត់អតិបរិមានៃខ្សែ នៅផ្នែកផ្ទុយគ្នារបស់ខ្សែ | |

## ខ. ផ្នែកនៅជិតដីរបស់ខ្សែទប់

ផ្នែកនៅជិតដីរបស់ខ្សែទប់ គឺគិតចាប់ពីផ្នែកនៅក្នុងដីរបស់ខ្សែទប់មកដល់កំពស់៣០សង់ទីម៉ែត្រ ខាងលើ ដី ត្រូវប្រើដែកមូលដែលមានស្រោបស្រទាប់ការពារ ឬលោហៈមូលដែលមានលក្ខណៈប្រហាក់ប្រហែល ឬលើស ចំពោះកម្លាំងទប់ និងការទប់ទល់នឹងភាពច្រេះស៊ី ។

## គ. គ្រឹះរបស់ខ្សែទប់

យុថ្ការបស់ខ្សែទប់ត្រូវតែតម្លើងឱ្យបានរឹងមាំយ៉ាងណា ដែលវាអាចធន់ នឹងកម្លាំងទាញរបស់ខ្សែទប់ ។ យុថ្ការបស់ខ្សែទប់ដែលត្រូវតម្លើងសម្រាប់ បង្គោលទ្រត្រូវតែជាវត្ថុធាតុដែលច្រេះមិនងាយស៊ី ។

## ឃ. ស្រោមអ៊ីសូឡង់

ប្រសិនបើខ្សែទប់ត្រូវបានតម្លើងនៅលើខ្សែបណ្ដាញចែកចាយអាកាស ដែលអាចមានគ្រោះថ្នាក់ដោយសារការប៉ះនឹងខ្សែចម្លងអគ្គិសនី គេត្រូវប្រើស្រោមអ៊ីសូឡង់ដើម្បីស្រោបផ្នែកខាងលើនៃខ្សែទប់នោះ ។

ទោះជាយ៉ាងនេះក៏ដោយ ប្រសិនបើខ្សែទប់ត្រូវបានតម្លើងនៅលើខ្សែបណ្ដាញចែកចាយអាកាសតង់ស្យុងទាបនៅកន្លែងក្រៅពីវាលស្រែ ឬ តំបន់លេចទឹក គេមិនចាំបាច់ស្រោបស្រោមអ៊ីសូឡង់ទេ ។

## ង. កម្ពស់របស់ខ្សែទប់

ខ្សែទប់ដែលឆ្លងកាត់ផ្លូវត្រូវមានកម្ពស់មិនតិចជាង ៦,៥ ម៉ែត្រ គិត ចាប់ពីផ្ទៃផ្លូវ ។ ប្រសិនបើករណីនេះមិនអាចអនុវត្តបានដោយសារហេតុផលបច្ចេកទេស អាចអនុញ្ញាតឱ្យមានកម្ពស់មិនតិចជាង ៤,៥ ម៉ែត្រ (ឬមិនតិចជាង ២,៥ ម៉ែត្រសម្រាប់ដីចំណីផ្លូវ) ប្រសិនបើកន្លែងនោះមិនបង្កឱ្យមានគ្រោះថ្នាក់ចរាចរ ។

## ច. ជន្ទល់

ជន្ទល់ដែលមានកម្លាំងប្រហាក់ប្រហែល ឬខ្ពស់ជាង អាចប្រើជំនួសខ្សែទប់បាន ។

## មាត្រា ៤០~. ខ្សែបណ្តាញអាកាសតង់ស្យុងមធ្យមនិងតង់ស្យុងទាប

### ១. ខ្សែកាបសំរាប់ខ្សែបណ្តាញអាកាស

ក. នៅពេលខ្សែកាបត្រូវបានប្រើប្រាស់សំរាប់ខ្សែបណ្តាញអាកាស ខ្សែកាបត្រូវតម្លើងដោយប្រើខ្សែសម្រាប់យោង ឬវិធីសមស្របផ្សេងទៀត ធ្វើយ៉ាងណាកុំឱ្យមានទំនាញលើខ្សែកាប ។ ខ្សែសម្រាប់យោង ត្រូវតែតម្លើង ស្របតាមការកំណត់ នៃមាត្រា ៣១ នៃ លលសបអក នេះ ។

ខ. នៅពេលខ្សែកាបត្រូវបានតម្លើងតាមបណ្តោយអគារ ឬវត្ថុដទៃទៀត ខ្សែកាបត្រូវតែបានទ្រយ៉ាងណាកុំឱ្យមានការខូចខាតដោយសារការប៉ះទៅនឹងអគារឬវត្ថុទាំងនោះ។

### ២. វិធីតភ្ជាប់ខ្សែចម្លងអាកាស

កំលាំងទប់ទំនាញនៃខ្សែចម្លងមិនត្រូវថយចុះ ២០% ឬលើសពីនេះទេ នៅពេលមានការតភ្ជាប់ខ្សែចម្លង ។ ប្រសិនបើកំលាំងទាញដែលមានលើ ខ្សែចម្លងមានតម្លៃតូចជាងច្រើនធៀបទៅនឹងកម្លាំងប្រ់ទំនាញនៃខ្សែចម្លង លក្ខខ័ណ្ឌនេះមិនបាច់អនុវត្តឡើយ ។

### ៣. ការតបំបែកចេញពីខ្សែបណ្តាញអាកាស

ការតបំបែកចេញពីខ្សែបណ្តាញអាកាសត្រូវធ្វើឡើងនៅត្រង់ចំណុចទ្រនៃ ខ្សែបណ្តាញនោះ ។ ប្រសិនបើការតបំបែកធ្វើឡើងដោយមិនបង្កើតកំលាំងទាញលើខ្សែចំលងនៅចំណុចបំបែកនោះទេ លក្ខខ័ណ្ឌនេះអាចមិនបាច់អនុវត្តបាន ។

## មាត្រា ៤១~. កំលាំងមេកានិចនៃអ៊ីសូឡាទ័រ

### ១. លក្ខណៈទូទៅនៃកំលាំងមេកានិចរបស់អ៊ីសូឡាទ័រ

អ៊ីសូឡាទ័រទ្រខ្សែបណ្តាញតង់ស្យុងមធ្យមត្រូវតែតម្លើងតាមរបៀបយ៉ាង ណាឱ្យអ៊ីសូឡាទ័រនោះមានកំលាំងគ្រប់គ្រាន់ដើម្បីទទួលបានមេគុណសុវត្ថិភាពស្មើនឹង ២.៥ ឬធំជាង ដោយផ្អែកលើការសន្មតថាបន្ទុកដូចខាងក្រោមនេះ ត្រូវបានផ្ទុកទៅលើអ៊ីសូឡាទ័រនោះ ។

ក. សំរាប់អ៊ីសូឡាទ័រថ្កក់ខ្សែ បន្ទុកត្រូវជាកំលាំងទាញអតិបរមា ដែលបានសន្មត់យកនៃខ្សែ

ខ. សំរាប់អ៊ីសូឡាទ័រទ្រខ្សែ បន្ទុកត្រូវជាបន្ទុកផ្តេកចំហៀង ឬបន្ទុកបញ្ឈរ ដែលទាញកែងនឹងអ័ក្សនៃអ៊ីសូឡាទ័រ ។

## ២. មេគុណសុវត្ថិភាពនៃអ៊ីសូឡាទ័រ

មេគុណសុវត្ថិភាពរបស់អ៊ីសូឡាទ័រសម្រាប់ខ្សែបណ្តាញតង់ស្យុងមធ្យម ត្រូវគណនាតាមសមីការដូចខាងក្រោមនេះ :

### ២.១ អ៊ីសូឡាទ័រថ្កក់ខ្សែ (អ៊ីសូឡាទ័រដែលមានទំពក់សម្រាប់ថ្កក់ខ្សែចម្លង)

$$\text{មេគុណសុវត្ថិភាព} = \frac{\text{កម្លាំងទាញបំបាក់}}{\text{កម្លាំងសន្ទុះអតិបរមានៃខ្សែ}}$$

### ២.២ អ៊ីសូឡាទ័រទ្រខ្សែ

$$\text{មេគុណសុវត្ថិភាព} = \frac{\text{កម្លាំងទាញបំបាក់}}{\text{បន្ទុកផ្តេកទទឹងឬបន្ទុកបញ្ឈរដែលទាញកែងនឹងអ័ក្សនៃអ៊ីសូឡាទ័រ}}$$

## ៣. បន្ទុកសន្ទុះ

បន្ទុកសន្ទុះដែលគេប្រើសម្រាប់គណនាកម្លាំងធន់របស់អ៊ីសូឡាទ័រនៃខ្សែបណ្តាញតង់ស្យុងមធ្យម ត្រូវគោរពតាមល័ក្ខខ័ណ្ឌដូចខាងក្រោម :

### ក. បន្ទុកបញ្ឈរ

បន្ទុកបញ្ឈរ គឺជាផលបូកនៃទម្ងន់របស់ខ្សែអគ្គិសនី និងទម្ងន់គ្រឿងផ្សំរបស់អ៊ីសូឡាទ័រ

### ខ. បន្ទុកផ្តេកទទឹង

បន្ទុកផ្តេកទទឹង គឺជាផលបូកនៃកម្លាំងសម្ពាធខ្យល់លើខ្សែចម្លងអគ្គិសនីលើគ្រឿងផ្សំនៃអ៊ីសូឡាទ័រ និងសមាសធាតុនៃបន្ទុកផ្តេកទទឹងដែលបង្កើតដោយកម្លាំងទាញសន្ទុះអតិបរមារបស់ខ្សែចម្លង ។ បន្ទុកសម្ពាធខ្យល់ត្រូវគណនាឈរលើមូលដ្ឋាននៃតម្លៃក្នុងតារាង ២០ ។

**តារាង ២០ ៖ បន្ទុកសម្ពាធខ្យល់**

| ផ្នែកនៃវត្ថុដែលរងសម្ពាធខ្យល់ | សម្ពាធខ្យល់លើ១ម៉ែត្រការ៉េនៃផ្ទៃបញ្ឈរ គិតជាប៉ាស្កាល់ |
|---|---|
| ខ្សែចម្លងអគ្គិសនី និងខ្សែចម្លងដទៃទៀត | **680** |
| គ្រឿងផ្សំនៃអ៊ីសូឡាទ័រ | **900** |

*សម្ពាធខ្យល់បានមកពីល្បឿនខ្យល់ ៣២ម/វិនាទី ដូចក្នុងតារាង ១៩ គ ។

## ៤. កម្លាំងទាញសន្ធត់អតិបរមានៃខ្សែបណ្ដាញ

កម្លាំងទាញសន្ធត់អតិបរមានៃខ្សែបណ្ដាញ គឺជាកម្លាំងទាញនៃខ្សែចម្លងរបស់ខ្សែបណ្ដាញតង់ស្យុងមធ្យម ក្រោមអំពើនៃផលបូកបន្ទុក ដូចខាងក្រោម ៖

ក. បន្ទុកដែលកើតឡើងដោយទម្ងន់ខ្សែចម្លង និង

ខ. បន្ទុកផ្ដេកដែលកើតឡើងដោយសម្ពាធខ្យល់ផ្ដេកដូចមានចែងក្នុងតារាង ២០ ។

## មាត្រា ៤២៖. ត្រង់ស្វូម៉ាទ័រតង់ស្យុងមធ្យម/ទាប

ត្រង់ស្វូម៉ាទ័រតង់ស្យុងមធ្យម/ទាបរួមទាំងខ្សែចម្លងតង់ស្យុងមធ្យម ក្រៅពីខ្សែកាប ត្រូវតែតម្លើងយ៉ាងណាមិនឱ្យមានគ្រោះថ្នាក់ឆក់អគ្គិសនី ដោយប្រើរបៀបណាមួយ នៃវិធីដូចខាងក្រោម៖

១. ត្រង់ស្វូម៉ាទ័រតង់ស្យុងមធ្យម/ទាប ត្រូវតម្លើងក្នុងបន្ទប់ដាច់ដោយឡែកមួយដែលត្រូវបានចាក់សោរ

២. ត្រង់ស្វូម៉ាទ័រតង់ស្យុងមធ្យម/ទាបត្រូវតម្លើងនៅកំពស់មិនតិចជាង ៥.០ម៉ែត្រ ពីផ្ទៃដី ដើម្បីកុំឱ្យមនុស្សអាចប៉ះវាបានដោយងាយស្រួល ។

៣. ត្រូវព័ទ្ធរបងឱ្យបានសមស្របជុំវិញត្រង់ស្វូម៉ាទ័រតង់ស្យុងមធ្យម/ទាប ដើម្បីកុំឱ្យមនុស្សអាចប៉ះវាបានដោយងាយស្រួលនិងត្រូវដាក់ផ្លាកសញ្ញាព្រមានអំពីគ្រោះថ្នាក់។ ម្យ៉ាងទៀតផ្នែកមានចរន្តនៃត្រង់ស្វូម៉ាទ័រតង់ស្យុងមធ្យម/ទាប ដែលត្រូវបិតនៅចំហរត្រូវតែតម្លើងវាយ៉ាងណាកុំឱ្យមនុស្សអាចប៉ះវាបានដោយងាយស្រួល ។

## មាត្រា ៤៣~. ការតម្លើងត្រង់ស្វូម៉ាទ័រចែកចាយសម្រាប់ប្រព័ន្ធខ្សែទោលចរន្តត្រឡប់តាមដី (SWER)

### ១. ការតម្លើងខ្សែដីសម្រាប់ប្រព័ន្ធខ្សែទោលចរន្តត្រឡប់តាមដី (SWER)

ខ្សែដីនៃផ្នែកចូលរបស់ត្រង់ស្វូម៉ាទ័រចែកចាយក្នុងប្រព័ន្ធខ្សែទោលចរន្តត្រឡប់តាមដី (SWER ) ត្រូវតម្លើងតាមរបៀបដូចខាងក្រោម ធ្វើយ៉ាងណាចៀសវាងកុំឱ្យកើតមានគ្រោះថ្នាក់ដល់មនុស្ស សត្វ ស្រុក និងខូចខាតសម្ភារៈផ្សេងៗ ដោយសារភាពខុសគ្នារវាងប៉ូតង់ស្យែលរបស់ប្រព័ន្ធខ្សែដី និងប៉ូតង់ស្យែលនៅលើដីដែលបណ្តាលមកពីចរន្តនៃបន្ទុក នៅពេលមានការខូចខាតណាមួយកើតឡើង ។

ក. រ៉េស៊ីស្តង់ដី ត្រូវមានតម្លៃ ៥ អូម ឬទាបជាង ។

ខ. មុខកាត់របស់ខ្សែដី មិនត្រូវតូចជាង ១៦ មម²

គ. ខ្សែដីដែលឋិតនៅជម្រៅពី៧៥សង់ទីម៉ែត្រផ្នែកក្រោមដី ដល់កម្ពស់ ២ ម៉ែត្រពីលើដី ត្រូវតែតម្លើងក្នុងបំពង់ទីបជ័រ ឬមានស្រោមការពារដែលមានគុណភាពអ៊ីសូឡង់ និងភាពធន់ប្រហាក់ប្រហែល ឬខ្ពស់ជាង ។

### ២. ចរន្តនៃបន្ទុករបស់ត្រង់ស្វូចែកចាយ

ចរន្តនៃបន្ទុកក្នុងសៀគ្វីចរន្តត្រឡប់តាមដីមិនត្រូវច្រើនជាង ៨ អាំពែរ ឡើយ ។

### ៣. ត្រង់ស្វូម៉ាទ័ររបុំដាច់គ្នា

សៀគ្វីប្រព័ន្ធខ្សែទោលចរន្តត្រឡប់តាមដី (SWER ) ត្រូវផ្គត់ផ្គង់ដោយត្រង់ស្វូម៉ាទ័រដែលមានរបុំពីរ ( **ត្រង់ស្វូម៉ាទ័ររបុំដាច់គ្នា** ) ។

### ៤. សុវត្ថិភាពសម្រាប់ជនទី៣

ផ្លាកសញ្ញាហាមឃាត់សម្រាប់រំលឹកដល់ជនទី៣ត្រូវតម្លើងនៅជិត ចំណុចខ្សែដី ។

## មាត្រា ៤៤~. ឧបករណ៍ការពារ

### ១. ការតម្លើងឌីស្យុងទ័រការពារចរន្តលើសតង់ស្យុងមធ្យម

ក. នៅលើខ្សែបណ្តាញតង់ស្យុងមធ្យម ត្រូវតម្លើងឌីស្ស៊ុងទ័រការពារចរន្តលើសមួយ នៅចំណុចចេញនៃអនុស្ថានីយឬ ទីតាំងស្រដៀងគ្នា និងនៅខាងផ្នែកទី១នៃត្រង់ស្វូរម៉ាទ័រ ។

ខ. ឌីស្ស៊ុងទ័រការពារចរន្តលើសសំរាប់ការពារចរន្តឆ្លងប៉ះត្រូវមានលទ្ធភាពអាចកាត់ផ្តាច់ចរន្តឆ្លងប៉ះដែលឆ្លងកាត់តាមឌីស្ស៊ុងទ័រនេះ ។

## ២. ការតម្លើងឌីស្ស៊ុងទ័រការពារចរន្តឆ្លងប៉ះដីតង់ស្យុងមធ្យម

ឌីស្ស៊ុងទ័រការពារចរន្តឆ្លងប៉ះដី ដែលត្រូវកាត់ផ្តាច់សៀគ្វីដោយស្វ័យប្រវត្តិនៅពេលមានការឆ្លងប៉ះដីកើតឡើងនៅលើបណ្តាញ ត្រូវតម្លើងនៅចំណុចចេញនៃអនុស្ថានីយ ឬនៃទីតាំងស្រដៀងគ្នា ។

## ៣. ការតម្លើងឧបករណ៍ចាប់ចរន្តច្រាល

ដើម្បីការពារបរិក្ខាអគ្គិសនីពីការខូចខាតដោយសាររន្ទះ ឧបករណ៍ចាប់ចរន្តច្រាលត្រូវតម្លើងនៅតាមកន្លែងនៃខ្សែបណ្តាញ ដូចបញ្ជាក់ខាងក្រោម ឬនៅតំបន់ជុំវិញកន្លែងនេះ ។ ប្រសិនបើមធ្យោបាយអគ្គិសនីមិនអាចមានការខូចខាតដោយសាររន្ទះទេនោះ លក្ខ័ខណ្ឌនេះមិនបាច់អនុវត្តឡើយ ។

ក. ចំណុចចេញនៃខ្សែបណ្តាញអាកាសពីរោងចក្រអគ្គិសនី អនុស្ថានីយ និងកន្លែងដូចគ្នា ។

ខ. ចំណុចតភ្ជាប់នៃខ្សែបណ្តាញអាកាសតង់ស្យុងមធ្យមជាមួយ ត្រង់ស្វូរម៉ាទ័រមេ ។

## ៣. ករណីលើកលែងក្នុងការតម្លើងឌីសង់ទ័រការពារចរន្តលើសសម្រាប់ខ្សែបណ្តាញតង់ស្យុងមធ្យម និងតង់ស្យុងទាប

មិនតម្រូវឱ្យតម្លើងឌីស្ស៊ុងទ័រការពារចរន្តលើសនៅតាមទីកន្លែងដូចខាងក្រោម :

ក. ខ្សែដីសំរាប់ការងារភ្ជាប់ខ្សែដី

ខ. ខ្សែណឺតនៃខ្សែអគ្គិសនី ។ ទោះជាយ៉ាងនេះក៏ដោយ ឌីស្ស៊ុងទ័រការពារចរន្តលើសអាចត្រូវតម្លើងប្រសិនបើប៉ូលអគ្គិសនីទាំងអស់ ត្រូវកាត់ផ្តាច់ក្នុងពេលជាមួយគ្នា

គ. ខ្សែដីរបស់ខ្សែអាកាសតង់ស្យុងទាប ដែលសៀគ្វីទាំងនោះត្រូវបានភ្ជាប់ខ្សែដីថ្នាក់ ខ ។

## មាត្រា ៤៥. កំពស់នៃខ្សែបណ្ដាញអាកាសតង់ស្យុងមធ្យមនិងតង់ស្យុងទាប

## ១. បទប្បញ្ញត្តិសម្រាប់ខ្សែបណ្ដាញអាកាសតង់ស្យុងមធ្យមនិងតង់ស្យុងទាប

កំពស់ខ្សែបណ្ដាញអាកាសតង់ស្យុងទាប និងតង់ស្យុងមធ្យម មិនត្រូវតូចជាងតម្លៃដែលកំណត់នៅក្នុងតារាងខាងក្រោមនេះឡើយ:

**តារាង ២១ — កំពស់ខ្សែបណ្ដាញអាកាសតង់ស្យុងមធ្យម និងទាប**

**(ខ្នាត: ម៉ែត្រ)**

| | តង់ស្យុងទាប | តង់ស្យុងមធ្យម | | |
|---|---|---|---|---|
| | | តំបន់ទីក្រុង | | តំបន់ដទៃទៀត |
| | | ខ្សែកាប | ខ្សែផ្សេងទៀត | |
| កាត់ទទឹងថ្នល់ | ៦.៥ | ៨.០ | ៨.០ | ៦.៥ |
| ផ្សេងទៀត | ៥.៥ | ៥.៥ | ៦.៥ | ៥.៥ |

## ២. តំបន់ទីក្រុងដែលត្រូវរាប់បញ្ចូល

តំបន់ដូចខាងក្រោម ត្រូវរាប់បញ្ចូលទៅក្នុងតំបន់ទីក្រុង :

**ក. តំបន់**

- ទីក្រុងភ្នំពេញ និងទីក្រុងដទៃទៀត
- ទីរួមខេត្ត

**ខ. ផ្លូវ**

-ផ្លូវជាតិ

-ផ្លូវខេត្ត

### ៣. ករណីលើកលែងសម្រាប់ការឆ្លងកាត់ផ្លូវ

ខ្សែចម្លងដែលស្ថិតក្នុងករណីដូចខាងក្រោម មិនត្រូវបានចាត់ទុកថាឆ្លងកាត់ផ្លូវឡើយ :

- ផ្លូវមានទំហំតូចដែលរថយន្តមិនអាចឆ្លងកាត់បាន
- ផ្លូវស្ថិតក្នុងបរិវេណដីឯកជន

### ៤. ការបន្ធូរបន្ថយកម្ពស់របស់ខ្សែបណ្ដាញតង់ស្យុងទាប

កម្ពស់អប្បបរមារបស់ខ្សែបណ្ដាញតង់ស្យុងទាប អាចបន្ធូរបន្ថយបានរហូតដល់កម្ពស់ ៤ ម៉ែត្រ សម្រាប់ទីកន្លែងដែលគ្មានផ្លូវ ។

## មាត្រា ៤៦_. គម្លាតរវាងខ្សែបណ្ដាញអាកាសតង់ស្យុងមធ្យមនិងតង់ស្យុងទាប និង វត្ថុដទៃទៀត

### ១. គម្លាតរវាងខ្សែបណ្ដាញអាកាស និងអគារ/ដើមឈើ

គម្លាតអប្បបរមារវាងខ្សែបណ្ដាញមួយជាមួយវត្ថុផ្សេងទៀតត្រូវមានតម្លៃដូចការកំណត់ក្នុងតារាង ២២ ក ។

### តារាង ២២ ក ~ គម្លាតរវាងខ្សែបណ្ដាញអាកាសនិងវត្ថុដទៃទៀត

(ខ្នាត: ម៉ែត្រ)

| | | | | តង់ស្យុងទាប | តង់ស្យុងមធ្យម |
|---|---|---|---|---|---|
| ជាមួយអគារ | នៅខាងលើ | ដែលមនុស្សមានលទ្ធភាពឡើងបាន | ខ្សែស្រាត | - | ៣.០ |
| | | | ខ្សែស្រោម | ២.០ | ២.៥ |
| | | | ខ្សែកាប | ១.០ | ១.២ |
| | | ផ្សេងទៀត | ខ្សែស្រាត | - | ៣.០ |
| | | | ខ្សែស្រោម | ១.២ | ១.៥ |
| | | | ខ្សែកាប | ០.៤ | ០.៥ |
| | នៅចំហៀង និង នៅខាងក្រោម | | ខ្សែស្រាត | - | ៣.០ |
| | | | ខ្សែស្រោម | ១.២ | ១.៥ |
| | | | ខ្សែកាប | ០.៤ | ០.៥ |
| ជាមួយដើមឈើ | | | ខ្សែស្រាត | - | ២.០ |
| | | | ខ្សែស្រោម | មិនត្រូវឱ្យមានការប៉ះផ្ទាល់ទេ | |
| | | | ខ្សែកាប | មិនត្រូវឱ្យមានការប៉ះផ្ទាល់ទេ | |

ខ្សែស្រោមប្រភេទ ABC (Aerial Bundle Conductor) តង់ស្យុងទាប អាចតម្លើងផ្ទាល់ជាប់នឹងជញ្ជាំងអគារបាន ដោយប្រើក្រចាប់ និងវិធីចាប់ភ្ជាប់ពិសេសរបស់ខ្សែស្រោមប្រភេទនេះ ប៉ុន្តែទីតាំងជញ្ជាំងដែលអាចចាប់ភ្ជាប់បាន គឺត្រូវជាទីតាំងមួយដែលមនុស្សពិបាកឡើងដល់ ។

## ២. គម្លាតរវាងខ្សែបណ្ដាញចែកចាយអាកាសនិងផ្លូវថ្នល់

នៅពេលបង្គោលទ្រត្រូវបានតម្លើងទាបជាងផ្លូវ គម្លាតអប្បបរមារវាង ខ្សែបណ្ដាញនិងផ្លូវត្រូវមានតម្លៃដូចមានក្នុងតារាង ២២ ខ និង ២២ គ :

**តារាងទី ២២ ខ ៖ គម្លាតរវាងខ្សែបណ្ដាញនិងផ្លូវនៅលើច្រាំងខ្ពស់ (ខ្នាត៖ ម៉ែត្រ)**

| | ប្រភេទខ្សែ | តង់ស្យុងទាប | តង់ស្យុងមធ្យម |
|---|---|---|---|
| ចម្ងាយផ្ទាល់ | ខ្សែស្រាត | - | ៣.០ |
| | ខ្សែស្រោម | ៣.០ | ៣.០ |
| | ខ្សែកាប | ៣.០ | ៣.០ |
| ចម្ងាយតាមផ្ទៃលាត | ខ្សែស្រាត | - | ៣.០ |
| | ខ្សែស្រោម | ១.០ | ១.៥ |
| | ខ្សែកាប | ១.០ | ១.២ |

* ប្រសិនបើ ចម្ងាយតាមផ្ទៃលាតដូចគ្នានឹងចម្ងាយផ្ទាល់ ចម្ងាយតាមផ្ទៃលាត ត្រូវយកតម្លៃដូចចម្ងាយផ្ទាល់ ។







* ប្រសិនបើ ចម្ងាយតាមផ្ទៃលាតដូចគ្នានឹងចម្ងាយផ្ទាល់ ចម្ងាយតាមផ្ទៃលាត ត្រូវយកតម្លៃដូចចម្ងាយផ្ទាល់

**រូបភាព ១២ ៖ ពន្យល់អំពីចម្ងាយផ្ទាល់និងចម្ងាយតាមផ្ទៃលាត(ផ្លូវនៅលើច្រាំងខ្ពស់)**

## តារាងទី ២២ គ ~ គម្លាតអប្បបរមារវាងខ្សែបណ្ដាញនិងស្ពានឆ្លងកាត់ផ្លូវ

(ខ្នាត: ម៉ែត្រ)

| | ប្រភេទខ្សែ | តង់ស្យុងទាប | តង់ស្យុងមធ្យម |
|---|---|---|---|
| ខ្សែបណ្ដាញនៅផ្នែកខាងលើ | ខ្សែស្រាត | មិនអនុញ្ញាតឱ្យប្រើ | ចម្ងាយផ្ទាល់ ៣,០ |
| | ខ្សែស្រោម | ចម្ងាយផ្ទាល់ ៣,០ ឬ ចម្ងាយតាមផ្ទៃលាត ១,០ | ចម្ងាយផ្ទាល់ ៣,០ ឬ ចម្ងាយតាមផ្ទៃលាត ១,៥ |
| | ខ្សែកាប | * ចម្ងាយផ្ទាល់ ៣,០ ឬចម្ងាយតាម ផ្ទៃលាត ១,០ | * ចម្ងាយផ្ទាល់ ៣,០ ឬចម្ងាយតាមផ្ទៃ លាត ១,២ |
| ខ្សែបណ្ដាញនៅផ្នែកខាងក្រោម | ខ្សែស្រាត | មិនអនុញ្ញាតឱ្យប្រើ | ចម្ងាយផ្ទាល់ ៣,០ |
| | ខ្សែស្រោម | ចម្ងាយផ្ទាល់ ០,៦ | ចម្ងាយផ្ទាល់ ១,៥ |
| | ខ្សែកាប | ចម្ងាយផ្ទាល់ ០,៣ | ចម្ងាយផ្ទាល់ ០,៥ |

* ត្រូវកំណត់ទាំងចម្ងាយតាមផ្ទៃលាតនិងចម្ងាយផ្ទាល់

ករណីខ្សែបណ្ដាញនៅផ្នែកខាងលើ



ករណីខ្សែបណ្តាញនៅផ្នែកខាងក្រោម




**រូបភាពទី ១៣ ~ ពន្យល់អំពីចម្ងាយផ្ទាល់ និងចម្ងាយតាមផ្ទៃលាត(សម្រាប់ស្ពានឆ្លងកាត់)**

## មាត្រា ៤៧~. លក្ខខណ្ឌនៅជិតគ្នានិងកាត់ខ្វែងគ្នានៃខ្សែបណ្តាញអាកាសតង់ស្យុងមធ្យមនិងតង់ស្យុងទាប

### ១. ខ្សែបណ្តាញតង់ស្យុងមធ្យមច្រើន

នៅពេលខ្សែបណ្តាញតង់ស្យុងមធ្យមមួយ ត្រូវបានតម្លើងជិតគ្នាឬខ្វែងគ្នាជាមួយខ្សែបណ្តាញតង់ស្យុងមធ្យមមួយផ្សេងទៀតគម្លាតរវាងខ្សែបណ្តាញតង់ស្យុងមធ្យមទាំងពីរនោះត្រូវមានប្រវែងយ៉ាងតិចបំផុត២.០ម៉ែត្រ ។ ប្រសិនបើខ្សែមួយជាខ្សែកាបហើយខ្សែមួយទៀតក៏ជាខ្សែកាបដែរ ឬជាខ្សែស្រោម ពេលនោះគម្លាតត្រូវមានប្រវែងយ៉ាងតិច ០.៥ ម៉ែត្រ ។

### ២. ខ្សែបណ្តាញតង់ស្យុងមធ្យមនិងខ្សែបណ្តាញតង់ស្យុងទាប

នៅពេលខ្សែបណ្តាញតង់ស្យុងមធ្យមនិងខ្សែបណ្តាញតង់ស្យុងទាបត្រូវដាក់តម្លើងជិតគ្នាឬខ្វែងគ្នាពេលនោះខ្សែបណ្តាញទាំងនោះត្រូវតែតម្លើងតាម របៀបដូចខាងក្រោម :

- ខ្សែបណ្តាញតង់ស្យុងមធ្យម មិនត្រូវតម្លើងនៅក្រោមខ្សែបណ្តាញតង់ស្យុងទាបឡើយ ។ ប្រសិនបើខ្សែបណ្តាញតង់ស្យុងមធ្យមអាចរក្សាប្រវែងគម្លាតតាមខ្សែដេកមិនតិចជាង ៣.០ ម៉ែត្រជាមួយខ្សែបណ្តាញតង់

ស្បុងទាបហើយខ្សែបណ្ដាញតង់ស្យុងទាបមិនអាចងាកទៅប៉ះនឹងខ្សែបណ្ដាញតង់ស្យុងមធ្យមនៅពេល ដែលបង្គោលខ្សែបណ្ដាញតង់ស្យុងទាបរលំពេលនោះល័ក្ខខ័ណ្ឌខាងលើមិនបាច់អនុវត្តឡើយ ។

- គម្លាតរវាងខ្សែបណ្ដាញតង់ស្យុងមធ្យម និងខ្សែបណ្ដាញតង់ស្យុងទាបមិនត្រូវតិចជាង ០.៥ ម៉ែត្រ ឡើយ នៅពេលដែលខ្សែបណ្ដាញតង់ស្យុងមធ្យមជាខ្សែកាប មិនត្រូវតិចជាង ១.០ ម៉ែត្រ ឡើយ នៅពេលវាជាខ្សែស្រោម និងមិនត្រូវតិចជាង២.០ម៉ែត្រឡើយនៅពេលវាជាខ្សែស្រាត ។
- ខ្សែបណ្ដាញតង់ស្យុងមធ្យមមិនត្រូវកាត់ខ្វែងពីក្រោមខ្សែបណ្ដាញតង់ស្យុងទាបឡើយ ។ ប្រសិនបើខ្សែបណ្ដាញតង់ស្យុងមធ្យមជាខ្សែកាប ហើយគម្លាតរវាងខ្សែបណ្ដាញតង់ស្យុងមធ្យម និងខ្សែបណ្ដាញតង់ស្យុងទាប មានប្រវែងមិនតិចជាង ០.៥ ម៉ែត្រនោះ ល័ក្ខខ័ណ្ឌខាងលើនេះមិនបាច់អនុវត្តឡើយ ។

## ៣. ខ្សែបណ្ដាញតង់ស្យុងទាបច្រើន

នៅពេលដែលខ្សែបណ្ដាញតង់ស្យុងទាបត្រូវតម្លើងជិតគ្នា ឬខ្វែងគ្នា ទៅនឹងបណ្ដាញខ្សែតង់ស្យុងទាបផ្សេងទៀត ពេលនោះ គម្លាតរវាងខ្សែបណ្ដាញតង់ស្យុងទាបទាំងពីរ ត្រូវមានប្រវែងយ៉ាងតិចបំផុត ០.៦ ម៉ែត្រ ។ នៅពេល ខ្សែមួយជាខ្សែកាប និងខ្សែមួយទៀតជាខ្សែកាបដែរ ឬជាខ្សែស្រោម ពេលនោះ គម្លាតត្រូវមានប្រវែងយ៉ាងតិចបំផុត ០.៣ ម៉ែត្រ ។

## ៤. ខ្សែបណ្ដាញតង់ស្យុងមធ្យមនិងខ្សែបណ្ដាញគមនាគមន៍

នៅពេលដែលខ្សែបណ្ដាញតង់ស្យុងមធ្យមត្រូវតម្លើងជិតគ្នា ឬខ្វែងគ្នា ជាមួយខ្សែបណ្ដាញគមនាគមន៍ ពេលនោះ ខ្សែបណ្ដាញតង់ស្យុងមធ្យមត្រូវតម្លើងតាមវិធីដូចខាងក្រោម :

- ខ្សែបណ្ដាញតង់ស្យុងមធ្យមមិនត្រូវតម្លើងក្រោមខ្សែបណ្ដាញគមនាគមន៍ឡើយ ។ ប្រសិនបើខ្សែបណ្ដាញតង់ស្យុងមធ្យម រក្សាគម្លាតតាមខ្សែដេកមិនទាបជាង០.៣ម៉ែត្រ ជាមួយខ្សែបណ្ដាញគមនាគមន៍ហើយខ្សែបណ្ដាញគមនាគមន៍ក៏មិនអាចប៉ះទៅនឹងខ្សែបណ្ដាញតង់ស្យុងមធ្យម នៅពេលបង្គោលនៃខ្សែបណ្ដាញគមនាគមន៍រលំពេលនោះ លក្ខ័ខ័ណ្ឌខាងលើអាចមិនអនុវត្តបាន ។
- គម្លាតរវាងខ្សែបណ្ដាញតង់ស្យុងមធ្យម និងខ្សែបណ្ដាញ គមនាគមន៍ត្រូវយ៉ាងតិចបំផុត ០.៥ម៉ែត្រ នៅពេលដែលខ្សែបណ្ដាញតង់ស្យុងមធ្យមជាខ្សែកាបត្រូវយ៉ាងតិចបំផុត១.០ម៉ែត្រ នៅពេលដែលខ្សែជាខ្សែស្រោមនិងត្រូវយ៉ាងតិចបំផុត២.០ម៉ែត្រ នៅពេលដែលខ្សែជាខ្សែស្រាត ។

- ខ្សែបណ្តាញតង់ស្យុងមធ្យម មិនត្រូវកាត់ខ្វែងក្រោមខ្សែបណ្តាញគមនាគមន៍ឡើយ ។ ប្រសិនបើខ្សែបណ្តាញតង់ស្យុងមធ្យមជាខ្សែកាបហើយគម្លាតរវាងខ្សែបណ្តាញតង់ស្យុងមធ្យម និងខ្សែបណ្តាញគមនាគមន៍យ៉ាងតិចបំផុត ០.៥ ម៉ែត្រ ពេលនោះ ល័ក្ខខ័ណ្ឌខាងលើអាចមិនអនុវត្តបាន ។

## ៥. ខ្សែបណ្តាញតង់ស្យុងទាបនិងខ្សែបណ្តាញគមនាគមន៍

នៅពេលខ្សែបណ្តាញតង់ស្យុងទាបត្រូវតម្លើងជិតគ្នា ឬកាត់ខ្វែងគ្នា ជាមួយខ្សែបណ្តាញគមនាគមន៍នោះ ខ្សែបណ្តាញតង់ស្យុងទាបត្រូវតម្លើង តាមវិធីដូចខាងក្រោម :

- ខ្សែបណ្តាញតង់ស្យុងទាបមិនត្រូវកាត់ខ្វែងក្រោមខ្សែបណ្តាញគមនាគមន៍ឡើយ ។ ប្រសិនបើវិធីដទៃទៀតមិនមានលក្ខណៈបច្ចេកទេសជាក់ស្តែងដើម្បីអនុវត្តបាននោះ ល័ក្ខខ័ណ្ឌនេះអាចមិនអនុវត្តបាន ។

- គម្លាតរវាងខ្សែបណ្តាញតង់ស្យុងទាប និងខ្សែបណ្តាញគមនាគមន៍មិនត្រូវតិចជាង ០.៣ ម៉ែត្រឡើយ នៅពេលដែលខ្សែបណ្តាញតង់ស្យុងទាបជាខ្សែកាប និងមិនតិចជាង០.៦ម៉ែត្រឡើយ នៅពេលដែលខ្សែជាខ្សែស្រាម ។